ទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- តើមិនមានយុត្តិធម៌នៅឆ្នាំ២០០៨ដែរឬទេ
- តុលាការនៅលើវ៉ែពេទតើក

លេខ១០៨ ខែធ្នូ ឆ្នាំ២០០៨

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២៥ ខែមករា ឆ្នាំ២០០២


## មាតិកា


◆ សំបុត្រៈ តើនឹងមានយុត្តិធម៌នៅឆ្នាំ២០០២ដែរឬទេ? .............១

### ផ្នែកឯកសារ

◆ សុន្ទរកថារបស់ ហ៊ូ យន់ ...........................................៣

◆ និរសាឯកសារប្រវត្តិសាស្ត្រ ........................................៧

◆ ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍ .......................១០

◆ គោលនយោបាយប្រឆាំងខ្មែរក្រហម .............................១២

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ ........១៦

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ រូបថតឯកសារ.........................................................១៨

◆ សម្លេងពីមន្ទីរ ស-២១ ..................................................២១

◆ ទំនាក់ទំនងចិននិងកម្ពុជាប្រជាធិបតេយ្យ..............................២៦

◆ អាពាហ៍ពិពាហ៍ខ្មែរក្រហម..................................................២៩

### ផ្នែកច្បាប់

◆ ការកាត់ទោសប្រហារជីវិត...............................................៣២

◆ តុលាការនៅទីម័រខាងកើត ...............................................៣៥

### វេទិកាពិភាក្សាសាធារណៈ

◆ មិនយុត្តិធម៌ក្នុងអយុត្តិធម៌................................................៤០

◆ តុលាការក្នុងស្រុកឲ្យតែមានបទដ្ឋានយុត្តិធម៌អន្តរជាតិ.............៤២

◆ អន្តរាគមន៍របស់អង្គការណាតូនៅកូសូវ៉ូ...................................៤៨

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ ជីវប្រវត្តិរបស់បងស្រី អ៊ុម ផល្លី...........................................៥៦

### សិល្បៈខ្មែរក្រហមៈ

◆ រឿងប្រលោមលោកបដិវត្តខ្មែរក្រហមៈ ពលិកម្មម៉ែៗយើង .....៥៩

◆ ចម្រៀងៈ យើងខ្ញុំប្រជាជនសូមសរសើរបងប្អូនកងទ័ព........ក្របក្រោយ






# រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម.៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**វាគ្មិនលេខនេះៈ** ដេង ពង្សរ៉ាស៊ី, យិន នាន, វ៉ាន់ថាន់ ពៅដារ៉ា, អ៊ីសា ឧស្មាន, ហ៊ុយ វេងរតនា, ឡុង អូន, អេលីហ្សាប៉ែត វ៉ាន់ស្កាក់, ដេវីដ វេនដល់រ, ទូច បូរ៉ា, ស៊ូហ្សាណា លីនគុន **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, ដួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងទី១ៈ** សួ ប៊ុនស៊ូ **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** សុខ វណ្ណៈ

*សំបុត្រៈ*

# តើនឹងមានយុត្តិធម៌នៅឆ្នាំ២០០២ ដែរឬទេ?

មកទល់នឹងពេលនេះមានការពិភាក្សាវែកញែកអំពីរឿងយុត្តិធម៌ច្រើនណាស់ រួមមានគឺយុត្តិធម៌សម្រាប់ ប៊ីនឡាដិន យុត្តិធម៌សម្រាប់ជនរងគ្រោះរបស់ ប៊ីនឡាដិន យុត្តិធម៌នៅក្នុងតុលាការយោធាជាដើម ។ នៅប្រទេសសេរ៉ាឡេអូន អង្គការសហប្រជាជាតិកំពុងតែជួយជ្រោមជ្រែងឲ្យមានការបង្កើតឡើងនូវតុលាការពិសេសមួយ ។ សូម្បីតែនៅទីក្រុងប៊ែលក្រាតដែលជាអតីតទីក្រុងនៃរបបប្រល័យពូជសាសន៍ គណបក្សសែប៊ីដ៏ធំជាងគេបានសម្រេចចិត្តបណ្តេញចេញពីគណបក្សនូវសមាជិកទាំងឡាយណាដែលទទួលខុសត្រូវពីបទឧក្រិដ្ឋកម្មដ៏យង់ឃ្នងដែលប្រព្រឹត្តឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ។ ក្នុងនោះមានឈ្មោះ ឡាឌីក និងការ៉ាដហ្ស៊ីក ដែលតុលាការបានចោទប្រកាន់ថាជាឧក្រិដ្ឋជនសង្គ្រាម ។

តើការជជែកវែកញែកគ្នាអំពីយុត្តិធម៌ប្រល័យពូជសាសន៍នៅកម្ពុជានឹងចេញតាមច្រកណា? តើយុត្តិធម៌សម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហមខិតកាន់តែជិតមកដល់ហើយឬនៅ?

ទោះបីជា អូស្សា ប៊ីនឡាដិន មេដឹកនាំអង្គការអាល់គីដា និងកូនចៅរបស់ខ្លួនបង្កឲ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់សហ-រដ្ឋអាមេរិកយ៉ាងណាក៏ដោយ ក៏សហរដ្ឋអាមេរិកអាចកសាងសំណង់អគារបាក់បែកទាំងនោះសាជាថ្មី ហើយនឹងមានភាពរឹងមាំព្រមទាំងធានាសន្តិសុខបានល្អប្រសើរជាងមុន ។ ថ្ងៃវិនាសកម្មបង្កឡើងដោយតាលីបង់និងសមមិត្តរបស់ខ្លួនឥឡូវនេះត្រូវបានបញ្ចប់ហើយ ចំណែកឯការវាយប្រហាររបស់ក្រុមភេរវករនេះក៏គ្មានប៉ះពាល់ដល់មូលដ្ឋានគ្រឹះរបស់ជាតិនិងប្រជាជនអាមេរិកាំងដែរ ។

ផ្ទុយមកវិញ ប៉ុល ពត មិនបានប្រើបច្ចេកវិទ្យាទំនើបដូចជា ប៊ីនឡាដិន ទេ ប៉ុន្តែ ប៉ុល ពត និងមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យដទៃទៀត អាចសម្លាប់មនុស្សបានរហូតដល់ទៅរាប់លាននាក់និងធ្វើឲ្យប្រទេសកម្ពុជាក្លាយជាគំនរដេះដង ។ អាវុធដ៏ពិសពុលរបស់ខ្មែរក្រហមគឺនយោបាយនិងគោលការណ៍របស់អង្គការ ដែលបានក្តោបក្តាប់គ្រប់ជ្រុងជ្រោយទាំងអស់នៃជីវិតរបស់ប្រជាជនកម្ពុជា ។ មរតកឆ្អួតព្រៃផ្សៃទាំងនេះស្ថិតនៅជាមួយប្រជាជនកម្ពុជារហូតមកដល់សព្វថ្ងៃ ហើយមិនមែនមាននៅក្នុងពេលវេលាដែលកម្ពុជាមិនទាន់មានការអភិវឌ្ឍផ្នែកនយោបាយនិងសេដ្ឋកិច្ចកិច្ចតែប៉ុណ្ណោះទេ គឺវាថែមទាំងបានជិតដាមនៅក្នុងរចនាសម្ព័ន្ធសង្គមទាំងមូលដែលជាឥទ្ធិពលអវិជ្ជមានបង្កឡើងដោយការវាយប្រហារឥតឈប់ឈរមកលើសង្គមគ្រួសារខ្មែរ ។

ជាងប្រាំពីរឆ្នាំក្រោយពីសភាអាមេរិកាំងបានអនុម័តច្បាប់ស្តីអំពីយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ពោលគឺនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ បានឡាយព្រះហស្តលេខាលើច្បាប់ស្តីពីការបង្កើតតុលាការពិសេសសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ មាត្រា១នៃច្បាប់នេះចែងថា *“ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា រំលោភទៅលើច្បាប់និងទម្លាប់អន្តរជាតិហើយនិងរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩”* ។

ទម្រាំតែមានការអនុម័តច្បាប់ឲ្យមានការរៀបចំតុលាការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមគឺប្រើរយៈពេលរហូតដល់ទៅជាង៧ឆ្នាំគឺមានរយៈពេល៤ឆ្នាំលើសពេលវេលាដែលខ្មែរក្រហមបានសម្លាប់និងបង្អត់អាហារប្រជាជនកម្ពុជាអស់រាប់លាននាក់ ។ អស់រយៈពេល២៣ឆ្នាំក្រោយពីការដួលរលំនៃរបបខ្មែរក្រហមជនរងគ្រោះនៅតែបន្តរង់ចាំយុត្តិធម៌និងការពិត ។ ចំណែកឯ

មេដឹកនាំរបបខ្មែរក្រហមវិញចេះតែបន្តរស់នៅពោរពេញទៅដោយសេរីភាពនៅចំពោះមុខជនរងគ្រោះរបស់ខ្លួន ។ នៅក្នុងខណៈពេលដែលជនរងគ្រោះនៃរបបខ្មែរក្រហមកំពុងរស់នៅក្នុងស្ថានភាពបានព្រឹកខ្វះល្ងាច មេដឹកនាំខ្មែរក្រហមមួយចំនួនដូចជា អៀង សារី និង អៀង ធីរិទ្ធ ធ្វើដំណើរយ៉ាងរំភើយទៅកាន់ប្រទេសថៃដើម្បីព្យាបាលជំងឺដោយចំណាយថវិកាយ៉ាងច្រើន ។

នៅពេលដែលដំណើរតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមកំពុងតែឈានមកដល់គោលដៅរបស់ខ្លួនក្នុងការផ្តល់យុត្តិធម៌សម្រាប់ជនរងគ្រោះក្នុងកម្រិតណាមួយនោះគឺសំខាន់ណាស់ក្នុងការធ្វើឲ្យកិច្ចខិតខំប្រឹងប្រែងក្នុងដំណើរការជំនុំជម្រះក្តីនេះទៅមុខប្រកបដោយផ្លែផ្កា ។

ក្នុងរយៈពេលប៉ុន្មានខែកន្លងទៅថ្មីៗនេះ ពិភពលោកទាំងមូលផ្តោតការយកចិត្តទុកដាក់ទៅលើយុត្តិធម៌សម្រាប់ ប៊ីនឡាដិន និងកូនចៅរបស់ខ្លួន ។ ជាការច្បាស់ណាស់ គឺត្រូវតែមានកិច្ចខិតខំប្រឹងប្រែងឲ្យអស់លទ្ធភាពក្នុងការចាប់ខ្លួននិងនាំខ្លួនបុគ្គលទាំងនោះមកកាន់តុលាការដើម្បីកាត់ទោសចំពោះមុខច្បាប់អំពីឧក្រិដ្ឋកម្មដែលបុគ្គលទាំងនេះបានប្រព្រឹត្ត ។ ប៉ុន្តែគួរឲ្យសោកស្តាយបច្ចុប្បន្ននេះ សហគមន៍អន្តរជាតិបង្ហាញចំណាប់អារម្មណ៍តិចតួចណាស់ក្នុងការស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជានិងមនុស្សជាតិទូទៅ ។ ការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសគឺជាការមិនលំបាកច្រើន ហើយការងារនេះអាចសម្រេចបានគ្រាន់តែចំណាយកិច្ចខិតខំប្រឹងប្រែងតែមួយចំណិតតូចប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងការប្រយុទ្ធប្រឆាំងនឹងបណ្តាញអង្គការអាល់គីដានៃតាលីបង់ ។ អ្វីដែលត្រូវការជាចាំបាច់គឺគ្រាន់តែយកសុឆន្ទៈនយោបាយរបស់សហគមន៍អន្តរជាតិនិងកម្ពុជាមកប្រសព្វគ្នាជាការស្រេចបាត់ទៅហើយ ។ ការប្រជុំគ្នានេះបានខិតមកជិតហើយ ប៉ុន្តែសន្ទុះទៅមុខហាក់ដូចជាកាន់តែយឺតទៅៗ ។ ទង្វើបែបនេះមិនគួរបណ្តោយឲ្យមានឡើយ ។

តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនឹងចេញជារូបរាងក្នុងពេលឆាប់ៗខាងមុខនេះ ត្រូវតែផ្តល់នូវភាពយុត្តិធម៌និងត្រូវធ្វើឲ្យដំណើរការជំនុំជម្រះក្តីមានភាពសុក្រឹតចំពោះជនរងគ្រោះនិងជនដៃដល់ ។

**ឆាំង យុ**



ប្រជាជនកម្ពុជានិងព្រះសង្ឃចូលរួមនៅក្នុងតុលាការ កាត់ទោសមេដឹកនាំខ្មែរក្រហម ប៉ុល ពត អៀង សារី នៅឆ្នាំ១៩៧៩

# សុន្ទរកថារបស់ ហ៊ូ យន់

## ថ្ងៃ៣០ខែកញ្ញាឆ្នាំ១៩៧៤នៅក្នុងឱកាសបុណ្យខួបទី២៣ ស្ដីអំពីប្រវត្តិតស៊ូនៅស្រុកអមលាំង

(ឯកសារលេខD២១៣០៦)


ហ៊ូ យន់

ខួបលើកទី២៣ជាប្រវត្តិនៃការតស៊ូរបស់បក្សកុម្មុយនិស្តកម្ពុជាបានត្រូវគណៈកម្មាធិការកណ្ដាលនៃបក្សកុម្មុយនិស្តកម្ពុជាប្រារព្វធ្វើឡើងនាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៤ នៅស្រុកអមលាំង(ខេត្តកំពង់ស្ពឺ) ។ ពិធីរំឭកនេះមានការចូលរួមពីប្រជាជនក្របខ័ណ្ឌខ្មែរក្រហម "បក្ខជន" កម្លាំងប្រដាប់អាវុធនិងប្រជាជនរំដោះជាតិកម្ពុជា មកពីគ្រប់ទិសទី ។

ក្នុងឱកាសនោះ ដួ ដេត បានឡើងប្រកាសបើកកម្មវិធី ។ សំឡេងខគ្សោសនស័ព្ទបានលាន់ឡើង បណ្ដាកងកម្លាំងប្រដាប់អាវុធទាំងអស់បានទម្លាក់អាវុធចុះសង្រួមឥរិយាបថដើម្បីគោរពទង់ជាតិនិងវិញ្ញាណក្ខន្ធ ។ ហ៊ូ យន់ បានឡើងថ្លែងសុន្ទរកថាអស់រយៈពេល១ម៉ោង ។ សេចក្ដីថ្លែងការណ៍នោះមានអត្ថន័យដូចខាងក្រោម ÷

នៅក្នុងសង្គ្រាមលោកលើកទី២ ប្រទេសកម្ពុជាត្រូវបានមហាអំណាចគ្រប់សង្កត់មកលើ បណ្ដាលឲ្យប្រជាជនខ្មែរមានការលំបាកវេទនា ។ ប្រជាជននៅក្នុងឥណ្ឌូចិនបានពួតដៃគ្នាតស៊ូជាមួយពួកអាណានិគមបារាំងតាំងពីឆ្នាំ១៩៥១មកម្ល៉េះ ។

ក្រោយពេលសង្គ្រាមបានស្ងប់ មហាអំណាចនានានិងប្រទេសជាច្រើនបានចូលរួមសន្និសីទមួយនៅក្រុងហ្សឺណែវស្ដីអំពីប្រទេសឥណ្ឌូចិន ដែលមានប្រទេសរុស្ស៊ីជាតំណាង ។ ប៉ុន្តែកម្ពុជាពុំបានចាត់តាំងអ្នកតំណាងណាម្នាក់ទៅចូលរួមក្នុងអង្គប្រជុំទេ គឺមានតែថៃនិងវៀណាមខាងជើង"ហូជីមិញ" ប៉ុណ្ណោះដែលបានចូលរួម ។ នៅពេលនោះសន្និសីទក្រុងហ្សឺណែវបានសម្រេចឲ្យហូជីមិញត្រួតត្រានៅឥណ្ឌូចិនទាំងមូល ។ សន្និសីទនេះបានបង្ហាញឲ្យឃើញថាប្រទេសកម្ពុជានឹងត្រូវរលុបបាត់ពីផ្ទាំងគំនូរផែនទីពិភពលោក ។ ដោយយល់សភាពការណ៍នេះទើបមានវរជនខ្មែរបីរូប ឈ្មោះ អៀវ កើស, យុត្តិវង្ស និង សឺង ង៉ុកថាញ់ ធ្វើដំណើរទៅចរចា ។ ប៉ុន្តែការចរចាបានហួសពេលទៅហើយ ។ អ្នកទាំងបីក៏បានបែកផ្លូវគ្នាដើរប្រមូលកម្លាំង ។ អៀវ កើស បានធ្វើការឃោសនាតាមកំហឹងមានះ ។ សឺង ង៉ុកថាញ់ បែរទៅរកបក្ស"សេ.អា.តូ" ។ យុត្តិវង្ស ងាកទៅខាងបក្សប្រជាធិបតេយ្យ ។ ដោយឃើញអ្នកទាំងបីធ្វើការរបៀបនេះ **រាជ្យ** ក៏កម្ចាត់អ្នកទាំងបីចេញអស់ពីប្រទេស ខ្លះស្លាប់ដោយឃាតកម្មយ៉ាងបិទមុខ ។

សង្គ្រាមឥណ្ឌូចិននៅតែបន្តពុំចេះចប់ កិច្ចប្រជុំក្រុងហ្សឺណែវ បានធ្វើឡើងម្ដងទៀត ។ នៅក្នុងសន្និសីទលើកនេះមានប្រទេសបីចូលរួមៈ កម្ពុជា លាវ និងវៀតណាម ។ ដោយសារការតស៊ូយ៉ាងប្ដូរផ្ដាច់ទាំងក្នុងនិងក្រៅប្រទេស កម្ពុជាក៏បានទទួលឯករាជ្យយ៉ាងជោគជ័យ ប៉ុន្តែឯករាជ្យនោះបានតែលើពួករាជសម្បត្តិនិងសក្តិភូមិប៉ុណ្ណោះ ឯប្រជាជនកម្ពុជារស់នៅក្រោម

ការជិះជាន់ដដែល ។

អាស្រ័យហេតុនេះទើបអង្គការបក្សមិនព្រមរួមសហការ ។ អង្គការបក្សបានចាត់តាំងជាផ្នែក១ មួយផ្នែកទៅសិក្សានៅប្រទេសវៀតណាមខាងជើង មួយផ្នែកទៀតទៅចលនានយោបាយនៅតាមទីក្រុង និងមួយផ្នែកទៀតចលនានយោបាយនៅតាមជនបទ ។ នៅឆ្នាំ១៩៦០ ចលនារបស់អង្គការបក្សកាន់តែរីកចំរើន រហូតដល់សម្តេច សីហនុ ក្តៅក្រហាយ ខ្លាចរាជបល្ល័ង្ក និងរបបសក្តិភូមិរលំរលាយ ក៏តាំងខ្លួនជាអ្នកជំនួញអូសទាញកម្មាជីពនិងបក្សសម្ព័ន្ធ "យុវកកស.ន.ក.ប" ដោយចំហ ។ ក្នុងរយៈកាលនោះ ដំណើរការបក្សមានភាពច្របូកច្របល់ខ្លាំង ព្រោះថា សម្ព័ន្ធស.ន.ក.ប និងកម្មាភិបាលជាច្រើនរត់ទៅនៅក្នុងព្រៃ ខ្លះរត់មិនទាន់ត្រូវដៃជើង សីហនុ សម្លាប់នៅកណ្តាលទីក្រុងដូចជាមិត្ត បូដាន់ ។ល ។ ខ្លះទៀតត្រូវកងទ័ព សីហនុ តាមសម្លាប់រហូតដល់ជនបទដូចជា មិត្ត ស៊ិន និង សេង គឹមអាយ ជាដើម ។ ដំណាក់កាលនេះហើយដែលបណ្តាជន និស្សិត សិស្ស សាស្ត្រាចារ្យបានចាកចេញពីទីក្រុងទៅលាក់ខ្លួននៅតាមខ្នងភ្នំកំចាយ ចំការលើ និងភ្នំអូរ៉ាល់ បណ្តាលឲ្យបាត់បង់ជីវិតអស់មួយចំនួនដោយពុលចំណីអាហារ រលាកក្រពះ និងជំងឺគ្រុនចាញ់ ។

នៅឆ្នាំ១៩៦២-៦៤ អង្គការបក្សឃើញថា កម្មាជីពមួយផ្នែកដែលនៅកំពុងលាក់ខ្លួនតាមជនបទមានការលំបាកគ្រប់ជំហាន ទើបបក្សបានសម្រេចឲ្យកម្មាជីពទាំងអស់ក្រោកឈរតស៊ូដោយកម្លាំងអាវុធវិញ ។

នៅក្នុងឆ្នាំ១៩៦៨មានការផ្ទុះអាវុធជាលើកដំបូង អង្គការបក្សបានចាត់តាំងឲ្យកម្មាជីពវាយដណ្តើមយកអាវុធពីក្រសួងនានានៅតាមជនបទក៏ដូចជាក្រសួងរុក្ខាប្រមាញ់និងកងឈ្លបនានា ឯកម្មាជិកសម្ព័ន្ធស.ន.ក.ប-យុវកក នៅភ្នំពេញខំប្រឹងធ្វើចលនាយ៉ាងពេញទំហឹងតាមមធ្យោបាយផ្សេង១ ។

ឆ្នាំ១៩៦៨ អង្គការបានបំផុសចលនាវណ្ណៈពលករបានយ៉ាងច្រើន ព្រោះមានតែវណ្ណៈនេះទេដែលជាឫសគល់នៃបក្ស ។ នៅក្នុងឆ្នាំដដែល អង្គការបានដឹកនាំវណ្ណៈនេះឲ្យងើបប្រឆាំងនឹងគម្រោងការផ្សេង១ដែលជាអំពើព្រៃផ្សៃរបស់ស្តេចសក្តិភូមិ "សីហនុ" ។ នៅក្នុងឆ្នាំនៃការបះបោរនេះ សម្ព័ន្ធរបស់បក្សបានស្លាប់បាត់បង់ជីវិតប្រហែល១០០០នាក់ ។

ក្នុងចន្លោះឆ្នាំ១៩៥៤-៧០ មុនថ្ងៃ១៧ ខែមីនា មានបក្សមួយផ្សេងទៀតចូលមករំលំរបបរាជាសក្តិភូមិនេះដែរ ។ គម្រោងការណ៍លើកទី១ តាមរយៈការអញ្ជើញសម្តេច សីហនុ ទៅសម្ភោធនៅផ្ទះ ឈួន ម្ជុលពេជ ហៅ ដាបឈួន ។ គម្រោងការរដ្ឋប្រហារលើកទី២គឺនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៦៩ គឺផ្ញើកេស(ឥវ៉ាន់)មកពីហុងកុង ។ គម្រោងការរដ្ឋប្រហារនេះមិនទាន់បានសម្រេចទេ ដោយសារតែអង្គការបក្សប្រាប់ឲ្យសម្តេច សីហនុ ដឹងមុន ព្រោះអង្គការបក្សយល់ឃើញថា បើបណ្តោយឲ្យបក្ស សេ.អា.តូ ធ្វើរដ្ឋប្រហារសម្តេច សីហនុ ដល់ពេលនោះអង្គការបក្សកុម្មុយនិស្តប្រាកដជាគ្មានប្រសិទ្ធភាពក្នុងការចលនាដឹកនាំប្រជាជនឆ្ពោះទៅរករបបសង្គមនិយមនិងកុម្មុយនិស្តកម្ពុជាបានឡើយ ។ ហេតុនេះទើបអង្គការបក្សសម្រេចទូលសម្តេច សីហនុ ឲ្យដឹងខ្លួនជាមុន ។

មកដល់ថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ រដ្ឋប្រហារកើតឡើងម្តងទៀត គឺនៅពេលដែលសម្តេច សីហនុ យាងទៅព្យាបាលព្រះរោគនៅប្រទេសបារាំង ពេលនោះអង្គការបក្សបានឆក់យកឱកាសដើម្បីដឹកនាំចលនា ដោយចាត់តាំងឲ្យតំណាងម្នាក់ទៅទាក់ទងប្រទេសដែលជាប់សម្ព័ន្ធកុម្មុយនិស្ត"ចិន" ដើម្បីសុំឲ្យសម្តេច សីហនុ បានស្នាក់នៅធ្វើជានយោបាយទី២ ។ តំណាងមួយទៀតគឺនៅជាមួយសម្តេច សីហនុ ទាក់ទងសម្តេច សីហនុ ឲ្យទៅស្នាក់នៅប្រទេសចិនតាមគម្រោងការ ដើម្បីងាយស្រួលក្នុងការធ្វើនយោបាយកៀងគរមហាជន ព្រោះថានៅប្រទេសចិនមានវិទ្យុសម្រាប់ផ្សាយទាក់ទងប្រជាជន ។ ដ្បិតអីប្រជាជនកំពុងពេញនិយមសម្តេច សីហនុ ។ អង្គការបានរៀបចំឲ្យមានរដ្ឋាភិបាលក្រៅប្រទេសមួយតែងតាំងស្តេច សីហនុ ជាប្រធានរណសិរ្សនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដើម្បីឲ្យសម្តេច សីហនុ ស្រែកឃោសនាអំពាវនាវឲ្យបក្សពួករបស់ទ្រង់រួមកម្លាំងជាមួយអង្គការបក្សឲ្យទាន់ពេលវេលា ។ គ្រាន់តែឃោសនាភ្លាម មានគ្រូសាស្ត្រាចារ្យចំនួន៣០០០នាក់ ព្រមទាំងវីរជន បញ្ញវ័ន្ត សិស្ស និស្សិត និងប្រជាជនគ្រប់ប្រភេទបានចូលរួមជាមួយអង្គការរួមទាំងមិត្តទី៧"យៀកណាមខាងជើង"ជួយរួមអាវុធផង ។

ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៧០ សម្តេច សីហនុ មានការសង្ស័យដោយឃើញឈ្មោះគណៈរដ្ឋមន្ត្រីដែលទ្រង់ចាត់តាំងឡើងប៉ុន្មានសុទ្ធជាបញ្ញាជនដែលព្រះអង្គធ្លាប់កាត់ទោសប្រហារជីវិតតាំងពីឆ្នាំ១៩៦០ម្ល៉េះ ។ ចុងឆ្នាំ១៩៧០ កម្មាជីពមួយចំនួនដែលបានបញ្ជូនខ្លួនឲ្យទៅបំពេញវិជ្ជានៅឯហាណូយបានត្រឡប់មកប្រទេសវិញ ។ កម្លាំងទ័ពក៏មានច្រើនតែពុំទាន់មាំមួន ពេលនោះមិត្តទី៧ "យៀកណាម" ក៏ឆ្លៀតឱកាសលួចបបួលអ្នកស្រុកយកទ្រព្យសម្បត្តិចិញ្ចឹមពួកវានិងលួចកាប់សម្លាប់កម្មាភិបាលខ្មែរមួយចំនួន ។

ក្រោយមក អង្គការអនុវត្តផែនការតាមពាក្យស្លោកថា ដំណាក់កាលទី១ "វាយជនបទ" ដំណាក់ទី២ "ហ៊ុមព័ទ្ធទីក្រុង" ។ ការអនុវត្តតាមពាក្យស្លោកបានសម្រេចជោគជ័យ ។ មកដល់ឆ្នាំ១៩៧១ អង្គការបានសម្រេចឲ្យកម្មាភិបាលកងទ័ពទាំងអស់រំដោះខ្លួនចេញពីកងឯកភាពយៀកណាមឲ្យអស់ ដោយពឹងលើភាពឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន ។ ក្នុងរយៈកាលដ៏ខ្លីអង្គការខំប្រឹងអប់រំបង្រៀនពួករណសិរ្ស"រំដោះ"តាមលក្ខណៈនយោបាយនិងតាមឯកសារបន្តិចម្តងៗ ដើម្បីកុំឲ្យកងទ័ពទាំងនោះនៅនិយមសម្តេច សីហនុ ទៀត ។

ហ៊ូ យន់ បានបញ្ជាក់នៅក្នុងសុន្ទរកថាទៀតថា នៅក្នុងឆ្នាំ១៩៧១ សម្តេច សីហនុ បានដឹងខ្លួនមុន ទ្រង់បានបញ្ជាឲ្យ ហួត សម្បត្តិ ចេញពីអង្គការសហប្រជាជាតិដើម្បីរៀបកម្លាំងមួយថ្មីគឺកម្លាំងទី៣ "ទ័ពសីហនុ" នៅក្នុងខេត្តក្រចេះនិងស្ទឹងត្រែង ។ ពេលនោះអង្គការបានដឹងពីគម្រោងការរបស់ សីហនុ អង្គការបក្សក៏ចាត់ឲ្យ អៀង សារី ចេញដំណើរទៅក្រុងប៉េកាំងភ្លាមដើម្បីទប់ស្កាត់កុំឲ្យ ហួត សម្បត្តិ រៀបចំតាមផែនការរបស់សម្តេច សីហនុ មុនបាន ។ គម្រោងការនេះត្រូវបរាជ័យធ្វើឲ្យសម្តេច សីហនុ ខកបំណងយ៉ាងខ្លាំង ។ ក្រោយមកអង្គការបានសម្រេចរៀបចំឲ្យសម្តេច សីហនុ គិតតែពីសប្បាយនឹងស្រាស្រី ម្តងទៅជប់លៀងប្រទេសនេះ ម្តងទៅប្រទេសនោះ ដែលជាបក្សសម្ព័ន្ធដូចគ្នា ដើម្បីឲ្យសម្តេច សីហនុ ភ្លេចគិតអំពីរឿងទឹកដីនិងលើកទឹកចិត្តឲ្យមានកម្លាំងស្រែកតទៅទៀត ។

ចុងឆ្នាំ១៩៧១-៧២ កងទ័ពក៏មានកម្លាំងមាំមួន ហើយយល់ដឹងនូវជំហរនៃការតស៊ូរបស់ខ្លួនពិតប្រាកដ ពេលនោះអង្គការចាប់ផ្តើមធ្វើបុណ្យខួបដោយចំហនិងជាលើកដំបូងបំផុតដោយមានចែកពីប្រវត្តិតស៊ូ២១ឆ្នាំទៀតផង ។ សព្វថ្ងៃនេះអង្គការពុំមានការព្រួយបារម្ភទេ ដោយហេតុថាអង្គការផ្នែកភូមិភាគនិរតីមានកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា និងកម្មាភិបាលក្របខ័ណ្ឌដឹកនាំសំខាន់ៗ មានកងទ័ពនិងផ្ទៃដីធំជាងគេ មានប្រាក់ចំណាយដល់ទៅជាង៥លានរៀលសម្រាប់បុគ្គលិករដ្ឋបាលនិងយោធាខ្មែរក្រហមម្នាក់ៗ២៤០រៀលក្នុងមួយខែទៀតផង ។ ប៉ុន្តែអង្គការនៅមានការព្រួយបារម្ភថា ក្នុងភូមិភាគមួយចំនួនមានខ្វះកម្មាភិបាលយ៉ាងច្រើន (មុននឹងចេញទៅកាន់តំណែងណាមួយកម្មាភិបាលម្នាក់ៗត្រូវទទួលនូវការអប់រំហ្វឹកហ្វឺនរយៈពេលយូរ ហើយកម្មាភិបាលនោះត្រូវជ្រើសពីអ្នកធ្លាប់បម្រើជាយុវជនកុម្មុយនិស្ត ឬសមាគមនារីប្រជាធិបតេយ្យ) ។

រហូតមកដល់ថ្ងៃ៣០-៩-៧៤ ដំណើរការតស៊ូរបស់បក្សកុម្មុយនិស្តកម្ពុជាមានប្រវត្តិតស៊ូ២៣ឆ្នាំហើយ ។ ការតស៊ូក៏បានទទួលជោគជ័យទាំងក្នុងស្រុកទាំងនៅក្រៅស្រុក(លើឆាកអន្តរជាតិ) ហើយបានទទួលចំណាត់ថ្នាក់លេខ៣ ក្នុងពិភពលោក បន្ទាប់ពីប្រទេសចិនប្រជាមានិតនិងអាល់បានី ហើយក៏មានប្រទេសសម្ព័ន្ធមិត្តខ្លះបានមករៀនសូត្រទៀតផង ដូចជាបក្សកុម្មុយនិស្តចិននិងកូរ៉េជាដើម ។

ថ្វីដ្បិតតែដំណើរបក្សមានការរីកចំរើនបែបនេះក៏ដោយ ក៏បក្សនៅមិនទាន់ឆ្លងកាត់គ្រប់ទិន្នាការនៅឡើយ ។ ព្រោះថាប្រទេសកម្ពុជាស្ថិតនៅពាក់កណ្តាលសក្តិភូមិនិយម ពាក់កណ្តាលអាណានិគមនិយមនិងចក្រពត្តិនិយម ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកបរទេស ទាំងផ្នែកនយោបាយ យោធា សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ។

អំណឹះតទៅ កម្មាភិបាលកងទ័ពត្រូវរំដោះឲ្យបានទាំងស្រុង ប៉ុន្តែកុំភ្លេចថា មុននឹងឈានទៅវាយខ្មាំងខាងក្រៅ សូមវាយខ្មាំងក្នុងខ្លួនយើងម្នាក់ៗឲ្យអស់សិន ។ ចែកឲ្យដាច់ស្រឡះថាតើអ្នកណាជាមិត្ត អ្នកណាជាសត្រូវ និងប្រកាន់យកនូវគោលជំហរពលកម្ម នយោបាយ សាមគ្គី សតិអារម្មណ៍ ចាត់តាំង ។ កម្មាភិបាលនិងកងទ័ពទាំងអស់ត្រូវតែៈ

◆ ស្រឡាញ់ការងារពលកម្មជិតស្និទ្ធនឹងប្រជាជន ស្តាប់សំណូមពរ ដឹងទុក្ខធុរៈ ព្រមទាំងឆ្លៀតរៀនសូត្រពីប្រជាជនលើបច្ចេកទេសការងារ ព្រោះប្រជាជនជាប្រភពនៃចំណេះវិជ្ជាមិនចេះរីងស្ងួត ។
◆ បណ្តុះស្មារតីគោរពអង្គការវិន័យរបស់ក្រុម ។
◆ លត់ដំខ្លួនដើម្បីជំនួស "ធាតុដើម" មិនបដិវត្តន៍ មិនកម្មាជីព ។
◆ បណ្តុះស្មារតីសម្ភារនិយម ។
◆ ក្របខ័ណ្ឌទាំងអស់ត្រូវតែយល់ថា នយោបាយគឺជា"កម្លាំងទី១" ឯកម្លាំងយោធាគ្រាន់តែជាឧបករណ៍នៃកម្លាំងនយោបាយប៉ុណ្ណោះ ។
◆ កម្មាភិបាលត្រូវតែមានអាកប្បកិរិយាសីលធម៌ស្អាតស្អំ១៦យ៉ាងគឺ÷

១) ស្រឡាញ់ គោរពនិងបម្រើប្រជាជនរបស់បក្ស កម្មករ កសិករ ឲ្យអស់ពីចិត្តពីថ្លើម មិនប្រើអំណាចផ្តាច់ការលើប្រជាជនដោយចេញមុខឬផ្លូវសម្ងាត់ក្តី មិនគំរាមកំហែងប្រជាជន ត្រូវរាបសារទៅរកប្រជាជនជានិច្ច ព្រោះអង្គការបានដាក់ពាក្យស្លោកថា "ប្រជាជនជាត្រី អង្គការជាទឹក" ។

២) ស្មោះត្រង់ការងារមហាជន ផលប្រយោជន៍មហាជនដាច់ខាត មិនត្រូវប៉ះពាល់ដល់ទ្រព្យមហាជន សូម្បីតែម្ជុលមួយគ្រាប់អង្ករមួយកំប៉ុងក៏ដោយ ទោះតាមផ្លូវត្រជាក់ក្តី តាមផ្លូវក្តៅក្តី នឹងមិនស៊ីសំណូកសូកប៉ាន់ពីប្រជាជនដាច់ខាត ។

៣) បើមានអ្វីធ្វើខុសត្រូវសុំទោសប្រជាជន ។

៤) និយាយស្តីដេកដើរ ឈរអង្គុយ ស៊ីចុក លេងសើចដោយសុភាពរាបសាតាមប្រពៃណីប្រជាជន ។

៥) មិនប្រព្រឹត្តបទល្មើសលើស្ត្រីភេទ ។

៦) កុំដឹកស៊ីដែលមានលក្ខណៈពាលាអាវ៉ាសែមិនបដិវត្តន៍ ។

៧) កុំលេងល្បែងស៊ីសងឲ្យសោះ ។

៨) កុំប៉ះពាល់លុយកាក់ទ្រព្យសម្បត្តិប្រជាជននឹងអង្គការ ។

៩) ត្រូវធ្វើពលកម្មដូចប្រជាជន ។

១០) គោរពមតិរបស់អង្គការជានិច្ច ។

១១) ធ្វើការទិតៀនស្វ័យទិតៀនឲ្យបានល្អជានិច្ចក្នុងសាខាអង្គការមួយៗ ដោយស្មារតីស្មោះត្រង់ ឯកភាពផ្ទៃក្នុងឲ្យបានរឹងប៊ឹងជាលំដាប់ មិនវាយប្រហារគ្នាក្រៅអង្គការ ឬនិយាយចាក់ចុចដណ្តើមឥទ្ធិពលគ្នាទេ ។

១២) មានស្មារតីភ្ញាក់រឭកធ្វើបដិវត្តន៍ដោយខ្លួនឯង កាន់កាប់វាសនាប្រទេសដោយខ្លួនឯង មិនត្រូវពឹងបរទេសទេ ។

១៣) មានស្មារតីម្ចាស់ការចេះដោះស្រាយគ្រប់បញ្ហាដែលទាក់ទងដល់ជីវភាពខាងស្មារតីនឹងសម្ភាររបស់ប្រជាជន ។

១៤) កម្មាភិបាលគ្រប់រូបត្រូវជម្រុះឲ្យអស់នូវទស្សនៈសេរីនិយម អាជ្ញានិយម អាត្មានិយម ស្វ័យតួនិយម ស្វ័យឯកោនិយម អត្តនោម័តនិយម គ្រួសារនិយម បុគ្គលនិយម បក្សពួកនិយម ។

១៥) មានកំហឹងឆាបឆេះចំពោះខ្មាំងជានិច្ច ។

១៦) កម្មាភិបាលគ្រប់រូបម្នាក់ៗត្រូវជឿជាក់ថា ការតស៊ូរបស់យើងមានការបត់បែនលំបាកមែនពិត តែយើងពិតជាមានជ័យជម្នះ ។

មុននឹងបញ្ចប់សុន្ទរកថានេះ ហ៊ូ យន់ បានឲ្យកម្មាភិបាលនិងកងទ័ពទាំងអស់ត្រៀមខ្លួនប្រយុទ្ធការពារទាំងផ្នែកនយោបាយនិងយោធា នៅតាមផ្លូវជាតិលេខ៣"ភ្នំពេញ-កំពត" នាវផ្លូវទឹកស្រុកខាងមុខ ដើម្បីកុំឲ្យបក្សខ្លះឆ្លៀតឱកាសអំពាវនាវប្រជាជនឲ្យចូលធ្វើទាហានដើម្បីយកបុណ្យស័ក្តិ ឬក៏ទៅសុំបុណ្យស័ក្តិពីលន់ ណុល ថា មកទាក់ទងកងកម្លាំងប្រដាប់អាវុធ ប្រជាជនរំដោះជាតិកម្ពុជាបាន ។

**សុផល**

## ពន្យល់ពាក្យខ្មែរក្រហម

◆**នាយទុនកុំប្រាដរ:** គឺពួកនាយទុនធំៗដែលប្រមូលស្រូវ អង្ករ ពោត សណ្តែក ថ្នាំនិងផលិតផលឯទៀតៗនៅក្នុងស្រុក បញ្ជូនទៅលក់ក្រៅប្រទេសដែលវាមានខ្សែទាក់ទងជាមួយ ។

◆**នាយទុនជាតិ:** គឺជានាយទុនរកស៊ីក្នុងស្រុកខាងឧស្សាហកម្មក្តី ខាងពាណិជ្ជកម្មក្តី ខាងកសិកម្មក្តី ។ ប្រើប្រាស់វត្ថុធាតុដើម (មធ្យោបាយពលកម្មកម្មករ) របស់ជាតិខ្លួន ហើយផលិតផលក្នុងប្រទេស ឬលក់ផលិតផលបន្តិចបន្តួចទៅក្រៅប្រទេស ។

(យុវជន-យុវនារីបដិវត្តលេខពិសេសខែសីហា-កញ្ញា ១៩៧៤)

# និរសាឯកសារប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជានិរសានាំមុខខាងផ្សព្វផ្សាយព័ត៌មានប្រវត្តិសាស្ត្រនិងផ្នែកច្បាប់ទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យឬហៅថារបបខ្មែរក្រហមតាមរយៈទស្សនាវដ្តី "ស្វែងរកការពិត" ។ ទស្សនាវដ្តីស្វែងរកការពិតផ្ទុកនូវសំណេររបស់អ្នកសិក្សាជាន់ខ្ពស់កម្ពុជា និងអន្តរជាតិល្បីៗ ។ ទស្សនាវដ្តីស្វែងរកការពិតបានចាប់ផ្តើមចេញផ្សាយលេខទី១ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០០ ។ រហូតមកដល់សព្វថ្ងៃនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាចេញផ្សាយបាន២៤លេខហើយ សរុបទាំងអស់មានចំនួន១សែន៦ម៉ឺន៨ពាន់ច្បាប់ ។ ទស្សនាវដ្តីស្វែងរកការពិតគឺជាមធ្យោបាយមួយក្នុងការពង្រីកការយល់ដឹងអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម ។

ក្នុងចំណោមអំពើគួរឲ្យព្រឺព្រួចដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលភាគច្រើនជាអំពើឃោរឃៅហើយពុំសូវបានចងក្រងជាឯកសារសម្រាប់សិក្សាជ្រាវជ្រាវនិងផ្សព្វផ្សាយដល់សិស្សានុសិស្សនៅប្រទេសកម្ពុជានោះគឺបទពិសោធន៍របស់ជនរងគ្រោះនិងជនដៃដល់ ។ អំពើទាំងអស់នេះរួមមានការឃុំឃាំងនិងសម្លាប់ដោយគ្មានការជំនុំជម្រះក្តីត្រឹមត្រូវកង្វះចំណីអាហារ ថ្នាំសង្កូវ និងការព្រាត់ប្រាសគ្រួសារ ញាតិមិត្ត ។

ក្រោយឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាចាប់ផ្តើមកសាងប្រទេសរបស់ខ្លួនឡើងវិញលើគំនរផេះផង់ និងជាប្រទេសមួយគ្មានសល់អ្វីក្រៅតែសំបក ហើយអ្នកចេះដឹងភាគច្រើនត្រូវខ្មែរក្រហមសម្លាប់ស្ទើរគ្មានសល់ ។ រដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបញ្ចូលប្រធានបទស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ(ឆ្នាំ១៩៧៥ - ១៩៧៩) ទៅក្នុងកម្មវិធីសិក្សារបស់ជាតិ ។ ប៉ុន្តែព័ត៌មានដ៏ស្តួចស្តើងនេះមិនអាចបំពេញតម្រូវការរបស់សិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវ ជាពិសេសប្រជាជនដែលទទួលរងការឈឺចាប់ បានគ្រប់គ្រាន់ទេ ។ រហូតមកដល់សម័យរដ្ឋកម្ពុជាទៀតសោត ក៏នៅតែពុំមានសញ្ញាណណាមួយបញ្ជាក់ថា យុវវ័យខ្មែរជំនាន់ក្រោយទទួលបាននូវការអប់រំអំពីអតីតកាលរបស់ប្រទេសនិងជនរួមជាតិខ្លួនបានជាលម្អិតដែរ ។

រយៈពេលចុងក្រោយថ្មីៗនេះ មតិសាធារណៈមួយចំនួនបានរិះគន់ថាមិនមានប្រធានបទខ្មែរក្រហមនៅក្នុងកម្មវិធីសិក្សាជាតិ ។ ហេតុផលចម្បងនេះគឺប្រហែលបណ្តាលមកពីការជំពាក់ជាប់វិនផ្នែកនយោបាយ ជាជាងប្រវត្តិសាស្ត្រ ឬអាចនិយាយម្យ៉ាងទៀតថា ប្រជាជនកម្ពុជាដែលកើតមុនដើមទសវត្សរ៍ឆ្នាំ១៩៧០ សុទ្ធតែមានរឿងផ្ទាល់ខ្លួនសម្រាប់និយាយរួចទៅហើយ ។

សៀវភៅសិក្សាសង្គមដែលរួមមានប្រវត្តិវិទ្យានិងភូមិវិទ្យាថ្នាក់ទី៩ ទំព័រទី១៦៩ ដែលបោះពុម្ពផ្សាយដោយក្រសួងអប់រំយុវជននិងកីឡា ឆ្នាំ២០០០ មាននិយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យតែមួយកថាខណ្ឌតែប៉ុណ្ណោះ ។ តើធ្វើដូចម្តេចទើបសិស្សានុសិស្សកម្ពុជានិងយុវវ័យជំនាន់ក្រោយអាចនឹងយល់ច្បាស់អំពីសារជាតិនៃរបបដ៏ព្រៃផ្សៃនេះទៅ? កថាខណ្ឌមានដូចខាងក្រោមៈ *"របបកម្ពុជាប្រជាធិបតេយ្យៈ ពីថ្ងៃទី២៥ដល់២៧ ខែមេសា ឆ្នាំ១៩៧៥ ក្រុមខ្មែរក្រហមបានធ្វើមហាសន្និបាតវិសាមញ្ញដើម្បីរៀបចំរដ្ឋធម្មនុញ្ញថ្មីហើយបានដាក់ឈ្មោះប្រទេសថាកម្ពុជាប្រជាធិបតេយ្យ ។ រដ្ឋាភិបាលមួយរបស់កម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើងដោយមាន ប៉ុល ពត ជាអ្នកដឹកនាំរបបនោះ ។ ប្រជារាស្ត្រខ្មែរស្លូតត្រង់ទទួលការកាប់សម្លាប់យ៉ាងរន្ធាល"* ។

តាមរយៈការស្ទាបស្ទង់ធ្វើឡើងដោយទស្សនាវដ្តីស្វែងរកការពិតបញ្ជាក់ថា មានអ្នកអានទូទៅចំនួន៨៤ភាគរយនិយាយថាខ្លួនចូលចិត្តអានដោយសារទស្សនាវដ្តីស្វែងរកការពិតមានសារសំខាន់ ។ ទស្សនាវដ្តីស្វែងរកការពិតបានទទួលសំបុត្រជាច្រើនពីសំណាក់អ្នកអានស្ទើរគ្រប់មជ្ឈដ្ឋាន ។ មានអ្នកអានមួយចំនួនចង់ឲ្យមានការស្រាវជ្រាវនិងចេញផ្សាយថែមទៀតលើផ្នែកសិល្បៈខ្មែរក្រហម ដូចជាចម្រៀង កំណាព្យ ជាដើម ហើយសំណូមពរឲ្យបង្កើនការបោះពុម្ពផ្សាយកាន់តែច្រើនថែមទៀតជាប្រយោជន៍ដល់យុវវ័យខ្មែរជំនាន់ក្រោយសិក្សាស្វែងយល់អំពីសារជាតិនៃ

អំពើឃោរឃៅប្រព្រឹត្តឡើងដោយខ្មែរក្រហម ។

នៅឆ្នាំ២០០១ ទស្សនាវដ្តីស្វែងរកការពិត បង្កើនចំនួនបោះពុម្ពផ្សាយដល់៧០០០ក្បាល ក្នុងមួយលេខចាប់តាំងពីខែមេសា ។ ប៉ុន្តែយើងដឹងច្បាស់ថាចំនួននេះ ក៏មិនទាន់ឆ្លើយតបទៅនឹងសំណូមពររបស់ពុកម៉ែបងប្អូននៅតាមមូលដ្ឋាននិងសិស្សានុសិស្សនៅតាមសាលារៀនទេ ។ ជាក់ស្តែង ឃុំទាំងអស់ទូទាំងប្រទេសក្នុងមួយឃុំបានទទួលតែទស្សនាវដ្តីស្វែងរកការពិត៣ច្បាប់តែប៉ុណ្ណោះក្នុង១លេខ ។ ចំណែកស្រុកនិងខេត្ត បានទទួលពី៥ទៅ១០ច្បាប់ក្នុង១លេខ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាទើបតែចាប់ផ្តើមចែកផ្សាយទស្សនាវដ្តីទៅតាមវិទ្យាល័យនិងសាលាគរុកោសល្យនានាទូទាំងប្រទេសសម្រាប់លោកគ្រូ អ្នកគ្រូនិងសិស្សានុសិស្សដើម្បីសិក្សាស្វែងយល់ ។ មាតិកាទស្សនាវដ្តីស្វែងរកការពិត ផ្តោតសំខាន់ទៅលើថ្នាក់ដឹកនាំខ្មែរក្រហមដូចជា ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន, តាម៉ុក, អៀង ធីរិទ្ធិ, វន វ៉េត, ឌុច និងជនរងគ្រោះរបស់របបខ្មែរក្រហម ។ មិនតែប៉ុណ្ណោះទស្សនាវដ្តីក៏បានបោះពុម្ពផ្សាយពត៌មានប្រវត្តិសាស្ត្រទំនាក់ទំនងរវាងជនកម្មុយនិស្តខ្មែរក្រហមជាមួយជនកុម្មុយនិស្តវៀតណាមនិងការទាញយកផលប្រយោជន៍របស់មេដឹកនាំខ្មែរក្រហមដែលនៅមានជីវិតពីការឈឺចាប់របស់ជនរងគ្រោះកម្ពុជា ។ ទស្សនាវដ្តីស្វែងរកការពិតនៅបានផ្សព្វផ្សាយសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗទាក់ទងនឹងបរិបទកម្ពុជាសម័យបច្ចុប្បន្នដំណើរការបង្កើតតុលាការខ្មែរក្រហមនិងប្រធានបទទាក់ទងនឹងការផ្សះផ្សាជាតិជាចំណុចចម្បងរបស់ទស្សនាវដ្តីស្វែងរកការពិតដែរ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាចាត់ចែងការចែងចាយដោយខ្លួនឯងផង និងដោយមានកិច្ចសហការគាំទ្រពីសំណាក់បណ្តាអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដែលស្ម័គ្រចិត្តចូលរួមចែករំលែកការផ្សព្វផ្សាយពត៌មានប្រវត្តិសាស្ត្រនេះ ជាពិសេសអង្គការលីកាដូ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ដៃគូអភិវឌ្ឍន៍ អង្គការប៉ាដិកនិងអ្នកស្ម័គ្រចិត្តមួយចំនួនទៀត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាដាក់លក់ទស្សនាវដ្តីចំនួនប្រមាណ៥ភាគរយ នៅក្នុងក្រុងភ្នំពេញដើម្បីយក





កម្រែសម្រាប់ចំណាយទៅលើសោហ៊ុយចែកចាយតាមខេត្ត ស្រុក ឃុំនិងភូមិ ។ ស្ថាប័នសំខាន់ៗមួយចំនួននៅក្នុងរាជធានីភ្នំពេញបានទទួលទស្សនាវដ្តីស្វែងរកការពិតរាល់លេខ ។ ស្ថាប័នទាំងនោះរួមមានព្រះបរមរាជវាំង ព្រឹទ្ធសភា សភា គណបក្សនយោបាយ ក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី ស្ថានទូតនានាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល បណ្ណសារដ្ឋានជាតិ បណ្ណាល័យជាតិ និងបណ្ណាល័យតាមសាកលវិទ្យាល័យ បណ្ណាល័យសម្តេច ហ៊ុន សែន មហាវិទ្យាល័យនិងតាមវិទ្យាល័យខេត្ត-ក្រុង ។

ដើម្បីពង្រីកការយល់ដឹងជាលក្ខណៈអន្តរជាតិ នៅពាក់កណ្តាលឆ្នាំ២០០១ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិតជាភាសាអង់គ្លេសទាំង១២ចំនួន ៨៤០០ច្បាប់ ។ នៅក្នុងឆ្នាំ២០០២ មជ្ឈមណ្ឌលឯកសារកម្ពុជាមានផែនការបង្កើតការិយាល័យនៅតាមខេត្ត-ក្រុងមួយចំនួនដើម្បីធានាឲ្យប្រាកដថា ទស្សនាវដ្តីស្វែងរកការពិត ពិតជាបានដល់ដៃប្រជាជនតាមមូលដ្ឋាន និងប្រយោជន៍ដើម្បីសិក្សាស្រាវជ្រាវរកពត៌មានបន្ថែមទៀតទាក់ទងនឹងប្រវត្តិនិយាយដោយផ្ទាល់មាត់និងពត៌មានទាក់ទងនឹងវត្ថុតាងដែលនៅសេសសល់ ។

នៅថ្ងៃទី១៨ខែធ្នូ ឆ្នាំ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានចេញសារាចរណែនាំស្តីពីការថែរក្សា រៀបចំទុកដាក់អដ្ឋិធាតុប្រជាជនរងគ្រោះដោយអំពើប្រល័យពូជសាសន៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥ - ១៩៧៩) និងការរៀបចំតំបន់អនុស្សាវរីយ៍ឲ្យទៅជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ ។ ខ្លឹមសារនៃសារាចរនេះជំរុញឲ្យមន្ត្រីជំនាញនិងអាជ្ញាធរខេត្ត-ក្រុងនិងតាមមូលដ្ឋានយកចិត្តទុកដាក់សិក្សាស្រាវជ្រាវបន្ថែមទាំងលើពត៌មានរណ្តៅសាកសពរួមដែលមិនទាន់រកឃើញ និងការសង់ជាបូជនីយ៍ដ្ឋានសម្រាប់តម្កល់អដ្ឋិធាតុនិងវត្ថុតាងឲ្យបានគង់វង្សដើម្បីបម្រើឲ្យផលប្រយោជន៍ប្រវត្តិសាស្ត្រ ។

ការវិវឌ្ឍថ្មីៗនេះបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ទៅលើការថែរក្សានូវការចងចាំអំពើឃោរឃៅពីអតីតកាល ។ ថ្មីៗនេះមានការរៀបចំបោះពុម្ពផ្សាយនូវសៀវភៅសិក្សាថ្នាក់ទី១២ ក្នុងនោះមានជំពូកមួយសិក្សាអំពីខ្មែរក្រហម ។ សមាជិកម្នាក់នៅក្នុងគណៈកម្មាធិការនិពន្ធសៀវភៅអប់រំនៃក្រសួងអប់រំយុវជននិងកីឡា មានប្រសាសន៍ថាសៀវភៅនេះនឹងត្រូវបញ្ចប់នៅខែកក្កដា ឆ្នាំ២០០១ ព្រោះត្រូវការពិនិត្យឲ្យបានកាន់តែសុក្រឹត ។ លោក ស៊ូប៉ូ ប្រាសិទី អ្នកជំនាញការខាងកម្មវិធីសិក្សាអប់រំរបស់អង្គការយូនីស្កូ ក៏មានគំនិតប្រហាក់ប្រហែលនេះដែរ ។ ប៉ុន្តែលោកបញ្ជាក់ថា ភាគច្រើននៃអ្នកនិពន្ធនៅក្នុងគណៈកម្មាធិការនេះមានទំនោរទៅរករបៀបសរសេរបែបកុម្មុយនិស្តដែលខ្លួនទទួលឥទ្ធិពលពីអតីតសហភាពសូវៀត ។

ទោះជាយ៉ាងណាក៏ដោយ ក៏ទស្សនាវដ្តីស្វែងរកការពិតនៅតែដើរតួយ៉ាងសំខាន់ក្នុងការចងក្រង សិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយពត៌មានទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យក្នុងខណៈពេលដែលការជំពាក់ជំពិនផ្នែកនយោបាយមិនទាន់ត្រូវបានដោះស្រាយនិងតម្រូវការចង់យល់ចង់ដឹងចេះតែកើនឡើងពីសំណាក់ប្រជាជនកម្ពុជាក៏ដូចជាសិស្សានុសិស្សនិងអ្នកសិក្សាស្រាវជ្រាវដែលមានចំណាប់អារម្មណ៍ ។

ដើម្បីជួយព្យាបាលរបួសនិងផ្សះផ្សាសង្គមកម្ពុជាដែលនៅឆាយនឹងប្រេះស្រាំនោះ ចាំបាច់ត្រូវតែស្វែងរកការពិតស្តីពីរបបខ្មែរក្រហមនិងផ្សព្វផ្សាយការពិតជាលក្ខណៈប្រវត្តិសាស្ត្រនេះដល់ប្រជាជនកម្ពុជាដើម្បីឲ្យគាត់ជួយបង្រៀនកូនចៅជំនាន់ក្រោយឲ្យទប់ស្កាត់មិនឲ្យអំពើអសម្បជ្ជញ្ញៈនេះកើតមានសាជាថ្មីនៅលើទឹកដីកម្ពុជា ។ ដើម្បីបោះជំហានទៅមុខ កម្ពុជាត្រូវបង្កើតរូបភាពប្រវត្តិសាស្ត្រអតីតកាលមួយច្បាស់លាស់ដើម្បីជាបង្គោលគ្រឹះសម្រាប់កសាងប្រទេសនៅពេលអនាគត ។ **ស្ងួ ប៊ុនស៊ុ**

សូមសរសេរលិខិត

ប្អ អត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមផ្ញើមក

**ទស្សនាវដ្តី«ស្វែងរកការពិត»**

ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ប្អ តាមទូរសារលេខៈ (៨៥៥)(២៣)២១០៣៥៨

ប្អ Email: dccam@bigpond.com.kh

# ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍

## ការធ្វើផែនទីវាលពិឃាតនៃប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥-២០០០

(តពីលេខមុន)

| លរ | លរទីតាំង | ឈ្មោះទីតាំង | ទិន្នន័យរណ្ដៅនិងជនរងគ្រោះ តាមជាក់ស្ដែង | | ទិន្នន័យរណ្ដៅនិងជនរងគ្រោះ តាមរបាយការណ៍ | | របាយការណ៍ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|
| | | | ចំនួនស្នានរណ្ដៅ | ចំនួនស្នានជនរងគ្រោះ | ចំនួនស្នានរណ្ដៅ | ចំនួនស្នានជនរងគ្រោះ | |
| ២៥១ | ២០០៤០៤ | ទួលអាគ្រៀម | ៨០ | ២០០០ | ប្រហែល៨០ | ១៥០០-២០០០ | ១៩៩៧ |
| ២៥២ | ២០០៤០៥ | ស្វាយទន្ទឹម | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៥៣ | ២០០៤០៦ | វត្តស្វាយទន្ទឹម | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៥៤ | ២០០៦០១ | ភូមិចុងព្រែក | ១ | ៤០ | ១ | ៤០ | ១៩៩៧ |
| ២៥៥ | ២០០៦០៣ | ភូមិឫស្សី | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៥៦ | ២០០៦០៤ | ឫស្សី | ៨៧ | ៤១៣៦ | គ្មាន | គ្មាន | ១៩៩៧ |
| ២៥៧ | ២០០៦០៥ | ទួលកំពង់ចក | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៥៨ | ២០០៦០៦ | ទួលកំពង់ចក | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៥៩ | ២០០៦០៧ | ទួលត្រពាំងត្នោត | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៦០ | ២០០៧០១ | វត្តស្រះក្រាំងបន្ទាយ | ៧០-៨០ | ៨០០ | ១៣០ | ៣៧៧៥ | ១៩៩៧ |
| ២៦១ | ២០០៧០២ | វត្តស្រះក្រាំងបន្ទាយ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៦២ | ២០០៧០៣ | វត្តស្រះក្រាំងបន្ទាយ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៦៣ | ២០០៧០៤ | ពេជ្រឥន្ទ្រា | ៤០-៥០ | ៩០០ | គ្មាន | គ្មាន | ១៩៩៧ |
| ២៦៤ | ២១០៩០២ | ក្រាំងតាចាន់ | ១១ | គ្មាន | ៦០-៧០ | គ្មាន | ១៩៩៧ |
| ២៦៥ | ០១០៣០១ | មន្ទីរសន្តិសុខតំបន់ | ១ | រាប់រយ | គ្មាន | គ្មាន | ១៩៩៨ |
| ២៦៦ | ០១០៣០២ | ល្អាងត្រពាំងថ្ម | ២-៣ | រាប់ពាន់ | ស្រះ | រាប់ពាន់ | ១៩៩៨ |
| ២៦៧ | ០១០៣០៣ | ព្រៃគោកគ្រាច | គ្មាន | រាប់រយ | គ្មាន | រាប់រយ | ១៩៩៨ |
| ២៦៨ | ០១០៣០៤ | វត្តកណ្ដាល | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ២៦៩ | ០២០២០១ | មេច្បារ | គ្មាន | រាប់រយ | គ្មាន | ប្រហែល៣០០ | ១៩៩៨ |
| ២៧០ | ០២០២០២ | វាលបត់កង | គ្មាន | ៥០០ | គ្មាន | ៣៥០-៥០០ | ១៩៩៨ |
| ២៧១ | ០២០២០៣ | ទួលរូងជ្រៃ | ១ | ៤០០ | គ្មាន | រាប់ពាន់ | ១៩៩៨ |
| ២៧២ | ០២០៤០១ | ចំការក្រូច | ៣០ | ៣៥០ | ១០-៣០ | ៣០០-៤០០ | ១៩៩៨ |
| ២៧៣ | ០២០៧០១ | បន្ទាយអូតាគ្រែ | ៣៥ | ៤០០០ | ៣៥ | ១៥០០-១៥៥០ | ១៩៩៨ |
| ២៧៤ | ០២០៧០២ | ផ្លូវបំបែកភូមិជារ | គ្មាន | ១៥០-២០០ | គ្មាន | គ្មាន | ១៩៩៨ |
| ២៧៥ | ០២០៧០៣ | ភូមិជីប៉ាំ | គ្មាន | ២០០-២៥០ | គ្មាន | ១៥០-២៥០ | ១៩៩៨ |
| ២៧៦ | ០២០៧០៤ | ភូមិវត្ត | គ្មាន | ១៥០ | គ្មាន | ១៥០-២៥០ | ១៩៩៨ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២៧៧ | ០២០៧០៥ | បន្ទាយត្រែង | គ្មាន | ៨០០-១០០០ | គ្មាន | ៨០០-១០០០ | ១៩៩៨ |
| ២៧៨ | ០២០៨០១ | វត្តពោធិ៍លង្កា | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ២៧៩ | ០២០៨០២ | កាច់រទេះ | ១-១៥០ | ២៥០-៥០០ | ១០០-២០០ | ១២០០-២០០ | ១៩៩៨ |
| ២៨០ | ០២០៨០៣ | វត្តសម្តេចមុនី | ៦ | ៥០០០-៦០០០ | ៦ | ៣៥-១០០ | ១៩៩៨ |
| ២៨១ | ០២០៨០៤ | ភូមិដំនឹក | ៥-៦ | ៣០-៣៥ | ៦ | ៣៥-១០០ | ១៩៩៨ |
| ២៨២ | ០២០៨០៥ | ភូមិដំនឹក | គ្មាន | ៥០-៦០ | ៨-១០ | ៥០-៦០ | ១៩៩៨ |
| ២៨៣ | ០៣០១០១ | គុកសន្តិសុខបាធាយ | ៤-៥០០ | ៨០០០-១០០០០ | ៤-៥០០ | ៨០០០-១០០០០ | ១៩៩៨ |
| ២៨៤ | ០៣០១០២ | ចំការដើមខ្នុរ | ១៥០-២០០ | ៣០០០-៧០០០ | ១០០-១៥០ | ៣០០០-៧០០០ | ១៩៩៨ |
| ២៨៥ | ០៣០១០៣ | ស្វាយជ្រុំ | គ្មាន | ៥០០-៦០០ | គ្មាន | ៥០០-៦០០ | ១៩៩៨ |
| ២៨៦ | ០៣០១០៤ | ទួលខ្មោចចោម | ១០០-២០០ | ៧០០-៨០០ | ១០០-២០០ | ៧០០-៨០០ | ១៩៩៨ |
| ២៨៧ | ០៣០២០២ | គុកមិត្តសៅ | ២០-៣០ | ៥០០-៦០០ | គ្មាន | គ្មាន | ១៩៩៨ |
| ២៨៨ | ០៣០២០២ | គុកមិត្តសៅ | ៧០០-១០០០ | ៨០០០-១០០០០ | ៥០០-៧០០ | ជាង១០០០០ | ១៩៩៨ |
| ២៨៩ | ០៣០២០៣ | វត្តពព្រេង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ២៩០ | ០៣០២០៤ | ព្រៃត្រពាំងគុកសំ | ៨ | ៨០០-១០០០ | ៨ | ៤០០-៨០០ | ១៩៩៨ |
| ២៩១ | ០៣០២០៥ | ចំការតាប៉ុម | ៥៤ | ៣០០០-១០០០០ | ៨ | ៤០០-៨០០ | ១៩៩៨ |
| ២៩២ | ០៣០២០៦ | ចំការតាប៉ុម | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ២៩៣ | ០៣០៤០១ | ខ្នុរចាស់ | ៦ | ១២០០ | គ្មាន | គ្មាន | ១៩៩៨ |
| ២៩៤ | ០៣០៤០២ | ខ្នុរចាស់ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ២៩៥ | ០៣០៨០១ | វត្តដំនឹក | ៤០ | ៣០០-៨០០ | ស្រះ២និងរណ្តៅ | ៣០០-៨០០ | ១៩៩៨ |
| ២៩៦ | ០៣០៨០២ | អ្នកតាចិន | ១០ | ១០០០-១៥០០ | គ្មាន | ៧០០-១៥០០ | ១៩៩៨ |
| ២៩៧ | ០៣០៨០៣ | វត្តដីហែ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ២៩៨ | ០៣១១០១ | ព្រៃធូដុង | ៦ | ២១៤ | គ្មាន | គ្មាន | ១៩៩៨ |
| ២៩៩ | ០៣១១០២ | ត្រពាំងសង្កែ | ៨ | ៣១៩-៥០០ | ៨ | ៣១៩-៥០០ | ១៩៩៨ |
| ៣០០ | ០៣១១០៣ | មាត់បឹងកាពិ | ៦០-៦១ | ២៣៥ | ៦១-៦២ | ២៣៥-៣០០ | ១៩៩៨ |
| ៣០១ | ០៣១៣០១ | គុកវត្តតាមាគ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣០២ | ០៣១៣០២ | ទួលត្រពាំងល្ហា | ៥០-១០០ | ៣០០-៥០០ | ៥០-១០០ | ១៧០-៥០០ | ១៩៩៨ |
| ៣០៣ | ០៣១៤០១ | វត្តជ័យមង្គល | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៨ |
| ៣០៤ | ០៣១៤០២ | វត្តជ័យមង្គល | ៧ | ២០០០ | គ្មាន | គ្មាន | ១៩៩៨ |

**(នៅមានត)**

តួលេខដែលចុះផ្សាយក្នុងលេខនេះសម្រាប់ ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តកំពង់ចាម ។

◆ ចំពោះព័ត៌មានមានដែលដាក់ថា“គ្មាន” មានន័យថាពុំមានសាក្សីឬតួលេខ ប៉ុន្តែវត្តមានទីតាំងបានមកពីប្រភពផ្សេងៗ ។

◆ ចំពោះព័ត៌មានដាក់ស្តែងនិងព័ត៌មានតាមរបាយការណ៍មានន័យខុសគ្នាត្រង់ថា ព័ត៌មានដាក់ស្តែងគឺបានមកពីសាក្សីដែលបញ្ជាក់ប្រាប់នៅទីតាំងកើតហេតុ ។ ព័ត៌មានតាមរបាយការណ៍មានន័យថា សាក្សីផ្សេងទៀតដែលប្រាប់តួលេខអំពីទីតាំងដដែល ។

# គោលនយោបាយប្រឆាំងខ្មែរក្រហម

(ឯកសារលេខ D១៤៣៣៣)

## I. *ក្រៅប្រទេស*

ពីក្រៅចូលក្នុងៈ មុនចាញ់

១) ទាក់ទងជាមួយប្រទេសនានាដែលជាបក្សសម្ព័ន្ធជប៉ុន-ឥណ្ឌូនេស៊ី ឲ្យជួយប្រកាសចរចាបញ្ឈប់សង្គ្រាមបង្ហូរឈាមរបស់កុម្មុយនិស្ត ពិសេសនៅក្នុងអង្គការសហប្រជាជាតិកាលពីប្រជុំឆ្នាំ១៩៧៣និង១៩៧៤ មានតែប្រទេសពីរនេះទេដែលគាំទ្រខ្មែរយើងខ្លាំងជាងគេ ។

២) ទាក់ទងប្រទេសសៀមឥណ្ឌូនេស៊ីនៅអាស៊ីដែលសង្ឃឹមថាមុខជាភ្ជាប់ចំណងទូតជាមួយនឹងកម្ពុជានៅថ្ងៃក្រោយ ហើយពុំថាឡើយប្រទេសតែពីរនេះទេ គឺប្រទេសណាក៏ដោយឲ្យតែអាចធ្វើទៅបាន ដើម្បីជួយផ្តល់ជាពត៌មាននិងធ្វើការនៅក្នុងប្រទេសកម្ពុជានៅពេលដែលភ្ជាប់ចំណងទូត ។

៣) ធ្វើអន្តរាគមន៍ជាមួយចិននិងយួនដែលមានឥទ្ធិពលលើខ្មែរក្រហមជំរុញឲ្យចរចាជាមួយរបបសាធារណរដ្ឋ ។

៤) បញ្ជូនតំណាងសភាអាមេរិកកាំងមកប្រទេសខ្មែរដើម្បីមើលនិងពិនិត្យសង្គ្រាមជាក់ស្តែង ហើយទៅផ្សាយអំពីសង្គ្រាមជូនសភាដើម្បីសុំជំនួយបន្ថែមដល់ខ្មែរ ។

៥) ប្រកាសក្នុងពត៌មាននានាក្នុងប្រទេសនិងសារពត៌មានខ្លះទៀតនៅប្រទេសសៀម ជប៉ុន អូស្ត្រាលី ហ្វីលីពីន ចិនតៃវ៉ាន់ អំពីសង្គ្រាមជ្រៀតជ្រែករបស់បក្សកុម្មុយនិស្តឥណ្ឌូចិន ។

៦) បង្កើតអង្គការមនុស្សធម៌ជាច្រើនដើម្បីជួយជនភៀសខ្លួនដូចនៅ *R.D.F* ទស្សនៈពិភពលោក *C.R.S CARE* និងកាកបាទក្រហមអន្តរជាតិ ហើយទាំងអស់គ្រប់គ្រងដោយស្ថានទូតអាមេរិកាំង ។

៧) ពេលចុងក្រោយផ្លាស់ប្តូរគោលនយោបាយនិងអ្នកដឹកនាំធំ ដូច លន់ ណុល, សុសស្តែន ដើម្បីលុបលាងនូវកំហុសដែលបានប្រព្រឹត្តពីដើមមក ។

◆ធ្វើការឲ្យតែរួចខ្លួន មិនយកចិត្តទុកដាក់ មិនសូវរវល់នឹងកិច្ចការក្រៅរោងចក្រ ។

◆ ប្រើប្រាស់ប្រដាប់ប្រដាមិនសន្សំសំចៃ ហើយចោលពាសពេញទីកន្លែង ។

◆ នៅតាមរោងចក្រខ្លះមិនគិតថែទាំវត្ថុធាតុដើម បណ្តាលឲ្យខូចប្រើការមិនកើតគុណភាពខិនថយ ។

◆ បំផុសនារីតាមរោងចក្រតម្បាញពេលបង្រៀនចេះគេឲ្យទៅក្រោយ ។

បើនិយាយសរុបទៅគឺនៅតាមរោងចក្រដែនការមិនខុសគ្នាទេ គ្រាន់តែម៉ាស៊ីន វត្ថុធាតុដើម របៀបធ្វើការខុសប្លែកពីគ្នាខ្លះៗ តែដែនការគឺបន្ថាក់ដំណើររោងចក្រធ្វើឲ្យប្របូកប្របល់បំផ្លាញធ្វើឲ្យអង្គការពិបាកដោះស្រាយបញ្ហាស្មុគស្មាញទាំងឡាយតាមរោងចក្រ ។

◆ ចាំជួយផ្ទៃក្នុងធ្វើឲ្យចលាចលប្របូកប្របល់ក្នុងរោងចក្រនៅពេលណាមានកម្លាំងវាយប្រហារពីក្រៅមកជិតដល់ ។

◆ពួករដ្ឋការស៊ីវិល មជ្ឈដ្ឋានសិក្សា យោធា និងស៊ីវិលខ្លះទៀត ដែលចូលតាមមូលដ្ឋាន ក៏មានលទ្ធភាពបំផុសបំផុលប្រជាជនដែរ តាមលទ្ធភាពរបស់ខ្លួននិងកសាងកម្លាំងថ្មីៗទៀត ។

◆ ដែនការធំទី១ រំលំរបបបដិវត្តក្នុង៧ខែក្រោយរំដោះក្រុងនោះ ត្រូវគ្មានសកម្មភាពដោយប្រជាជនជម្លៀសចេញអស់ពីទីក្រុង កម្លាំងក៏ត្រូវរលាយ ការទាក់ទងគ្នាក៏ត្រូវដាច់ ។

◆តាមខេត្តក៏មិនខុសគ្នាពីទីក្រុងដែរ ដោយប្រជាជនជម្លៀសចេញទៅតាមជនបទនានា ។

◆នៅជាយដែនសៀមដែលបន្តប់ទំពនិងក្រុមសេ.អ៊ី.អាមានដែនការវាយប្រហារនៅខែ១-៧៦ និងនៅខែ៤-៥-៧៦ទៀត ហើយចាប់ផ្តើមនៅតាមខេត្តដែលនៅជាប់នឹងសៀមតែម្តង ដូចនៅប៉ៃលិន បាត់ដំបង ព្រះវិហារជាដើម ហើយអាចមានការជួយគាំទ្រពីកងម៉ារីនផង ។

◆ អាវុធយុទ្ធភ័ណ្ឌនិងស្បៀងទាំងអស់ត្រូវទទួលពីសេ.អ៊ី.អា

តាមប្រទេសសៀម គឺដឹកជញ្ជូនតាមទល់ដែនសៀមពីមូលដ្ឋានធំរបស់អាមេរិកនៅក្នុងប្រទេសសៀម(អ៊ុយតាប៉ាវ) ។

◆ ចំណែកសេ.អ៊ី.អា ដែលធ្វើនៅតាមជាយដែនមានបានទៅហ៊ឹកហ៊ឺននៅឥណ្ឌូនេស៊ីផង ចំពោះអ្នកឯទៀតដែលទៅហ៊ឹកហ៊ឺននៅប្រទេសនានាទៀត ខ្ញុំពុំបានដឹងថាត្រឡប់មកវិញឬយ៉ាងណាដែរ តែផែនការមុនពេលចាញ់មានគម្រោងថានឹងយកកម្លាំងទាំងអស់មកធ្វើការក្រោយពេលចាញ់កម្លាំងនៅអាមេរិក អូស្ត្រាលី សៀម នូវែលហ្សេឡង់ ឥណ្ឌូនេស៊ី ហ្វីលីពីន ។

◆ ជាទិសត្រូវអនុវត្ត គឺវាយប្រហារយកប្រទេសកម្ពុជាពីបដិវត្តន៍វិញក្រោយពេលប្រទេសធ្លាក់ក្នុងដៃខ្មែរក្រហម ។

សេចក្ដីរាយការណ៍ពីសកម្មភាពក្រោយចាញ់ដែលខ្ញុំសរសេរដូចនេះ គឺការដឹងរបស់ខ្ញុំផ្ទាល់អំពីផែនការរបស់សេ.អ៊ី.អាក្រោយពីពេលចាញ់មក ខ្ញុំពុំដែលដឹងអ្វីក្រៅពីផែនការក្នុងរោងចក្រឡើយ ។

ចំពោះសមាជិកដែលបានទៅរៀននៅប្រទេសក្រៅបម្រុងខ្លួនចូលធ្វើសកម្មភាពក្រោយពេលចាញ់នោះ មានគ្រប់ផ្នែកទាំងអស់ តែភាគច្រើនជាទាហាន ដូចជានៅសៀមភាគច្រើនណាស់ ជានាយទាហាននិងទាហានជើងគោកគ្រប់ផ្នែក មានទាហានខ្លះនៅរៀនតាមមូលដ្ឋានធំរបស់អាមេរិកផ្ទាល់នៅសៀមខាងអាកាស ។ នៅអាមេរិកខាងកងរថក្រោះច្រើននៅរដ្ឋតិចសាស (*Texas*) គឺច្រើនទាហានស័ក្តិ១ដែលមានសញ្ញាបត្រ (*BacII*) ឬក៏មានសញ្ញាបត្រ (*BST*) និងខាងអាកាសក៏បញ្ជូនទៅអាមេរិក ហើយខ្លះខាងអាកាសទៅហ៊ឹកហ៊ឺន ទៅអូស្ត្រាលី ខ្ញុំផ្ទាល់បានជួបនៅអូស្ត្រាលីក្នុងឆ្នាំ១៩៧៣ ។

នៅប្រទេសឥណ្ឌូណេស៊ីច្រើនទាហានស៊ើបការណ៍(សេ.អ៊ី.អា) នៅហ្វីលីពីនច្រើនជាជាងម៉ាស៊ីននិងសំណង់ នៅនូវែលហ្សេឡង់ វិជ្ជាទូទៅភាសាក៏មាន ចំពោះឯវិធីវាយប្រហារច្រើននៅយួន (ឡាំសឹង ឡុងហាយ) និងនៅសៀមតាមមូលដ្ឋានអាមេរិកកាំងខ្លះ និងតាមមូលដ្ឋាននិងសាលាធម៌របស់សៀមមួយក្រៅពីប្រទេសសៀមនិងយួន ទាហានដែលបញ្ជូនទៅរៀនមានបណ្ដាស័ក្តិពីស័ក្តិ១ឡើងទៅ ។ នេះបើតាមខ្ញុំដឹងហើយជួបផ្ទាល់ ។

## II. *នៅក្នុងប្រទេសៈ*

ផែនការៈ

◆ ជាននយោបាយនៅប្រកាសថាផ្ដល់ជំនួយបន្ថែមដល់ខ្មែរទៀត ហើយគាំទ្រនយោបាយខ្មែរជានិច្ច ។

◆ បង្កើនជំនួយជាច្រើនតាមអង្គការមនុស្សធម៌នានាដល់ជនភៀសខ្លួនទាំងឡាយនៅក្នុងក្រុងនិងតាមខេត្ត ។

◆ សន្ទាទាក់ទងជាមួយប្រទេសមហាអំណាចផ្នែកខាងកើតដើម្បីចរចារកសន្តិភាពដល់ខ្មែរដែលមានសមាជិកសភា *Mans Field* ទៅដល់ប្រទេសចិនផង ។

◆ ផ្លាស់ប្ដូរនាយទាហានខាងផ្នែកយោធានៅតាមខេត្តឧទាហរណ៍ បាត់ដំបង កំពង់ចាម និងកំពត និងនៅទីក្រុងភ្នំពេញខាងផ្នែករដ្ឋការស៊ីវិលមិនសូវមានការប្រែប្រួលក្រៅពីឲ្យលោកប្រធានាធិបតីទៅមើលខ្លួននៅសហរដ្ឋ និងអគ្គមេបញ្ជាការទៅបរទេស(ប្រទេសបារាំង) ។

◆ កិច្ចការទូទៅនៅក្នុងរដ្ឋាភិបាលត្រូវអនុវត្តទៅដោយការលាលែងពីមុខតំណែងរដ្ឋមន្ត្រីទី១ ឡុង បូរ៉េត និងរដ្ឋមន្ត្រី ហើយដែលមានគំរោងមកពីស្ថានទូតពីអាមេរិកាំងមាន *Mr. Dean* នូវនយោបាយក្នុងប្រទេសក៏ដូចក្រៅប្រទេស ។

◆ នៅតាមជ្ឈដ្ឋានសិក្សានៅតែមានការរំជើបរំជួលរវាងសិស្ស គ្រូ ជាមួយរដ្ឋាភិបាល ការសិក្សាពុំបានប្រព្រឹត្តទៅបានធម្មតាឡើយ ។

◆ ការទិញចូលរបស់របសម្រាប់ប្រទេស គឺនៅក្រោមការត្រួតពិនិត្យរបស់អាមេរិកាំង ដោយមានចែងកូតាសម្រាប់ទិញដែលទាក់ទងនឹងជំនួយសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក ។

◆ ប្រាក់រៀលចេះតែចុះ ក៏ប៉ុន្តែការគ្រប់គ្រងរបស់ប្រទេសដែលគាំទ្រស្ថិរភាពលុយរៀលចេះតែគាំទ្រដែលមានអាមេរិកជាមេ ។

◆ សាំងតែលក់ថោកពេកវាឈប់យកឲ្យ ។ ជាននយោបាយក្នុងប្រទេសមុនចាញ់នេះ គឺសឹងតែស្ថិតនៅក្រោម ការដឹកនាំនិងត្រួតពិនិត្យរបស់អាមេរិក ។

◆ ចង់ឲ្យមានប័ណ្ណសម្រាប់សម្គាល់ខ្លួនដែលប្រើដោយម៉ាស៊ីន *IBM* សម្រាប់ទាហានទាំងអស់នៅពេលបើកបៀវត្សរ៍

កុំឲ្យមានការប្រឆាំពីនាយទាហាន ។

◆ បន្ថែមកម្រៃដល់ទាហានដែលចេញច្បាំង ។

◆ បង្កើតជំរំសម្រាប់ប្រពន្ធទាហានមេម៉ាយដោយសង្គ្រោម ។ រវាងប្រជាជននិងមន្ទីរ ប្រធានភូមិឬក៏សង្កាត់មិនបានស្របគ្នា ១០០ភាគរយឡើយ សកម្មភាពធំបំផុតគឺការប្រុងវាយប្រហារតាមទល់ដែនក្នុងខែ១-២/៧៦ និងខែ៤-៥/៧៦នេះ របស់ទ័ព សេ.អ៊ី.អា ។

មានសេ.អ៊ី.អា ជម្លៀសចេញទៅនៅមូលដ្ឋាននោះ ។ ជាងនេះទៅទៀតដែលសុទ្ធសឹងទៅដោយកម្មករចាស់ៗភាគច្រើន ហើយដែលមានការមិនពេញចិត្តនឹងអង្គការបដិវត្តន៍ផងនោះ ការកសាងកម្លាំងថ្មីបង្កប់ក្នុងរោងចក្រក៏មានជាន្តបន្ទាប់មក កម្មករច្រើនជាងគេដែលជាបុរស បើតាមខ្ញុំដឹងគឺថានៅអគ្គិសនីកម្ពុជា ។

**អាវុធ:** នៅក្រោយពេលចាញ់នេះ អាវុធនៅក្នុងរោងចក្រខ្ញុំផ្ទាល់គឺឥតមានទេ ចំណែកឯរោងចក្រក្រៅដែលខ្ញុំមានការទាក់ទងក៏ពុំបានដឹងពីអាវុធនេះដែរ ចំពោះកម្លាំងទ័ពនៅតាមទល់ដែនច្បាស់ជាទទួលបានអាវុធពីអាមេរិកតាមរយៈសៀមមិនខាន ។



សិល្បៈខ្មែរក្រហម

**ពង្រីកកម្លាំង:** តាមរោងចក្រក៏ដូចគ្នានៅតាមមជ្ឈដ្ឋាន ការកសាងកម្លាំងថ្មីបានប្រព្រឹត្តតាមកន្លែងដែលសេ.អ៊ី.អារស់នៅ ដូចជារូបខ្ញុំកសាងបាន៨នាក់នៅរោងចក្រខ្ញុំផ្ទាល់ និងម្នាក់ទៀតដែលជាកម្មករក្រោមការណែនាំរបស់ខ្ញុំចាស់ពីរោងចក្រទឹកដោះគោ បានម្នាក់ទៀតដែលបច្ចុប្បន្នធ្វើនៅរោងចក្រមី ចំពោះការតាមដានក៏មិនខុសគ្នាដែរ ។

**បង្កប់កម្លាំងមនុស្ស:** នៅពេលក្រោយចាញ់នេះ ការបង្កប់កម្លាំងមនុស្សតាមរោងចក្រនានាគឺមាននៅក្នុងទីក្រុង រីឯជនបទក៏មានកម្លាំងដែរ នៅតាមមូលដ្ឋានទោះនៅជិតក្តី ឆ្ងាយក្តី ដែល

**ក្នុងវិស័យផ្សេងៗ:** នៅពេលក្រោយពីចាញ់នេះ នាយទាហានដែលបានទៅហ្វឹកហ្វឺននៅប្រទេសឥណ្ឌូនេស៊ីជាសេ.អ៊ី.អា បានចូលតាមជាយដែនសៀមមកក្នុងប្រទេស ហើយមានចលនាចេញចូលចំពោះដំណឹងរឿងនាយទាហានសេ.អ៊ី.អានេះ ខ្ញុំបានដឹងកាលពីពេលមុនរំដោះម្ល៉េះ ហើយពួកនេះហើយដែលបង្ហាត់បង្រៀនត្រៀមខ្លួនចាំធ្វើក្រោយពេលចាញ់ នៅក្នុងក្រុងក្រោយពីអង្គការប្រមូលកម្មករចូលក្នុងរោងចក្រវិញមកព្រឹត្តិការណ៍ក្នុង

រោងចក្រក៏ចាប់កម្រើកឡើងតាំងពីខែ៧-៧៥ រហូតមក ហើយគោលដៅធំគឺនៅខែ១២-៧៥ ។

**មុនចាញ់:** ការយល់ថា ចាញ់សង្គ្រាមតាំងពីចុងឆ្នាំ១៩៧៣ ក្រោយពេលបញ្ឈប់ការទម្លាក់គ្រាប់បែករបស់អាមេរិកនៅកម្ពុជា ផែនការគ្រប់ទីកន្លែងមុនចាញ់នេះក៏ចាប់ផ្តើមអនុវត្ត ។

**ក្រោយចាញ់:** បង្កើនកម្លាំងក្រុង ខេត្ត ជនបទ។ ក្រុងមានកម្លាំងយោធា រដ្ឋការស៊ីវិល មជ្ឈដ្ឋានសិក្សា និងស៊ីវិល ។ កម្លាំងយោធាមានទាហាន អាវុធហត្ថ ប៉ូលិស និងគិញ ។ ខេត្តក៏ដូចគ្នាដែរ តែភាគច្រើនជាទាហាន ព្រោះចៅហ្វាយខេត្តនានាជានាយទាហាន ហើយខេត្តដែលសំខាន់គឺបាត់ដំបង ប៉ៃលិន កោះកុង កំពង់សោម ព្រះវិហារ ពិសេសខេត្តតាមព្រំដែនសៀម ។ តាមជនបទកម្លាំងក៏ខំកសាងបង្កើន ហើយបង្កប់ជាមួយប្រជាជនក្នុងចំណោមគ្រូបង្រៀននិងរដ្ឋការតូចៗក្នុងតំបន់ ។

◆ គ្រប់មជ្ឈដ្ឋានទាំងអស់ក្នុងឆ្នាំ១៩៧៣ បានពង្រីកកម្លាំងច្រើន បើប្រៀបធៀបទៅឆ្នាំនានា និងពង្រីកជាហូរហែបន្តបន្ទាប់មកទៀត ពិសេសខាងទាហានដែលពឹងផ្អែកជាងគេសម្រាប់អនុវត្តផែនការ ។

◆ នាយទាហាននិងទាហានរបស់សេ.អ៊ី.អា បញ្ជូនចេញក្រៅប្រទេសដើម្បីហ្វឹកហ្វឺន និងទុកសម្រាប់អនុវត្តគម្រោងសេ.អ៊ី.អាក្រោយចាញ់ ។

◆ ផ្នែកស៊ីវិលក៏បញ្ជូនទៅប្រទេសក្រៅ ប្រុងប្រៀបបំពេញភារកិច្ចរបស់សេ.អ៊ី.អាតាមផ្នែករបស់ខ្លួន ក្នុងការទាក់ទងជាមួយផ្នែកស៊ីវិលបរទេសដែលទាក់ទងនឹងទាហាន ។

◆ គម្រោងនឹងយកស៊ីវិលនិងទាហានទៅរៀននិងហ្វឹកហ្វឺននៅប្រទេសក្រៅនានា មកជួយបំរើផែនការនៅពេលត្រូវការប្រទេសដែលបញ្ជូនទៅក្រោមការឧបត្ថម្ភពីអាមេរិកផ្ទាល់និងបក្សសម្ព័ន្ធដូចជា អាមេរិក ហ្វីលីពីន ឥណ្ឌូនេស៊ី សៀម អូស្ត្រាលី និងនូវែលហ្សេឡង់ នៅភូមិភាគអាស៊ីនេះ ។

◆ នៅក្នុងក្រុងក៏បានរៀបចំសម្រាប់រំលំរបបបដិវត្តន៍ ដោយប្រគល់ផែនការទៅខាងយោធា គឺក្នុងរយៈពេល៧ខែក្រោយខ្មែរក្រហមរំដោះក្រុង មានព្រឹត្តិការណ៍វាយយកវិញតាមកម្លាំង ។

◆ តាមរោងចក្រត្រូវរៀបចំបំផ្លិចបំផ្លាញបន្ទាក់ដំណើរការនិងជួយកក្កូរកកាយផ្ទៃក្នុង ពេលណាមានសកម្មភាពពីខាងក្រៅចូលមក ដូចជាផែនការខែ៧នេះក៏ដោយ គឺតាមរោងចក្រត្រូវជួយមួយផ្នែកផ្ទៃក្នុង ។

◆ រដ្ឋការស៊ីវិល មជ្ឈដ្ឋានសិក្សានិងស៊ីវិលក៏មានភារកិច្ចជួយធ្វើឲ្យមានការច្របូកច្របល់តាមក្រសួងរបស់ខ្លួនដែរ ។

ចំពោះកម្លាំងមនុស្សនិងសកម្មភាពផែនការសេ.អ៊ី.អាមុនពេលចាញ់ គឺខ្ញុំបានជម្រាបតាមការដឹងដូចខាងលើតែព្រឹត្តិ-ការណ៍ធំបំផុត គឺសេ.អ៊ី.អាពុំបានគិតដល់ជម្លៀសប្រជាជនចេញពីភ្នំពេញ ហើយបណ្តាលឲ្យដាច់ខ្សែរយៈអស់ ។

◆ នៅតាមទល់ដែនជាមួយសៀម សកម្មភាពផែនការរៀបចំរបស់សេ.អ៊ី.អា បានបង្កប់កម្លាំងនៅជាយដែន និងតាមកន្លែងខ្លះមានកម្លាំងយោធានៅដោយកន្លែងៗ ។

◆ ប្រុងប្រៀបជាកប៉ាល់សម្រាប់វាយប្រហារដែលគ្រោងទុកនៅខែ១២-៧៦ និងខែ៤-៥-៧៦ ។

## សកម្មភាពជាផែនការក្រោយពេលចាញ់

◆ ជនជម្លៀសចេញពីភ្នំពេញបំផុសបំផុលប្រជាជនដែលទៅជាមួយ ។

◆ ជនជម្លៀសពីភ្នំពេញចាប់បំផុសបំផុលតាមជនបទពេលទៅរស់នៅជាមួយ ហើយនឹងកសាងកម្លាំងថ្មី ។

◆ សេ.អ៊ី.អានៅតាមរោងចក្រនានាក៏ចាប់ផ្តើមបំផុសបំផុលកម្មករ និងទាក់ទងរកខ្សែរយៈ ។

◆ ក្រោយពីបំផុស កម្មករក៏បានអនុវត្តផែនការធ្វើឲ្យម៉ាស៊ីនខូច បន្ទាក់ដំណើរការនិងកសាងកម្លាំងថ្មីៗទៀត ទិសដែលអនុវត្តនៅក្នុងរោងចក្រ គឺត្រៀមចាំជួយធ្វើឲ្យមានការច្របូកច្របល់ក្នុងរោងចក្រពេលដែលមានការវាយប្រហារពីក្រៅរោងចក្រ ។

◆ គម្រោងក្រោយចាញ់នៅក្រុងភ្នំពេញ ដែលជាគម្រោងកម្រិតទី១ វាយយកក្រុងមកវិញនោះបានរលាយ ដោយគ្មានកម្លាំងនិងប្រជាជននៅក្នុងក្រុង ។

◆ ផែនការនៅតាមទល់ដែនក្រោយចាញ់នេះ បើយោងទៅតាមគម្រោងមុនចាញ់ គឺមានទ័ពធ្វើសកម្មភាពនិងសេ.អ៊ី.អាធ្វើសកម្មភាពចូលមកក្នុងកម្ពុជាតាមកន្លែងៗ ។

**(នៅមានត)**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេច នៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយៈ យិន នាន

| ល.រ | ឈ្មោះដើម | តួនាទី | កន្លែងយក | ថ្ងៃកម្ទេច | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ម៉ម អេន | ពលទោ | | ២២-៣-៧៦ | |
| ២ | កែវ សុផល | ដោយបីជាន់ (ពលបាលឯក) | ២២-៣-៧៦ | | |
| ៣ | ចាន់ ទី | កាប៉ូរ៉ាល់ | | ២២-៣-៧៦ | |
| ៤ | អ៊ុយ កែវ | ពលទោ | | ២២-៣-៧៦ | |
| ៥ | ពេទ្យ សុបិន | ព្រឹទ្ធបាលឯក | | ២២-៣-៧៦ | |
| ៦ | សុខ ផុន | ពលទោ | | ២២-៣-៧៦ | |
| ៧ | សូ ចក់ | ពលទោ | ក្រោមពេទ្យចិនពោចិនតុង | ២២-៣-៧៦ | |
| ៨ | ជួប ហេង | ពលទោ | | ២២-៣-៧៦ | |
| ៩ | កែវ ភួង | ពលទោ | | ២២-៣-៧៦ | |
| ១០ | កែវ ពួនហោង | ពលទោ | | ២២-៣-៧៦ | |
| ១១ | គង់ ឃឿន | ពលទោ | | ២២-៣-៧៦ | |
| ១២ | ហុង ហឹម | ពលទោ | | ២២-៣-៧៦ | |
| ១៣ | ស៊ូ សឿន | ពលបាលត្រី | | ២២-៣-៧៦ | |
| ១៤ | ស សារ៉ាត | នាយឯក | | ២២-៣-៧៦ | |
| ១៥ | គឹម អ៊ុក | ដោយពជាន់ (ពលបាលឯក) | តំបន់២៥ | ២២-៣-៧៦ | |
| ១៦ | ឡុង ហេង | កាប៉ូរ៉ាល់ | | ២២-៣-៧៦ | |
| ១៧ | ចាយ សុវណ្ណា | គិញ | ក្រោយពេទ្យចិន | ២២-៣-៧៦ | |
| ១៨ | ខេង ខន | ពលទោ | | ២២-៣-៧៦ | |
| ១៩ | យូ សារឿន | ដោយពជាន់ (ពលបាលឯក) | បាត់ដំបង | ២២-៣-៧៦ | |
| ២០ | អេង ផល | កាប៉ូរ៉ាល់ | បាត់ដំបង | ២២-៣-៧៦ | |
| ២១ | ពេជ សៅខេង | ដោយ១ជាន់ (ពលបាលទោ) | បាត់ដំបង | ២២-៣-៧៦ | |
| ២២ | យឹម ទី | នាយឯក | | ២២-៣-៧៦ | |
| ២៣ | ទូត ញឹម | នាយឯក | វត្តបារ៉ាយ | ២២-៣-៧៦ | |
| ២៤ | ង៉ែត ស៊ឹម | ពលទោ | ពោធិចិនតុង | ២២-៣-៧៦ | |
| ២៥ | អ៊ុង ដា | ពេទ្យទាហាន | | ២២-៣-៧៦ | |
| ២៦ | ប្រាំង មួង | ពលទោ | ពោធិចិនតុង | ២២-៣-៧៦ | |
| ២៧ | នុត ហុន | កាប៉ូរ៉ាល់សេហ្ | ប៉ៃអឹម | ២២-៣-៧៦ | |
| ២៨ | ឌុម សារិ | ដោយប៉ៃអឹម | | ២២-៣-៧៦ | |
| ២៩ | បាន់ អៀច | ពលទោ | | ២២-៣-៧៦ | |
| ៣០ | ង៉ួន ឡែម | ព្រិទ្ធបាលទោ | | ២២-៣-៧៦ | |
| ៣១ | ថោង ឈួង | ពលទោ | | ២២-៣-៧៦ | |

| | | | | |
|---|---|---|---|---|
| ៣២ | គីម សំបាត់ | ពលទោ | ២២-៣-៧៦ | |
| ៣៣ | យស គិន | ពលទោ | ២២-៣-៧៦ | |
| ៣៤ | បាន់ នី | ពលទោ | ២២-៣-៧៦ | |
| ៣៥ | ឃួន វុទ្ធី | ពលទោ | ២២-៣-៧៦ | |
| ៣៦ | វង់ សារិត | ពលទោ | ២២-៣-៧៦ | |
| ៣៧ | សោម សាក់ | ពលទោ | ២២-៣-៧៦ | |
| ៣៨ | មូវ ចាន់ផល | ពលទោ | ២២-៣-៧៦ | |
| ៣៩ | ហង់ សៀ | ពលទោ | ២២-៣-៧៦ | |
| ៤០ | គ្រូច គុធ្វាង | ពលទោ | ២២-៣-៧៦ | |
| ៤១ | ហង់ ស្រាំ | ពលទោ | ២២-៣-៧៦ | |
| ៤២ | ឡុច យ៉ាន | ពលទោ | ២២-៣-៧៦ | |
| ៤៣ | គង់ អួន | ពលទោ | ២២-៣-៧៦ | |
| ៤៤ | ងៀង យ៉ាងអឿង | ពលទោ | ២២-៣-៧៦ | |
| ៤៥ | សាម សន | ពលទោ | ២២-៣-៧៦ | |
| ៤៦ | មៅ បូរ៉ាន | ពលទោ | ២២-៣-៧៦ | |
| ៤៧ | ស ប៊ុនរ៉ា | ពលទោ | ២២-៣-៧៦ | |
| ៤៨ | ប៉ិត ដាត ហៅ ប៉ូ សុន | ទាហានស័ក្តិ២ | ២២-៣-៧៦ | |
| ៤៩ | ពេជ ខុន | ទាហានស័ក្តិ៤ | ២៦-៣-៧៦ | |
| ៥០ | ពេជ ស៊ីមឿន | ទាហានស័ក្តិ៤ | ២៦-៣-៧៦ | |
| ៥១ | សើន ហេង | ទាហានស័ក្តិ៣ | ២៦-៣-៧៦ | |
| ៥២ | ខៀវ អាន | ទាហានស័ក្តិ៤កន្លះ | ២៦-៣-៧៦ | |
| ៥៣ | ណុប អ៊ូច | ទាហានស័ក្តិ៤កន្លះ | ២៦-៣-៧៦ | |
| ៥៤ | វង់ សុផាណូ | ទាហានសក្តិ៥ | ២៦-៣-៧៦ | |
| ៥៥ | បាន អ៊ូចនិលពេជ | ទាហានស័ក្តិ៤កន្លះ | ២៦-៣-៧៦ | |
| ៥៦ | ណឹង កែវ | ទាហានស័ក្តិ៤ | ២៦-៣-៧៦ | |
| ៥៧ | ប៉ុក ជុំ | ទាហានសក្តិ៤កន្លះ | ២៦-៣-៧៦ | |
| ៥៨ | ចៅ គក | ទាហានស័ក្តិ២ | ២៦-៣-៧៦ | |
| ៥៩ | ហាម ជឹម | ទាហានស័ក្តិ៣ | ២៦-៣-៧៦ | |
| ៦០ | ស ប៊ុនគី | ទាហានស័ក្តិ៥ | ២៦-៣-៧៦ | |
| ៦១ | ព្រែក យុន | ទាហានស័ក្តិ៤កន្លះ | ២៦-៣-៧៦ | |
| ៦២ | ឡុង ធិន | គ្រូបង្រៀន | ២៩-៣-៧៦ | ខ្សែឡុងបូរ៉េត |
| ៦៣ | ឡុង ប៊ុនដារ៉ា | គ្រូបង្រៀន | ២៩-៣-៧៦ | ខ្សែឡុងបូរ៉េត |
| ៦៤ | ឡុង សុធារី | កូនសិស្ស | ២៩-៣-៧៦ | ខ្សែឡុងបូរ៉េត |
| ៦៥ | ឡុង ធីរ៉ាវុធ | កូនសិស្ស | ២៩-៣-៧៦ | ខ្សែឡុងបូរ៉េត |
| ៦៦ | ញ៉ែម ម៉ិះ | មេផ្ទះ ប្រពន្ធ ឡុង ធិន | ២៩-៣-៧៦ | **(នៅមានត)** |

# រូបថតឯកសារ

រូបថតខាងក្រោមនេះជាអតីតយុទ្ធជននៅមន្ទីរស-២១ (គុកទួលស្លែង) ។ ក្នុងចំណោមយុទ្ធជនទាំងនេះមួយចំនួនបានក្លាយជាអ្នកទោសនៅមន្ទីរស-២១ដដែល ហើយត្រូវបានស្លាប់ក្រោមស្នាដៃយុទ្ធមិត្តរួមការងារ ។ យុទ្ធជនមួយចំនួនទៀតស្លាប់ក្រោយឆ្នាំ១៩៧៩និងមួយចំនួនទៀតនៅរស់រានមានជីវិតដល់បច្ចុប្បន្ន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្រាវជ្រាវរកឃើញអត្តសញ្ញាណតាមរយៈរូបថតមួយចំនួនដូចខាងក្រោម៖







**រូបទី១**

◆ ស៊ីន កុយ អាយុ ២០ឆ្នាំ ជាយុទ្ធជននៅក្នុងកងការពារនៅមន្ទីរ ស-២១ ។ វណ្ណភាពកសិករក្រ កម្រិតវប្បធម៌ថ្នាក់ទី១០ចាស់ ។ ចូលបដិវត្តន៍នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៣ ។ ឪពុកឈ្មោះ ស៊ីន ណយ ម្តាយឈ្មោះ ជា គ្រិក ។ ស្រុកកំណើតនៅភូមិកំពង់សំបួរក្រោម ឃុំព្រែកថ្មី ស្រុក១៨ (កោះធំ) តំបន់២៥ ។ ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៧ ។ (បច្ចុប្បន្នៈមិនដឹង) ។




**រូបទី២**

◆ អ៊ុង ជឿន អាយុ១៧ឆ្នាំ (ឆ្នាំ១៩៧៧) ជាអ្នកបើកបររថយន្តនៅមន្ទីរ ស-២១ ។ ស្រុកកំណើត ភូមិឫស្សីស្រុក ឃុំឈើទាល ស្រុក១៦ តំបន់២៥ ។ ចូលបដិវត្តន៍នៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៥ ។ ម្តាយឈ្មោះ នៅ ឡៃ ឪពុកឈ្មោះ អ៊ុន ជៀវ ។ មានបងប្អូន៥នាក់ ប្រុស៤នាក់ ស្រី១នាក់ ។ (បច្ចុប្បន្នៈមិនដឹង) ។

**រូបទី៣**

◆ អូយ ផនលី ឈ្មោះបដិវត្តន៍ អូយ លី អាយុ១៩ឆ្នាំ ជាយុទ្ធជនសួរចម្លើយនៅមន្ទីរស-២១ ។ នៅឆ្នាំ១៩៧៧ លី ត្រូវចាប់ខ្លួនដាក់ឃុំក្នុងមន្ទីរស-២១វិញម្តង ។ លី មានស្រុកកំណើតនៅភូមិព្រែកតាកែ ឃុំកោះធំ ស្រុក១៨ (កោះធំ) តំបន់២៥ ។ លី ជាកូនទោលដែល

មានឪពុកឈ្មោះ អួយ ម្តាយឈ្មោះ គុល ជូ ។ កម្រិតវប្បធម៌ថ្នាក់ទី៩ចាស់ ។ លី ចូលបដិវត្តន៍នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៧៣ និងត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៧ ។ (បច្ចុប្បន្នៈមិនដឹង) ។




**រូបទី៤**

◆ សោម ម៉េត អាយុ២០ឆ្នាំ (ឆ្នាំ១៩៧៨) កងការពារនៅមន្ទីរ ស-២១ ។ កើតនៅភូមិព្រែកស្តី ឃុំព្រែកស្តី ស្រុក១៨ (កោះធំ) តំបន់២៥ ។ ឪពុកឈ្មោះ សោម សុខ ម្តាយឈ្មោះ អ៊ុក ណន ឬ (អ៊ុក អន) បងប្រុសឈ្មោះ សោម តយ ។ កម្រិតវប្បធម៌ថ្នាក់ទី១១ចាស់ ។ ចូលបដិវត្តន៍ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៣ ។ បច្ចុប្បន្នរស់នៅខេត្តកណ្តាល ។




**រូបទី៥**

◆ ម៉ាន់ ម៉េង អាយុ២៤ឆ្នាំ (ឆ្នាំ១៩៧៧) ជាចុងភៅនៅមន្ទីរស-២១ ។ ស្រុកកំណើតនៅភូមិកណ្តាលកោះ ឃុំទឹកវិល ស្រុក២០ (លើកដែក) តំបន់២៥ ។ ឪពុកឈ្មោះ ម៉ាន់ សម្បត្តិ ម្តាយឈ្មោះ សំ ភាច ។ មានបងប្អូន៥នាក់ ប្រុស២នាក់ ស្រី៣នាក់ ។ កម្រិតវប្បធម៌ថ្នាក់ទី១០ចាស់ ។ ចូលបដិវត្តន៍ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧២ ចូលជាសមាជិកសម្ព័ន្ធយុវកកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៧៣ ។ ចូលបម្រើការងារនៅមន្ទីរស-២១ នៅខែតុលា ឆ្នាំ១៩៧៥ ។ នៅចុងឆ្នាំ១៩៧៧ ត្រូវបាន ឌុច ចាប់ដាក់មន្ទីរស-២១ ។ (បច្ចុប្បន្នៈមិនដឹង) ។




**រូបទី៦**

◆សួស ធី ឈ្មោះបដិវត្តន៍ ធី ។ កើតថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៥១ នៅភូមិព្រែកកែវ សង្កាត់កោះខែល ស្រុក២០ តំបន់២៥ ។ ចូលបដិវត្តន៍នៅថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧១ នៅឃុំកោះខែល ស្រុក២០ តំបន់២៥ ។ ចូលអង្គការយុវកកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៣ នៅភូមិរាយដប សង្កាត់រាយដប ស្រុកកណ្តាលស្ទឹង តំបន់២៥ ។

◆ កម្រិតវប្បធម៌ថ្នាក់ទី២ចាស់ សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ។

◆ ឪពុកឈ្មោះ សួស ធុយ ម្តាយឈ្មោះ ញឹម វឿន ។

◆មានបងប្អូន៨នាក់ ប្រុស៤នាក់ ស្រី៤នាក់ ។ (បច្ចុប្បន្នៈ រស់នៅខេត្តកណ្តាល) ។

**(នៅមានត)** សាន់ កល្យាណ


26-2-78
35 5

**(តពីលេខមុន)**

### អំពើហិង្សានិងការសប្បាយដោយបានធ្វើបាបអ្នកទោស

ការសួរចម្លើយត្រូវបញ្ឈប់ រឹតបន្តឹង ឬផ្អាកយ៉ាងណាៗនោះ គឺស្រេចតែប្រធានក្រុមសួរចម្លើយតែប៉ុណ្ណោះ ។ ចំណែកឯអ្នកធ្វើទារុណកម្មវិញអាចប្រើដៃ ប្រើអាវុធថ្មី ឬយកអ្នកទោសទៅបន្ទប់របស់ខ្លួនតែម្តង ។ ប្រសិនបើវាយឬសួរចម្លើយហើយចេញជាចម្លើយសារភាពនោះមិនថ្មីទេ ប៉ុន្តែប្រសិនបើធ្វើទារុណកម្មខ្លាំងហើយ នៅតែមិនចេញទៀតនោះគឺជាបញ្ហាធំបំផុត ។ អ្នកទោសខ្លះត្រូវបានសួរចម្លើយជារៀងរាល់ថ្ងៃ ។ គេន ចាន់ ដា អ្នកដែលមានវាសនាចាកផុតពីសេចក្តីស្លាប់ បានរំឭកឡើងវិញថា ខ្លួនទទួលរងការវាយដំប្រាំធាក់ ហើយជួនកាលរងទារុណកម្មរហូតដល់២៦ថ្ងៃជាប់រហូត ។

ជនរងគ្រោះដោយធ្វើទារុណកម្មច្រើនតែស្លាប់ ។ អ្នកគ្រប់គ្រងគុកមិនមានការបារម្ភអ្វីឡើយ អ្នកទោសណាស្លាប់ក៏ស្លាប់ទៅ ឲ្យតែបានជម្រិតយកចម្លើយសារភាព ។ ប៉ុន្តែប្រសិនបើអ្នកទោសស្លាប់មុនពេលស្រង់ចម្លើយសារភាព អ្នកសួរចម្លើយច្រើនតែត្រូវបានសង្ស័យថាជាអ្នកធ្វើ«វិទ្ធង្សនា» ។ អ្នកសួរចម្លើយជាច្រើនដែលជាប់ឃុំនៅមន្ទីរស-២១ បានសារភាពថាខ្លួនធ្លាប់ធ្វើឲ្យអ្នកទោសស្លាប់នៅពេលសួរចម្លើយ ហើយឆ្នាំពីរនាក់ទៀតក៏និយាយដូចគ្នានេះដែរ ប៉ុន្តែភាគច្រើននៅតែមិនច្បាស់នៅឡើយថាតើនេះជាកំហុសមួយក្នុងចំណោមកំហុសនានាដែលនាំឲ្យអ្នកសួរចម្លើយនិងឆ្មាំត្រូវចាប់ខ្លួន ឬថាកំហុសនេះចេញពីការវាយតម្លៃលើសកម្មភាពរបស់អ្នកទាំងនេះកាលពីអតីតកាលដែលទើបកន្លងទៅឬយ៉ាងណា ។ អារម្មណ៍សប្បាយដែលបានធ្វើបាបអ្នកទោសតែងតែកើតឡើងជារឿយៗដូចដែលអតីតឆ្មាំគុកម្នាក់ឈ្មោះ សុន មឿន បានសរសេរនៅក្នុងចម្លើយសារភាពរបស់ខ្លួនថា «ក្រោយពីគេចាត់តាំងឲ្យខ្ញុំយាមអ្នកទោសនៅក្នុងគុកពិសេស(ខាងត្បូងទួលស្លែង) ខ្ញុំឃើញ(អ្នកសួរចម្លើយ)កំពុងតែវាយអ្នកទោស ហើយនៅពេលអ្នកសួរចម្លើយចេញបាត់ទៅ ខ្ញុំក៏លួចចូលទៅវាយអ្នកទោសបន្ថែមទៀត ដោយរុញទាត់ធាក់និងវាយតាមចិត្ត វាយទាល់តែអ្នកទោសសួរថា«តើឯងកំពុងតែធ្វើអ្វីហ្នឹង? ឯងចង់សម្លាប់ខ្ញុំតាមផ្លូវនេះមែនទេ?» ។




**សម្លេងពីមន្ទីរ ស-២១**
**វគ្គទី៥: បង្ខំឱ្យឆ្លើយ**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

បន្ទាប់ពីការធ្វើទារុណកម្មមិនយូរប៉ុន្មានអ្នកទោសឈ្មោះ ប៊ុន ថន ក៏ត្រូវស្លាប់ដោយរងរបួសដែលបង្កឡើងដោយអ្នកសួរចម្លើយនិងឆ្មាំគុក ។ ចម្លើយសារភាពរបស់ ប៊ុន ថន មិនមានលក្ខណៈពេញលេញទេ ។

ដោយចាក់សោទុកនៅក្នុងស្ថាប័នស្ងាត់ដែលមានភាពប្រទាញប្រទង់គ្នារវាងការបណ្តោយឲ្យធ្វើតាមចិត្ត និង«វិន័យ» រវាងការផ្តល់អំណាចនិងការមិនទុកចិត្ត និងរវាងអំពើឃោរឃៅនិងការឃោសនា អ្នកសួរចម្លើយតែងតែឈរខ្សែកណ្តាល «មិនធ្វើខ្លាំងពេកនិងមិនខ្សោយពេក» ។ អ្នកសួរចម្លើយតែងតែមានកំហុសដោយការ (ធ្វើទារុណកម្ម)ហួសកំណត់ ។ កំហុសដោយធ្វើទារុណកម្មជ្រុលកម្រនឹងទទួលរងទណ្ឌកម្មណាស់ ចំណែកឯការប្រឹងប្រយ័ត្នក៏គ្មានទទួលបាននូវការលើកទឹកចិត្តដែរ ។

មិនខុសពីអ្នកធ្វើការងារដូចគ្នានេះនៅជំរំមរណៈណាហ្សីទេ គឺថាអ្នកសួរចម្លើយគ្មានអារម្មណ៍ជាមនុស្សឡើយ ។ តាមការវាយតម្លៃលើឯកសារដែលនៅសេសសល់ឃើញថា ភាពឃោរឃៅនៅក្នុងគុកគឺជាអ្វីដែល វ៉ែនដល កូលីន បានហៅ «ភាពឃោរឃៅដែលគ្មានមនោសញ្ចេតនា» ដែលក្នុងនោះប្រភពនៃភាពឃោរឃៅគឺគ្រាន់តែជាឧបករណ៍ឬឧបសគ្គមួយប៉ុណ្ណោះ ។ ចំណែកការឈឺចាប់ដែល កូលីន បានទទួលរង គ្រាន់តែជាហេតុការណ៍កើតឡើងដោយចៃដន្យ (ដែលជាទូទៅគ្មានអ្នកណាដឹងពុំឡើយ)សម្រាប់បំណងផ្សេង ។ ឧទាហរណ៍ជាក់ស្តែងបង្ហាញ

ពីភាពឃោរឃៅគឺចំណាររបស់ ប៊ុន ផ្ញើទៅ ឌុច ក្រោយពីធ្វើការសួរចម្លើយដ៏ធ្ងន់ធ្ងររួច ។ អ្នកទោសមានឈ្មោះថា កែ មាស ជាអតីតគណៈកម្មាធិការមជ្ឈិម ។ ប៊ុន បានសរសេរថា÷ «នៅយប់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៦ ក្រោយពីសម្ភុត អ្នកទោសពីរ-បីម៉ាត់ ហើយខ្ញុំក៏ដោះអាវវាចេញនិងដាក់ខ្នោះវា ដោយដាក់ដៃទៅក្រោយ ។ ខ្នោះនេះដោះចេញនៅពេលបាយតែប៉ុណ្ណោះ ។ មិនឲ្យវាដេកលក់ ហើយឲ្យមូសខាំវា» ។

## ទារុណកម្មព្រហ្មទណ្ឌ និងទារុណកម្មតាមផ្លូវតុលាការ

បាតុភាពនៃអំពើទារុណកម្មនិងអំពើឃោរឃៅនៅមន្ទីរ ស-២១ ចាំបាច់ត្រូវដាក់នៅក្នុងបរិបទប្រវត្តិសាស្ត្រ ។ តើអំពើទាំងនេះមានឫសគល់នៅក្នុងប្រទេសកម្ពុជាសម័យមុនបដិវត្តន៍ដែរឬទេ ឬតើជាបាតុភូតកើតឡើងដោយការចាំបាច់របស់ខ្មែរក្រហមនិងយកតាមគំរូរបស់បរទេសឬទេ?

ដើមកំណើតនៃពាក្យផ្ទុះបញ្ចាំងពីបញ្ហាទារុណកម្មខ្លួនឯងមួយកម្រិតដែរ ។ ពាក្យទារុណកម្មដែលប្រើដូចគ្នានឹងពាក្យថៃមានដើមកំណើតចេញមកពីពាក្យទារុណ ដែលមានន័យថា «កាច» ឬ «អាក្រក់» ចំណែកឯពាក្យបាលី «កម្ម» មានន័យថា «អំពើ» ។ តាមវចនានុក្រមខ្មែរបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ន័យមួយទៀតនៃពាក្យនេះគឺ «អំពើអាក្រក់» និង «អំពើសាហាវយង់ឃ្នង» ។ ឧទាហរណ៍មួយនៅក្នុងវចនានុក្រមនេះដាក់ថា«ពុំគួរធ្វើទារុណកម្មដល់មនុស្សនិងសត្វឡើយ» ។

ដូច្នេះពាក្យទារុណកម្មនៅក្នុងភាសាខ្មែរគ្រាន់តែបញ្ជាក់អំពីភាពឃោរឃៅ បង្កប់ភាពអាប់យស ប៉ុន្តែមិនទាក់ទងនឹងរដ្ឋបាលតុលាការទេ ។ ឃ្លាថា «ដាក់ទារុណកម្ម» បញ្ជាក់ពីពិសោធន៍ឃោរឃៅ ឬអ្វីដែល ហ៊្វូខល និង រីចាលី ហៅថា «ទារុណកម្មព្រហ្មទណ្ឌ» ដែលតំណាងឲ្យអ្វីដែល ហ៊្វូខល ហៅថា «ការសងសឹករបស់អ្នកកាន់អំណាច» មិនមែនជាអ្វីដែល អេដវឺដ ភីតធ័រ ហៅថាទារុណកម្មផ្នែកតុលាការ ដែលជាទូទៅទាក់ទងដល់ការប្រមែប្រមូលភស្តុតាងនិងការទាញយកចម្លើយសារភាពនោះទេ ។

ការសិក្សាស្រាវជ្រាវរបស់ ភីតធ័រ មានដើមកំណើតចេញពីការធ្វើទារុណកម្មផ្លូវតុលាការពីប្រទេសក្រិចនៅសតវត្សរ៍ទី៥មុនគ្រិស្តសករាជ ។ នៅប្រទេសក្រិចកាលនោះ ការធ្វើទារុណកម្មត្រូវបានធ្វើឡើងតែទៅលើទាសករតាមរយៈការវិវឌ្ឍន៍តាមក្រោមច្បាប់រ៉ូម៉ាំង និងការនិយមប្រើច្បាប់នេះឡើងវិញរបស់ពួកអឺរ៉ុបនៅសតវត្សរ៍ទី១២និង១៣នៃគ្រិស្តសករាជ ។ ភីតធ័រ រៀបរាប់នូវអ្វីដែលលោកហៅថា «ធ្វើឲ្យដូចគ្នា» ទៅនឹងទារុណកម្មតាមផ្លូវតុលាការដែលកើតមានឡើងរវាងសតវត្សរ៍ទី១៣និងសតវត្សរ៍ទី១៨ ហើយដែលកាលណោះការអនុវត្តនេះត្រូវទទួលការរិះគន់យ៉ាងខ្លាំង ។ ភីតធ័រ បិទសៀវភៅរបស់គាត់ ហើយពិភាក្សាអំពីការនិយមប្រើទារុណកម្មតាមផ្លូវតុលាការនៅលើពិភពលោកនាពេលថ្មីនេះៗ ។

ចំណុចខ្វះខាតនៅក្នុងការសិក្សារបស់ ភីតធ័រ គឺការមិនទាញយកគំរូទារុណកម្មផ្លូវតុលាការរបស់អាស៊ីឲ្យបានលម្អិត ។ ទាំងទារុណកម្មផ្លូវតុលាការនិងទារុណកម្មព្រហ្មទណ្ឌត្រូវបានអនុវត្តជាទូទៅនៅប្រទេសជប៉ុននិងវៀតណាម ជាពិសេសប្រើសម្រាប់សួរចម្លើយឈ្លើយសឹក ឬនៅពេលតម្រូវឲ្យមានចម្លើយសារភាព ឬឈ្មោះរបស់អ្នកធ្វើការជាមួយអ្នកទោស ។ វចនស័ព្ទ *kao wen* អាចយកមកបំបែកចេញជាពីរពាក្យ មួយមានន័យថា «សួរចម្លើយ» និងមួយទៀតមានន័យថា «វាយ» ។ ចំណែកឯពាក្យវៀតណាម «ចាទិន» ប្រើកិរិយាស័ព្ទ «ពិនិត្យ»និង«សួរសំណួរ» ដោយមិននិយាយដល់អំពើឃោរឃៅឡើយ ។ សញ្ញាណនៃការផ្សំគ្នារវាងទារុណកម្មជាមួយនឹងការសួរចម្លើយដើម្បីជម្រិតយកចម្លើយសារភាព ហាក់ដូចជាផ្នត់គំនិតចិន-វៀតណាម និងផ្នត់គំនិតអឺរ៉ុប ប៉ុន្តែគំនិតនេះមិនមាននៅក្នុងផ្នែកខ្លះនៃព្រះពុទ្ធសាសនានិកាយថេរវាទនៅអាស៊ី-អាគ្នេយ៍ទេ ។ គ្មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាផ្នត់គំនិតនេះបានមកដល់កម្ពុជាមុនសម័យកម្ពុជាប្រជាធិបតេយ្យឡើយ ។

ទោះបីជាមានការខ្វះខាតចន្លោះរឿងរ៉ាវនៅអាស៊ីយ៉ាងណាក៏ដោយ ក៏អ្វីដែល ភីតធ័រ សរសេរអំពីទារុណកម្មផ្លូវតុលាការនៅអឺរ៉ុបមុនឆ្នាំ១៨០០គឺមានពាក់ព័ន្ធនឹងមន្ទីរស-២១ ។ ភីតធ័រ ប្រាប់យើងថា ដោយមានការកើនឡើងនូវគ្រិស្តសាសនាទារុណកម្មតាមផ្លូវតុលាការក្លាយជាទារុណកម្មទាំងស្រុងចំពោះ

រឿងអញ្ញមតិ (មតិដែលផ្ទុយពីអ្វីដែលមានជាទូទៅ) ។ ករណីនេះត្រូវបានធ្វើយុត្តិកម្ម ពីព្រោះមួយផ្នែកមកពី“អញ្ញមតិ គឺជាបទល្មើសរួមហើយក្រៅពីការសង្គ្រោះព្រលឹងអញ្ញទិដ្ឋិជន អ្នកអង្កេតត្រូវការឈ្មោះរបស់អ្នកគាំទ្រអញ្ញទិដ្ឋិ” ។ ដោយមានការធ្វើទារុណកម្មមកលើខ្លួន អញ្ញទិដ្ឋិជនដែលត្រូវសង្ស័យថាបានឲ្យឈ្មោះអ្នកដែលនឹងចូលខ្លួនមកទទួលទារុណកម្ម ហើយអ្នកទាំងនេះចេះតែឲ្យឈ្មោះអ្នកផ្សេងៗទៀតបន្តកន្ទុយគ្នារដឹកនៅក្នុងទ្រង់ទ្រាយមិនខុសពីអ្នកដែលជាប់ឃុំនៅទួលស្លែងប៉ុន្មានសតវត្សរ៍កំពូលទើបបាន ។ ករណីបែបនេះភាគច្រើនមិនខុសពីនៅមន្ទីរស-២១ទេ គឺចុងចោទដែលត្រូវបានសន្មតចាប់តាំងពីក្បាលដំបូងថានឹងមានកំហុសនោះត្រូវបានអនុញ្ញាតតិចតួច ឬមិនផ្លូវការក្នុងការការពារខ្លួន ហើយត្រូវបានថ្កោលទោសទៅតាមពាក្យចចាមអារ៉ាម ។

## ទារុណកម្មនៅកម្ពុជាកាលពីអតីតកាល

នៅប្រទេសកម្ពុជាមុនសម័យបដិវត្តន៍គ្មានការធ្វើឯកសារទារុណកម្មសម្រាប់ប្រើជាភស្តុតាងទេ ទោះជានៅពេលខ្លះជន



យុទ្ធជនសួរចម្លើយកំពុងធ្វើទារុណកម្មទៅលើរាងកាយរបស់អ្នកទោស

វិចិត្រករៈ វ៉ាន់ ណាត
អតីតអ្នកទោសនៅមន្ទីរស-២១

ក្រោយមកទេ ។ នៅក្នុងសំណេរមួយដែលឆាយយល់ស្តីអំពីទារុណកម្មនៅមជ្ឈិមសម័យ តាឡាល់ អាសាឆ បានលើកឡើងថា “ដោយសារទោសនៃការប្រកាន់នូវទស្សនៈអញ្ញមតិមិនអាចបញ្ឈាក់ដាច់ដោយឡែកទៅលើចម្លើយសារភាពរបស់ជនជាប់ចោទ ទារុណកម្មត្រូវតែយកមកកាត់សេចក្តីមុនពេលកំហុសត្រូវបានបង្កើតឲ្យចេញជារូបរាងឡើង ។ ដោយសារទោសនេះត្រូវបានលាក់បាំង ការស្វែងរកការពិតត្រូវតែប្រើល្បិចសម្ងាត់ដល់សង្ស័យត្រូវបានដាក់ឲ្យទទួលរងនូវពិសោធន៍ដ៏ខ្លោចផ្សាដើម្បីឲ្យ“បង្ហាញ”ថាខ្លួនកំពុងតែកុហកឬប្រាប់ការពិតក៏ដោយ ។ ប៉ុន្តែភស្តុតាងនៅរាយប៉ាយបង្ហាញថាទារុណកម្មមានលក្ខណៈដូចជាការដាក់ទណ្ឌកម្មដែរ ហើយទោសដែលត្រូវទទួលទណ្ឌកម្មធ្ងន់ធ្ងរបំផុតនោះគឺទោសក្បត់ព្រះរាជា ។ ឧទាហរណ៍ជាក់ស្តែងឃើញមានចារលើសិលាចារឹកនៅប្រាសាទអង្គរវត្តមួយចំនួន ហើយត្រូវបានលើកឡើងថាជាទោសនៃការបំពានទៅលើសម្បថរបស់

មន្ត្រីខ្មែរកាលពីមជ្ឈិមសម័យ ។ ក្បាច់ចម្លាក់លឹបនៅវិចិត្រសាលខាងត្បូងអង្គរវត្តពិពណ៌នាអំពីទណ្ឌកម្មដែលអាចដាក់មកលើអ្នកទោសរំលោភបំពាន ។ នៅក្នុងចម្លាក់នេះមានឃើញរូប "យមៈ" ដែលជា"អធិបតីនរក"នៃសាសនាហិណ្ឌូជិះច្រកគាវលើខ្នងក្របីនាំយកមនុស្សប្រុសស្រីទាំងជួរៗ ទៅឋានសួគ៌ឬឋាននរកដែលជឿថាមានរហូតដល់៣២ជាន់ ។ នៅឋាននរក អ្នកទាំងនេះត្រូវបានដាក់ទោសទៅតាមបាបកម្មរបស់ខ្លួនមិនខុសពីអ្វីដែលជាការអះអាងរបស់ ដាណេ នៅក្នុងសំណេររបស់គាត់ ដែលមានចំណងជើងថា "ឋាននរក"ឡើយ ។ មគ្គុទ្ទេសក៍នៅអង្គរវត្តម្នាក់បានចង្អុលប្រាប់ភ្ញៀវទេសចរណ៍កាលពីឆ្នាំ១៩៨១ ថា "យមៈ" នេះគឺប្រៀបដូចជា ប៉ុល ពត អ៊ីចឹង ។


ប៉ុល ពត

នៅប្រទេសកម្ពុជាក្រោយសម័យអង្គរ នៅតាមជញ្ជាំងវត្តអារាមឃើញមានគំនូររូបភាពឋាននរកដែលមានជនរងគ្រោះជាច្រើនទទួលទារុណកម្ម ។ វ៉ាន់ ណាត បានប្រៀបធៀបរូបភាពនៅតាមជញ្ជាំងវត្តទៅនឹងបទពិសោធន៍របស់គាត់ផ្ទាល់ដែលបានជួបប្រទះ ។ វ៉ាន់ ណាត កត់សម្គាល់ថា ជាទូទៅអ្នកធ្វើការនៅក្នុងគុក ចាត់ទុកអ្នកទោសដូចជាប្រេតអ៊ីចឹង ។ សព្វថ្ងៃរូបគំនូររបស់ វ៉ាន់ ណាត ដែលរៀបរាប់ពីទារុណកម្មធ្វើឡើងនៅមន្ទីរស-២១ បានដាក់តាំងនៅតាមជញ្ជាំងសារមន្ទីរឧក្រិដ្ឋកម្មទួលស្លែង ។

ក្នុងន័យនេះ ការបំបាត់ភាពជាមនុស្សពីអ្នកទោសដែលធ្វើឡើងជាប្រព័ន្ធដូចដែល វ៉ាន់ ណាត បានលើកយកពិភាក្សានៅក្នុងបទសម្ភាសន៍ជាច្រើននោះ ប្រហែលជាអាចបញ្ជាក់បានថា អ្នកទោសទាំងនោះត្រូវបានចាប់ចងដោយចោទថាទមិឡមិនអាចកែប្រែបាន ។ ទមិឡ គឺជាគំនិតបែបព្រះពុទ្ធសាសនាដែលបានចាត់ទុកជាមនុស្សក្រោមសង្គម ។ ការបំបាត់ភាពជាមនុស្សពីអ្នកទោសបានធ្វើឲ្យអ្នកធ្វើការនៅមន្ទីរស-២១មានភាពងាយស្រួល ។ ការនេះមិនខុសគ្នាទៅនឹងអ្វីដែលកើតឡើងចំពោះជនជាតិ ជីហ្វ ហ្គីបស៊ី អ្នករួមភេទដូចគ្នា និងអ្នកទោសដទៃទៀតនៅជំរំមរណៈរបស់ណាហ្ស៊ីទេ ។ អ្នកដែលកំពុងតែត្រូវបានធ្វើទារុណកម្មនិងសម្លាប់ដូចជារូបគំនូរនៅតាមជញ្ជាំងវត្តគឺជាអ្នកដទៃ ។ ប៉ុល ពត បានបញ្ជាក់ច្បាស់នៅក្នុងសុន្ទរកថារបស់ខ្លួនកាលពីឆ្នាំ១៩៧៧និយាយពីអត្ថិភាពរបស់បក្សកុម្មុយនិស្តកម្ពុជាថា "សមាសភាពប្រឆាំងនឹងបដិវត្តន៍ដែលក្បត់និងព្យាយាមបំផ្លាញបដិវត្តន៍ មិនត្រូវទុកជាប្រជាជនយើងទេ" ។

ការប្រហារជីវិតជាសាធារណៈនៅក្នុងប្រទេសកម្ពុជាមុនសម័យអាណានិគមដែលដាក់ទោសឲ្យជីវីជាន់នោះ បានបង្ហាញអំពីអំណាចរបស់ព្រះមហាក្សត្រក្នុងការកម្ទេចពិរុទ្ធជន និងធ្វើឲ្យអ្នកមើលមានការស្ញើចសរសើរ ។ ការវិនិច្ឆ័យទៅលើមេៗនិងវាសនារបស់ពិរុទ្ធជនខ្លួនឯងផ្ទាល់ ដូចដែលបានរៀបរាប់តាមរយៈគំនូរនៅតាមជញ្ជាំងអង្គរវត្តនិងក្រោយមកនៅតាមវត្តអារាមគឺមើលទៅហាក់ដូចជាត្រូវបានធ្វើឡើងជាសាធារណៈទូទៅ ។

ការដាក់ទណ្ឌកម្មលើរាងកាយតាមវិធីផ្សេងៗទៀតនៅសម័យមុនអាណានិគម ក៏មានលក្ខណៈធ្ងន់ធ្ងរដែរ ។ ឧទាហរណ៍ដាក់ស្ដែង ក្រមច្បាប់កម្ពុជានៅសតវត្សរ៍ទី១៧មានទារុណកម្ម ៣១យ៉ាង ដែលជាការដាក់ទណ្ឌកម្មយ៉ាងឈឺចាប់ចំពោះអ្នកដែល "ចង់មានអំណាចខ្លាំងនិងចង់ក្បត់នឹងព្រះរាជាជាស្ដេចផែនដី" ។ និទានកថារបស់ខ្មែររឿងទុំទាវដែលនិពន្ធនៅសតវត្សរ៍ទី១៧ និងបោះពុម្ពផ្សាយនៅដើមទសវត្សរ៍ឆ្នាំ១៩៦០ ហើយសិស្សានុសិស្សគ្រប់ជំនាន់បានដឹងឮនោះបញ្ជាក់ថា នៅពេលសមាជិកគ្រួសារម្នាក់ត្រូវបានចោទថាក្បត់នឹងព្រះរាជានោះ គ្រួសារទាំងមូលនឹងត្រូវសម្លាប់ចោលទាំងអស់មិនឲ្យសល់ម្នាក់ឡើយ ។ គ្រួសារនោះត្រូវបានកប់ក្នុងដីត្រឹមកហើយឲ្យរនាស់ក្របីអូសកាត់លើក្បាលទាល់តែដាច់ខ្ទេចខ្ទី ។

ករណីកើតឡើងក្នុងសម័យមុនអាណានិគមនិងការប្រកាន់នូវរបៀបរបបបែបនេះមានលក្ខណៈដូចគ្នានឹងករណីដែលកើតឡើងនៅស្រុកបារាំងមុនសម័យបដិវត្តន៍ដែរ ។ ការប្រហារជីវិតជាសាធារណៈនៅប្រទេសបារាំងនេះបានរៀបរាប់យ៉ាង

ពិស្តារដោយលោក ម៉ៃឃើល ហ៊ូខល នៅដើមទំព័រនៃចំណងជើងថា"វិន័យនិងការដាក់ទណ្ឌកម្ម" ។ ប៉ុន្តែករណីទាំងនេះមានលក្ខណៈខុសប្លែកច្រើនពីអ្វីដែលកើតឡើងនៅមន្ទីរស-២១ ។ នៅមន្ទីរនេះទារុណកម្មត្រូវបានធ្វើឡើងដោយរើសមុខសញ្ញាដាច់ដោយឡែក ហើយមិនមានពាក់ព័ន្ធជាមួយការសម្លាប់ទេ ។ ការសម្លាប់ចោលជារឿងផ្សេងដែលត្រូវធ្វើឡើងនៅខាងក្រៅដោយសម្ងាត់និងទាំងហ្វូងៗ ហើយជាទូទៅនៅពេលយប់ទៀត ។ បើប្រមូលផ្តុំការធ្វើទារុណកម្មលើរាងកាយនិងភាពសម្ងាត់ដាច់ខាត ការធ្វើឯកសារនិងការស៊ើបការណ៍ឃើញថាការអនុវត្តទាំងអស់នេះមានលាយឡំនូវអ្វីដែលលោក ហ៊ូខល បានទាញហេតុផលរួចមកហើយថា មានការប្រែប្រួលទៅតាមដំណាក់កាល ហើយលោកហៅដំណាក់កាលទាំងនេះថាជា "ការសងសឹករបស់ព្រះរាជា ឬអ្នកកាន់អំណាច" និង "ការការពារសង្គម" ។

ក្នុងសម័យធ្វើអាណានិគមនៅកម្ពុជា (១៨៦៣-១៩៥៤) បារាំងបានបង្កើតនគរបាលឲ្យធ្វើការក្រោមការគ្រប់គ្រងរបស់ខ្លួន ។ នៅត្រឹមឆ្នាំ១៩០០ ឬឆ្នាំប្រហាក់ប្រហែលនេះ មន្ត្រីកម្ពុជាលែងប្រើទារុណកម្មព្រហ្មទណ្ឌទៀតហើយ ។ ដោយសារបារាំងមានការក្រែងរអែង ទារុណកម្មព្រហ្មទណ្ឌមិនដែលធ្វើឡើងជាចំហទេ ។ ផ្ទុយទៅវិញ បារាំងបានបង្កើតនីតិវិធីតុលាការនិងស្ថាប័នរដ្ឋបាលយុត្តិធម៌តាមរបៀបលោកខាងលិច ។ ប៉ុន្តែនៅក្នុងគម្រោងដែលគេគិតថាមានលក្ខណៈសមហេតុសមផលនេះ ការសួរចម្លើយលើអ្នកទោសច្រើនតែស្ថិតក្នុងសភាពសាហាវណាស់ ។ ក្រោយពីប្រទេសកម្ពុជាបានទទួលឯករាជ្យ មន្ត្រីនគរបាលដែលជាបរិវាររបស់បារាំងនៅតែវាយធ្វើបាបអ្នកទោស ហើយអ្នកដែលត្រូវបានចោទថាក្បត់តែងតែទទួលរងនូវទារុណកម្មមុនពេលសម្លាប់ចោល ។ នៅក្នុងរបប លន់ ណុល ឈ្លើយសឹកត្រូវបានធ្វើទារុណកម្មជម្រិតយកព័ត៌មានជាធម្មតាទៅហើយ ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏គ្មានភ័ស្តុតាងណាបញ្ជាក់ថានគរបាលបានអនុវត្តទារុណកម្មផ្លូវតុលាការយ៉ាងទូលំទូលាយ ឬយកទារុណកម្មបែបនេះធ្វើជាឧទាហរណ៍សម្រាប់សន្តិសុខជាតិដែរ មុនពេលដែលខ្មែរក្រហមឡើងកាន់អំណាចនោះ ។

ហេតុអ្វីមានករណីបែបនេះ? ជាបឋមសូមលើកករណីមួយចំនួនមកនិយាយ ។ អ្នកដែលត្រូវចោទប្រកាន់ថាក្បត់ជាតិក្រោមការគ្រប់គ្រងរបស់សម្តេច សីហនុ និង លន់ ណុល កម្របានមកកាន់តុលាការណាស់ ។ ដូច្នេះគ្មានការសុំឲ្យមានការឆ្លើយសារភាពពលម្អិតដូចការអនុវត្តទារុណកម្មតាមផ្លូវតុលាការឡើយ ។ កត្តាដាច់ណាត់មួយទៀតគឺថាមកដល់ឆ្នាំ១៩៧៥ នៅតែមាន



នីតិវិធីនគរបាលនិងតុលាការបែបលោកខាងលិចដដែល ។ ភ័ស្តុតាងដែលបានមកដោយសារការធ្វើទារុណកម្ម ប្រសិនបើយកមកប្រើប្រហែលជាអាចយកមកតវ៉ាដេញដោលនៅក្នុងតុលាការ ហើយការបើកចំហដែលមិនអាចទទួលយកបានប្រហែលជាធ្វើឲ្យអាប់កិត្តិយសរបស់កម្ពុជាផង ប្រសិនបើការណ៍នេះលេចឮដល់អ្នកសង្កេតការណ៍បរទេស ។ ការគាបសង្កត់បែបនេះក៏មានអនុវត្តនៅប្រទេសដទៃទៀតដែរ ។ ប្រសិនបើទារុណកម្មផ្លូវតុលាការកើតឡើងនៅប្រទេសកម្ពុជាក្រោយសម័យអាណានិគម ការគ្មានសេចក្តីបញ្ជាក់ពីឯកសារបង្ហាញថា ទារុណកម្មបែបនេះត្រូវបានធ្វើឡើងដោយសម្ងាត់ដូចជាទម្លាប់ធម្មតានៅតាមកន្លែងផ្សេងទៀតនៅសម័យបច្ចុប្បន្ននេះដែរ ។ **(នៅមានត)**

# ទំនាក់ទំនងចិននិងកម្ពុជាប្រជាធិបតេយ្យ កម្មាភិបាលខ្មែរក្រហមម្នាក់បរិយាយ


ម៉ាន

នៅក្រោយពេលដែលខ្មែរក្រហមដណ្តើមបានជ័យជម្នះរបស់ខ្លួន នៅថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ “បក្ស” បានប្រគល់អគារស្ថានទូតឲ្យក្រុមរបស់ ម៉ាន ធ្វើជាទីបញ្ជាការដ្ឋានកងទ័ព ។ ម៉ានបានទទួលភារកិច្ចជាកងសន្តិសុខក្រុងភ្នំពេញ ។ នៅឆ្នាំ១៩៧៦ ម៉ាន ត្រូវបានចាត់តាំងឲ្យធ្វើការនៅកំពង់សោម ជាអ្នកទទួលភ្ញៀវចិននិងជាអ្នកត្រួតពិនិត្យនិងកត់ត្រាមុខទំនិញនៅកំពង់ផែកំពង់សោម ដែលចិនបាននាំចូលមកឲ្យកម្ពុជាតាមនាវា ។ ម៉ាន បានឃើញនាវាពាណិជ្ជសមុទ្ររបស់ចិន និងនាវាពាណិជ្ជខ្មៅមួយរបស់កូរ៉េដែលចតនៅកំពង់ផែជានិច្ចកាល ។ នាវាទាំងនេះតែងផ្លាស់ប្តូរគ្នានៅពេលដែលនាវាថ្មីបានមកដល់ ។ ម៉ាន ជាអ្នកត្រួតពិនិត្យទំនិញដែលនាំចូលដោយកប៉ាល់ចិន ។ ម៉ាន សម្គាល់ឃើញភាគច្រើនគឺជាគ្រឿងយន្ត ប្រេង ខោអាវ និងកេសបិទជិតៗ ។

ក្រោយមកទៀត ម៉ាន មានភារកិច្ចមកជាអ្នកអមដំណើរចិនបីនាក់ដែលជាគ្រូបង្ហាត់ក្បាច់យុទ្ធសាស្ត្រកងទ័ពនៅកំពង់សោម (ក្រុងព្រះសីហនុ) ។ ម៉ាន បានរៀបរាប់ថា “គេដកខ្ញុំពីទទួលភ្ញៀវចិននិងពិនិត្យទំនិញឲ្យមកនៅលើភ្នំត្រង់រោងចក្របីយែរ ហើយក៏មានចិននៅត្រង់នោះដែរ ។ ចិនវាមានស្គាល់អ្នកណា វាស្គាល់តែខ្ញុំ ព្រោះធ្លាប់ទាក់ទងគ្នានៅលើកប៉ាល់ ដល់ពេលចិនមកបង្ហាត់ក្បួនយុទ្ធសាស្ត្រ ត្រង់ហ្នុងវាក៏ដកខ្ញុំមកដែរ” ។ ម៉ាន បានបន្ត



ទៀតថា "ចិនមានគ្នាបីនាក់ (ប្រុសពីរនាក់ ស្រីម្នាក់ និងមានអ្នកបកប្រែម្នាក់ឈ្មោះ ចៀវ និងមានខ្ញុំម្នាក់ជាអមដំណើរចិន) ។ តាមការអះអាងរបស់ ម៉ាន ថា អ្នកមានឋានៈចាប់ពីប្រធានកងអនុសេនាតូចឡើងទើបមានសិទ្ធិទទួលការបង្ហាត់ផ្ទាល់ពីគ្រូជនជាតិចិន ។ អ្នកដែលមកហ្វឹកហាត់មានកម្លាំងទាហានមកពីភូមិភាគនិរតី និងភូមិភាគឧត្តរចម្រុះគ្នា ។ ក្រោយមកមេទាហានទាំងនោះបានរៀនចប់និងចេះក្បាច់យុទ្ធសាស្ត្រហើយ ទើបអាចបង្ហាត់កូនទាហានរបស់ខ្លួននៅតាមអង្គភាព ។ ម៉ាន បានគូសបញ្ជាក់ថា "មុននឹងមកបង្ហាត់ទាហាន គឺហាត់ជាមួយចិនយូរណាស់ប្រហែលជា២-៣ខែ ហាត់ផង រៀនផង (គេហៅថារៀននយោបាយ) ។ ដល់យើងហាត់រៀនចេះហើយ បានចិនហៅយើងប្រជុំបើកវគ្គ ហើយចិនហៅយើងទៅបង្ហាត់កូនទាហាន ដល់បង្ហាត់ឲ្យធ្វើរោងដូចជារោងសហករណ៍ដែលមានទាហានរាប់រយនាក់មកពីវរៈពិសេសនៃកងពលរបស់ឈ្មោះ អឿន នៃភូមិភាគឧត្តរ និងកងពលមួយទៀតមកពីភូមិភាគនិរតី ។ នៅពេលដែលយើងបង្ហាត់ ចិនគ្រាន់តែឈរមើលប្រាប់ពីទ្រឹស្តី ប៉ុន្តែខ្មែរយើងទេជាអ្នកបង្ហាត់ ហើយចិនជាអ្នកដើរមើលប្រាប់បច្ចេកទេស ។ ក្បាច់នោះគឺក្បាច់ចិនតែម្តង ហាត់ក៏ក្បាច់ចិន ក្បាច់គុនក៏ក្បាច់គុនចិន" ។

នៅឆ្នាំ១៩៧៧ ម៉ាន ត្រូវបក្សបញ្ជូនមកភ្នំពេញមកអមដំណើរវិស្វករចិនក្នុងការដើរត្រួតពិនិត្យការដ្ឋានទំនប់ប្រឡាយសំណង់ទូទាំងប្រទេសកម្ពុជា ។ ម៉ាន នៅចាំបានថា វិស្វករចិននោះមានឈ្មោះថា វ៉ុង ដែលធ្លាប់បានស្គាល់គ្នាតាំងពីនៅកំពង់សោម ។ ពេលធ្វើដំណើរទៅត្រួតពិនិត្យការដ្ឋាននៅកន្លែងណាក៏ដោយគឺត្រូវតែវិលត្រឡប់មកភ្នំពេញវិញ (នេះគឺគោលការណ៍របស់វ៉ុង) ។ ម៉ាន បានរៀបរាប់ដំណើររឿងនោះថា "វ៉ុង បានឲ្យខោអាវចិនមួយកំប្លេមានតាំងពីផ្លាកសញ្ញាដូចគ្នា ។ រយៈពេលប្រហែលបីខែ ខ្ញុំនិង វ៉ុង ដើរមើលទំនប់អាងទឹកច្រើនកន្លែងណាស់ យើងបានទៅទំនប់បឹងក្រចាប់ក្នុងខេត្តកំពង់ចាម ទំនប់៦មករា ក្នុងខេត្តកំពង់ធំ និងទំនប់ជាច្រើនទៀតនៅក្នុងខេត្តតាកែវ ខេត្តកណ្តាល ។ នៅពេលទៅមើលការដ្ឋានម្តងៗមានទាហានចិន៥នាក់និងកងទ័ពខ្មែរចំនួនពីររថយន្តធំៗ អមដំណើរខ្ញុំនិង វ៉ុង ។ ទាហានចិនក៏មានកាំភ្លើងគ្រប់ដៃ ហើយជិះរថយន្តហ្ស៊ីបមួយបើកពីក្រោយរថយន្តដែលខ្ញុំជិះ ។ រថយន្តដែលខ្ញុំជិះជារថយន្តហ្ស៊ីបដូចគ្នាដែរ ហើយនៅលើរថយន្តនេះមាន វ៉ុង អ្នកបកប្រែម្នាក់, អ្នកបើកបរម្នាក់និងខ្ញុំ ។ រថយន្តកងទ័ពខ្មែរដែលជិះនោះជារថយន្តមកពីចិនដែរតែធំៗ បានបើកនាំមុខមួយ និងនៅក្រោយបង្អស់មួយ ។ ពេលទៅដល់ការដ្ឋាន អ្នកធ្វើការធ្វើដូចធម្មតា មានប្រធានៗមកគោរពហើយចាប់ដៃខ្ញុំ ។ ខ្ញុំឃើញ វ៉ុង សួរនាំប្រធានៗ ហើយមានសៀវភៅកត់ត្រាមួយនៅកន្លែងខ្លះ ដូចជាទំនប់៦មករា ចិនស្តីឲ្យប្រធាននោះខ្លាំងមែនទែន ព្រោះធ្វើអត់ត្រូវតាមបច្ចេកទេស" ។ ម៉ាន បានរៀបរាប់ថា "ខ្លួនមិនបានចាប់អារម្មណ៍ថាប្រជាជនក្នុងពេលនោះពិបាកយ៉ាងម៉េចទេ ព្រោះខ្លួនឯងមិនដែលពិបាកអ្វីសោះ ។ នៅពេលដែលទៅមើលការដ្ឋាន ម៉ាននិងវ៉ុង បានផឹកទឹកដូងរួចចោលសាច់នៅនឹងមុខ ហើយមិនដែលបានឃើញពួកអ្នកធ្វើការនោះរើសយកស៊ីទេ ។ ម្យ៉ាង ម៉ាន ក៏មិនដែលបានចុះជួបគេផ្ទាល់ បានត្រឹមតែចុះពីលើរថយន្តជួបប្រធានការដ្ឋាន ហើយក៏ឡើងឡានត្រឡប់មកភ្នំពេញវិញ" ។ ចុងក្រោយ ម៉ាន ក៏បានរំឭកពីការសង្ស័យរបស់ខ្លួនមួយថា "មានរឿងមួយចម្លែក គឺខ្ញុំសុំមកលេងផ្ទះ ខ្ញុំបានទៅសុំដល់ប្រធានកងពលរបស់ខ្ញុំឈ្មោះ អឿន តែគាត់ប្រាប់ថាចាំមួយរយៈទៀត ហើយក្រោយមកខ្ញុំទៅសុំទៀត គាត់ចេះតែថាចាំមួយរយៈៗរហូត" ។

ម៉ាន និង វ៉ុង បានដើរត្រួតពិនិត្យការដ្ឋានបានរយៈពេលប្រហែលបីខែ ។ ថ្នាក់លើរបស់ វ៉ុង បានតម្រូវឲ្យ វ៉ុង បង្ហាត់កងទ័ពនៅភ្នំពេញវិញម្តង ។ ម៉ាន ក៏ចុះជាប់ជាមួយ វ៉ុង នៅក្នុងភារកិច្ចបង្ហាត់ទាហាននោះដែរ ។ ដូចនៅកំពង់សោមដែរ មានតែអ្នកដែលមានឋានៈចាប់ពីប្រធានអនុសេនាតូចឡើង ទើប វ៉ុង ជ្រើសរើសយកបង្ហាត់ ។ ម៉ាន បានឲ្យដឹងថា មានកងទ័ពខ្លះដែលបានហាត់ជាមួយ វ៉ុង នៅភ្នំពេញក៏ធ្លាប់បានហាត់ជាមួយចិនបីនាក់នៅកំពង់សោមដែរ ។ មានមេទាហានមួយចំនួនត្រូវបានមកពីខេត្តផ្សេងៗ ។ ម៉ាន បានរំឭកថា "វ៉ុង បង្ហាត់នៅភ្នំពេញនៅក្រោយទូតបារាំង(សព្វថ្ងៃនេះ) និងនៅចំហៀងស្តាតចាស់ ។ ក្បាច់របស់ វ៉ុង ដូចគ្នានឹងក្បាច់របស់ចិននៅកំពង់សោមដែរ ។ ម៉ាន បាននិយាយថា ក្នុងពេលហាត់ ខ្ញុំមានសិទ្ធិឈរមើលដើម្បី

ជួយប្រាប់បច្ចេកទេស ។ ប្រហែល១០ថ្ងៃ មេបញ្ជាការកងពល ឈ្មោះ អឿន ប្រាប់ខ្ញុំថា ខ្ញុំចេះក្បាច់គុនហើយ រួច អឿន បញ្ជូនខ្ញុំទៅត្រួតពិនិត្យការដ្ឋានធ្វើព្រលានយន្តហោះយោធានៅកំពង់ឆ្នាំង»ម្តង ។

នៅក្នុងឆ្នាំ១៩៧៨ ម៉ាន ត្រូវបានចាត់តាំងឲ្យត្រួតមើលការដ្ឋានធ្វើព្រលានយន្តហោះយោធាដែលមានទីតាំងហួសពីទីរួមខេត្តកំពង់ឆ្នាំងបន្តិច ។ ម៉ាន នៅចាំបានថាទីនោះហៅថាភូមិពង្រ ។ សព្វថ្ងៃនេះគឺឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ពេលទៅដល់ទីនោះ ម៉ាន បានឃើញព្រលានយន្តហោះនោះបានសាងសង់រួចពាក់កណ្តាលរួចទៅហើយ ។ ម៉ាន ក៏បានជួបជាមួយជនជាតិចិនប្រមាណជា៥០នាក់ដែលជាអ្នកបច្ចេកទេសធ្វើព្រលានយន្តហោះ ។ គាត់បានចូលរួមប្រជុំជាមួយជនជាតិចិនទាំងនោះ ។ ម៉ាន បានរំឭកសម្តីរបស់ចិនដែលបានណែនាំថា “ព្រលានយន្តហោះនៅកម្ពុជាមានពីរគឺ ព្រលានយន្តហោះនៅពោធិចិនតុងសម្រាប់ចតយន្តហោះស៊ីវិល ចំណែកព្រលានយន្តហោះនៅកំពង់ឆ្នាំងសម្រាប់ដាក់យន្តហោះយោធា ។ ចិនប្រាប់ ម៉ាន ថា កាលណាធ្វើព្រលានយន្តហោះរួចស្រេចហើយនឹងធ្វើរូងសម្ងាត់ដែលនៅជាប់ព្រលានយន្តហោះនេះសម្រាប់ដាក់យន្តហោះចម្បាំងនៅក្នុងរូង (ពេលដែលចិនផ្តល់ឲ្យកម្ពុជា) ។ អ្នកដែលបានហាត់ក្បាច់គុននឹងយកមកឲ្យប្រើប្រាស់យន្តហោះ និងការពារព្រលានយន្តហោះនោះ» ។ ម៉ាន បន្តទៀតថា “ខ្ញុំនៅកន្លែងនោះជាអ្នកទាក់ទងជាមួយចិនផ្ទាល់ដូចថាខ្មែរយើងត្រូវការអី ហើយខ្វះអីមួយខាងខ្មែរមកប្រាប់ខ្ញុំ ហើយខ្ញុំទៅប្រាប់ចិនដែលមានអ្នកបកប្រែឲ្យ” ។ ម៉ាន ក៏បានឲ្យដឹងដែរថា គ្រឿងយន្តដែលបានប្រើប្រាស់ក្នុងការកសាងសង់ព្រលានយន្តហោះនេះ សុទ្ធតែនាំចូលពីប្រទេសចិនតាមច្រកកំពង់ផែកំពង់សោម ដែលខ្លួននៅចំណាំបានថាធ្លាប់បានឃើញគ្រឿងយន្តទាំងនោះនៅពេលធ្វើការជាអ្នកត្រួតពិនិត្យទំនិញក្នុងឆ្នាំ១៩៧៦ ។

ពីរបីខែក្រោយមកទៀត ម៉ាន បានជួប វ៉ុង ដែលធ្វើដំណើរពីភ្នំពេញឆ្ពោះទៅការដ្ឋានព្រលានយន្តហោះនោះដែរ ។ វ៉ុង ទទួលភារកិច្ចជាអ្នកសាងសង់ផ្ទះថ្មនៅត្រង់ភ្នំនោះ និងជាអ្នកខួងភ្នំធ្វើរូងសម្ងាត់មួយដែលគាត់ធ្លាប់បានប្រាប់ ម៉ាន កាលពីថ្ងៃមុន ។ ម៉ាន បាននិយាយថា “ភ្នំនៅត្រង់នោះមានពីរមិនដឹងជាគេហៅភ្នំអីទេ ដែលស្ថិតនៅហួសពីទីរួមខេត្តកំពង់ឆ្នាំងបន្តិចត្រង់នោះគេហៅថាភូមិពង្រ ។ ភ្នំទី១ វ៉ុង បានសង់ផ្ទះថ្ម និងបំពាក់វ៉ាដា ហើយភ្នំទី២ជាភ្នំដែលនឹងគ្រោងថាចោះធ្វើរូងសម្ងាត់ ។ វ៉ុង បានវាស់វែងភ្នំដែលត្រូវធ្វើរូងនោះរួចទៅហើយ ហើយបានចោះទម្លុះទៅខាងមុខបន្តិច” ។

ចុងឆ្នាំ១៩៧៨ ការដ្ឋានសាងសង់ព្រលានយន្តហោះជិតត្រូវបានបញ្ចប់សព្វគ្រប់ ដំណើរការខួងភ្នំធ្វើរូងក៏បានចាប់ផ្តើមឡើង ប៉ុន្តែសកម្មភាពទាំងនោះត្រូវបានគាំងលែងដំណើរការទៅវិញ នៅពេលដែលរបបខ្មែរក្រហមបរាជ័យនៅដើមឆ្នាំ១៩៧៩ ។

សព្វថ្ងៃ ម៉ាន រស់នៅក្នុងភូមិមួយស្ថិតក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។ នៅមុនសម័យខ្មែរក្រហម ម៉ាន រស់នៅក្នុងភូមិមាយ ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ នៅឆ្នាំ១៩៧០ ពេលដែល ម៉ាន អាយុបាន១៨ឆ្នាំ មិត្តភក្តិពីរនាក់ឈ្មោះម៉ៅ និង រួន បានមកបបួល ម៉ាន ឲ្យចូលធ្វើកងទ័ពនៅក្នុងភាគីរណសិរ្សរំដោះជាតិ ។ ដោយឮមិត្តភក្តិទាំងពីរនិយាយថាធ្វើកងទ័ពសប្បាយ ម៉ាន ក៏ស្ម័គ្រចិត្តចូលធ្វើកងទ័ពជាមួយមិត្តភក្តិនៅភូមិសូភាស ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដែលជាមូលដ្ឋានកាន់កាប់ដោយរណសិរ្សរំដោះជាតិ ។ ពេលទៅដល់ដំបូង អ្នកជ្រើសរើសទាហាននោះបានសួរ ម៉ាន ថា “ប្អូនឯងឈឺចាប់ឬបានជាមកធ្វើកងទ័ព?» គាត់បានឆ្លើយថា “ខ្ញុំឈឺចាប់” ។ តា សក់ ជាប្រធានកងអនុសេនាធំទី៣នៃកងពលរបស់ឈ្មោះហេង បានរើសយក ម៉ាន ឲ្យធ្វើជានិរសាររបស់គាត់ ។

ដោយភាពក្លាហានរបស់ ម៉ាន ក្នុងការបំពេញភារកិច្ចនិរសាររបស់ តាសក់ បន្ទាប់ពីនោះមក ម៉ាន ត្រូវបានបញ្ជូនមកសមរភូមិនៅជាយក្រុងភ្នំពេញ ហើយត្រូវបានប្រគល់តួនាទីជាប្រធានកងអនុសេនាធំលេខ២ នៅក្នុងកងពលរបស់ឈ្មោះអឿន ។ នៅក្នុងការប្រយុទ្ធដ៏ក្តៅគគុកដណ្តើមយកទីក្រុងភ្នំពេញពីរបបសាធារណរដ្ឋខ្មែរ ម៉ាន ស៊ិតស្វាញនៅក្នុងការបញ្ជាកូនទាហានរបស់គាត់នៅទីតាំងសមរភូមិភ្នំប្រសិទ្ធិប៉ែកខាងលិចក្រុងភ្នំពេញ រហូតបានទទួលជោគជ័យនៅក្នុងការរំកិលខ្លួនចូលមកកាន់កាប់ទីក្រុងទាំងមូល ។

**អ៊ីសា ឧស្មាន**

# អាពាហ៍ពិពាហ៍ខ្មែរក្រហម

អាពាហ៍ពិពាហ៍ដែលរៀបចំឡើងដោយបក្សកុម្មុយនិស្តកម្ពុជាមានលក្ខណៈខុសប្លែកពីអាពាហ៍ពិពាហ៍តាមបែបប្រពៃណីដូនតាខ្មែរ ។ កូនក្រមុំនិងកូនកម្លោះត្រូវតម្រូវឲ្យរៀបការទាំងរាងកាយស្គាំងស្គម ល្ហិតល្ហៃ ដោយការទទួលទានអាហារមិនគ្រប់គ្រាន់និងការងាររហូសកម្លាំង ។ យុវជននិងយុវនារីត្រូវឈរតម្រៀបជួរម្ខាងម្នាក់ដើម្បីត្រៀមខ្លួនទទួលយកគូអនាគតដែលអង្គការរៀបចំទុកដាក់ឲ្យ ។

អាពាហ៍ពិពាហ៍ខ្មែរក្រហមត្រូវបានធ្វើឡើងមិនឲ្យសាមីខ្លួនដឹងមុន សូម្បីតែឈ្មោះឬមុខមាត់នៃអនាគតប្តីឬប្រពន្ធក៏មិនស្គាល់ដែរ ។ ឪពុកម្តាយបងប្អូនបង្កើតនិងមិត្តភក្តិក៏មិនបានមកចូលរួមអបអរសាទរដែរ ដោយហេតុថា ខ្មែរក្រហមឲ្យប្រជាជនទាំងអស់ចាត់ទុកអង្គការគឺជាឪពុកម្តាយ ។

អាពាហ៍ពិពាហ៍រៀបចំឡើងដោយមានកូនកម្លោះនិងកូនក្រមុំច្រើនគូ ហើយគ្មានប្រារព្ធពិធីតាមប្រពៃណីខ្មែរទេ ។ មានករណីជាចាំបាច់មួយទៀតត្រូវបានអនុវត្តជាទូទៅ ចំពោះប្រជាជនធម្មតានិងកម្មាភិបាលខ្មែរក្រហម គឺការជ្រើសរើសយកប្រវត្តិរូបដូចគ្នានៅក្នុងវណ្ណៈទាំងបីគឺ វណ្ណៈកណ្តាលថ្នាក់លើ កណ្តាលថ្នាក់កណ្តាលនិងកណ្តាលថ្នាក់ក្រោម មានន័យថាស្វាមីភរិយានៃគូនីមួយៗត្រូវស្ថិតនៅក្នុងវណ្ណៈតែមួយដូចគ្នា ដើម្បីឲ្យមានកំហិងវណ្ណៈស្មើគ្នា ។ លោកពូ អ៊ុំ ឈាវ និងអ្នកមីង ចាន់ ថន អតីតកម្មាភិបាលខ្មែរក្រហមបច្ចុប្បន្នរស់នៅភូមិពាមប្រជុំ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល គាត់ទាំងពីរគឺជាគូស្វាមីភរិយាដែលបក្សកុម្មុយនិស្តកម្ពុជារៀបចំឲ្យនៅក្នុងឆ្នាំ១៩៧៧ នៅបឹងជើងឯក ។ អ្នកមីង ចាន់ ថន បានបញ្ជាក់ថា គាត់ពុំដែល


អ៊ុំ ឈាវ និងភរិយា ដែលបានរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ស្គាល់ហើយក៏ពុំបានដឹងថាតើនរណានឹងក្លាយជាគូអនាគតរបស់គាត់ឡើយ «នៅពេលឡើងទៅអង្គុយកៅអីជិតរៀបការហើយ ហ្នឹងក៏អត់ស្គាល់គ្នាដែរ» ។ មីង ចាន់ ថន ប្រាប់ទៀតថា បើគាត់មិនព្រមតាមអង្គការគាត់ប្រហែលជាត្រូវយកទៅសម្លាប់ចោលហើយ ព្រោះរឿងរៀបចំគ្រួសារបើខុសតែបន្តិចក៏សម្លាប់ចោល ។ លោកតា អ៊ុំ ឈាវ បានបន្ថែមថា «ខ្ញុំនឹកឃើញថារៀបការអត់មានឪពុកម្តាយចិត្តអត់ចង់យកសោះ អត់មាននឹកឃើញថាស្រឡាញ់គ្រួសារអីទេ ព្រោះអានេះវាអត់មានម៉ែឪបងប្អូនដឹងឮទទួលស្គាល់ ។ មីង អ៊ុន ទឹម នៅភូមិអន្លង់រមៀតបានបញ្ជាក់ថាៈ នៅពេលរៀបអាពាហ៍ពិពាហ៍ខ្មែរក្រហមតែងប្រកាសថា«ឪពុកម្តាយរបស់មិត្តមិនមកចូលរួមពិធីនេះទេ ។ យើងជាឪពុកម្តាយជំនួសឲ្យមិត្តនិងបងប្អូនប្រុសស្រីរបស់មិត្តទាំងអស់គ្នា» ។ ក្នុងឆ្នាំ១៩៧៨ អ្នកមីង អ៊ុន ទឹម រស់នៅភូមិអន្លង់រមៀតធ្លាប់រៀបការក្នុងគូអាពាហ៍ពិពាហ៍ដែលមានចំនួនរហូតដល់ទៅ ១៦០គូ ។

លោក គង់ ឈុន អតីតកម្មាភិបាលខ្មែរក្រហមនៅភូមិក្បាលកោះគេរ ឃុំកោះខ្សាច់ជន្លា ស្រុកស្អាង ខេត្តកណ្តាល ដែលធ្លាប់បានចូលរួមរៀបចំចាត់ចែងក្នុងពិធី បានឲ្យដឹងថាៈ អាពាហ៍ពិពាហ៍បានសម្រេចចប់សព្វគ្រប់និងពេញច្បាប់ដោយគ្រាន់តែប្រកាសថា «មនុស្សទាំងពីរនាក់នេះគឺជាប្តីប្រពន្ធនឹងគ្នា ត្រូវស្រឡាញ់គ្នាទៅវិញទៅមកអស់មួយជីវិត ត្រូវស្គាល់គ្នាទៅវិញទៅមក» ។

ប្រជាជនជាច្រើនសុទ្ធតែធ្លាប់បានឆ្លងកាត់នូវអាពាហ៍ពិពាហ៍ចាប់បង្ខំទាំងសាមីខ្លួនមិនពេញចិត្ត ។ មានតែកម្មាភិបាលនិងប្រជាជនមូលដ្ឋានមួយចំនួនតូច(ព្រោះអង្គការចាត់ទុកជាជនដាច់ខាតនឹងបដិវត្តន៍)ប៉ុណ្ណោះ ដែលមានសិទ្ធិប្រកែកតវ៉ាមិនព្រមរៀបការនៅពេលដែលខ្លួនមិនពេញចិត្តមានសិទ្ធិស្នើអង្គការរៀបការជាមួយអ្នកដែលខ្លួនស្រឡាញ់ឬក៏រៀបការក្នុងពិធីគ្រាន់បើជាងប្រជាជនធម្មតា គឺមានគូអាពាហ៍ពិពាហ៍ក្នុងចំនួនតិច មានចែកសម្ភារប្រើប្រាស់ដូចជាខោអាវ មុង ភួយ កន្ទេល ខ្នើយ និងចែកផ្ទះឲ្យនៅ ។

លោកតា គូ សៀម អតីតកម្មាភិបាលខ្មែរក្រហមសព្វថ្ងៃរស់នៅភូមិមឿងចារ ឃុំដាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។ កាលណោះគាត់មានតួនាទីជាប្រធានក្រុមនៅភូមិព្រៃល្វា ហើយបានស្នើសុំអង្គការដើម្បីរៀបការជាមួយកម្មាភិបាលពេទ្យម្នាក់ ។គូ សៀម បានបញ្ជាក់ទៀតថា នៅក្នុងឆ្នាំ១៩៧៧ នៅពេលដែលគាត់រៀបការនោះ មានគូស្វាមីភរិយា៣គូប៉ុណ្ណោះតាមការជ្រើសរើសយកប្រវត្តិរូបឲ្យត្រូវគ្នា ។ នៅពេលនោះគាត់ស្ថិតក្នុងវណ្ណៈកណ្តាលថ្នាក់ក្រោម ។


គូ សៀម


ដាន់ ចន្ទា

អ្នកមីង ដាន់ ចន្ទា អតីតកម្មាភិបាលពេទ្យ នៅស្រុកត្រាំកក់ ខេត្តតាកែវ បានអះអាងថា គាត់ធ្លាប់បានប្រកែកមិនព្រមរៀបការតាមការស្នើសុំរបស់អង្គការចំនួន២ឬ៣ដងដោយគ្មានទោសពៃរ៍អ្វីឡើយ លុះក្រោយមកទើបគាត់យល់ព្រមរៀបការជាមួយយុទ្ធជនបើកបរយន្តម្នាក់ ហើយរស់នៅជាមួយគ្នារហូតដល់សព្វថ្ងៃនេះ ។

លោក រៀល សន អតីតលេខាពេទ្យស្រុកត្រាំកក់ បានប្រាប់ថា នៅកន្លែងរបស់គាត់(មន្ទីរពេទ្យស្រុកត្រាំកក់)ក្នុងពេលរៀបការឬកសាងគ្រួសារឲ្យកម្មាភិបាលពេទ្យ គាត់តែងឲ្យប្រជាជនធ្វើនំបារាំង កាប់ជ្រូក ដើម្បីជប់លៀង ព្រមទាំងចែកផ្ទះថ្មីឲ្យនៅក្រោមមន្ទីរពេទ្យទៀតផង ។

ហេតុអ្វីបានជាខ្មែរក្រហមលុបបំបាត់ប្រពៃណីក្នុងការរៀបអាពាហ៍ពិពាហ៍របស់ខ្មែរ ហើយប្រែក្លាយរូបភាពនៃអាពាហ៍ពិពាហ៍ដោយការជ្រើសរើសយកវណ្ណៈដូចគ្នាចាប់ដៃគ្នាច្រើនគូទៅវិញ?

អង្គការបានបំពាក់មនោគមវិជ្ជាដល់យុវជន-យុវនារីស្តីពីលោកទស្សនៈបដិវត្តន៍ ចំពោះបញ្ហាកសាងគ្រួសារ ខ្មែរក្រហមបាន

រិះគន់និងបង្ហាញនូវការមិនពេញចិត្តចំពោះរបៀបរបបនៃការកសាងគ្រួសារនាសម័យមុនៗ ហើយចាត់ទុកថាជាការកសាងគ្រួសារបែបចក្រពត្តិ សក្តិភូមិ នាយទុនៗ នៅក្នុងសៀវភៅកំណត់ហេតុសិក្សាពី «លោកទស្សនៈបដិវត្តន៍និងមិនបដិវត្តន៍ចំពោះបញ្ហាកសាងគ្រួសារ» របស់កម្មាភិបាលខ្មែរក្រហមមួយរូប (មិនស្គាល់ឈ្មោះ) បានបង្ហាញថា ការរៀបចំគ្រួសារបែបនោះគឺដើម្បីអូសទាញពីវណ្ណៈមួយទៅវណ្ណៈមួយទៀត ឬដើម្បីទាញយកផលប្រយោជន៍ ពីគ្នាទៅវិញទៅមក ដោយលើកឧទាហរណ៍ថា«បើបុរសគេរកប្រពន្ធដែលមានសម្បត្តិល្អ ជាកូនមានទ្រព្យសម្បត្តិស្តុកស្តម្ភ ឬជាកូនអ្នកមានឬអ្នកមានបណ្តាស័ក្តិខ្ពង់ខ្ពស់ ដើម្បីឲ្យខ្លួនគេឡើងជាអ្នកមាន ឬមានបុណ្យស័ក្តិទៅតាមឪពុកឬម្តាយក្មេក ។ បើឪពុកម្តាយនារីវិញ គឺសម្លឹងរកតែអ្នកមានទ្រព្យសម្បត្តិ ឬអ្នកមានបុណ្យស័ក្តិ ដើម្បីឲ្យកូនបានស្រណុកសុខស្រួល ទោះជាគ្រួសារអាវ៉ាសែឬមានប្រវត្តិក្បត់ជាតិក៏ដោយ» ។

អាស្រ័យហេតុនេះហើយទើបខ្មែរក្រហមអនុវត្តនូវការជ្រើសរើសប្រវត្តិរូបបុរស-នារីមុននឹងចាប់បង្ខំឲ្យរៀបការ ។

នៅក្នុងសេចក្តីរាយការណ៍អំពីការស៊ើបអង្កេតស្តីពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលបានធ្វើឡើងដោយរដ្ឋកម្ពុជា បានបង្ហាញនូវមូលហេតុពីរយ៉ាងដែលនាំឲ្យមានអាពាហ៍ពិពាហ៍ដោយបង្ខំនិងដាក់កំហិតឲ្យអនុវត្តឡើងទូទាំងប្រទេសគឺ ១) ខ្មែរក្រហមស្អប់នារីស្អាតៗ ២) ខ្មែរក្រហមប្រឆាំងនឹងទំនៀមទម្លាប់នៃអរិយធម៌ជាទូទៅ ជាពិសេសអរិយធម៌នៃប្រជាជាតិខ្មែរតែម្តង ។ អាស្រ័យហេតុនេះទើបបានជាខ្មែរក្រហមច្រើនតែបង្ខំឲ្យយុវនារីដែលមានរូបសម្ផស្សស្អាតៗ ចរិតឆ្នើមឆ្នៃ ដែលកម្រនឹងបែចង់បាននោះរៀបការជាមួយយោធាពិការ កំបុតជើង ខ្វាក់ភ្នែកម្ខាង និងមានរូបរាងអាក្រក់ក្រៃលែង ។ ករណីបែបនេះមានជាញឹកញាប់ណាស់ច្រើនតែបានទទួលបរាជ័យ ដូចជាការធ្វើអត្តឃាត និងពលិកម្មផ្សេងៗ ព្រោះតែខ្លួនគ្មានសិទ្ធិនឹងតវ៉ា ។ កញ្ញា ងួន សុភាព ធ្វើការនៅក្រសួងឃោសនាការពត៌មាននិងវប្បធម៌បានបញ្ជាក់ថា: បងស្រីរបស់ខ្លួនបានធ្វើអត្តឃាតដោយការមិនពេញចិត្តនឹងអាពាហ៍ពិពាហ៍ចាប់បង្ខំរបស់អង្គការដែលឲ្យគាត់រៀបការជាមួយកម្មាភិបាលខ្មែរក្រហមម្នាក់ដែលគាត់មិនស្រឡាញ់ ។

អ៊ឹំស្រី ស៊ាយ យិន រស់នៅភូមិសំប៉ានលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាលបានឲ្យដឹងថា នៅលើកោះខ្សាច់ជន្លា ខ្មែរក្រហមបានបង្ខំឲ្យនារីរៀបការជាមួយយុទ្ធជនពិការដោយមិនអាចប្រកែកបានឡើយ ។ ក្រោយពីរៀបការរួចមានកងឈ្លបដើរស៊ើបការណ៍ពីក្រោមផ្ទះនៅពេលយប់ទៀតផង ដើម្បីឲ្យដឹងថាអ្នកទាំងពីរស្រឡាញ់តាមការរៀបចំទុកដាក់របស់អង្គការដែរឬទេ ។

ក្នុងករណីខ្លះ ការមិនយល់ព្រមឬប្រឆាំងមិនរៀបអាពាហ៍ពិពាហ៍តាមការស្នើរបស់អង្គការ ត្រូវបានចាត់ទុកថា«ក្បត់អង្គការ» ហើយនឹងត្រូវទទួលទណ្ឌកម្ម ចាប់ឃុំឃាំង ឬក៏អាចមានគ្រោះថ្នាក់ដល់អាយុជីវិតថែមទៀតផង ។ នៅក្នុង១៩៧៧ អ្នកមីង នួន ថុក អតីតកម្មាភិបាលបម្រើក្នុងជួរខ្មែរក្រហមត្រូវបានបង្ខំឲ្យរៀបការជាមួយយុទ្ធជនពិការ ប៉ុន្តែគាត់បានបដិសេធមិនព្រមទទួលយកយុទ្ធជនពិការរូបនោះធ្វើជាគូអនាគតទេ ។ កម្មាភិបាលខ្មែរក្រហមបានចាប់គាត់ដាក់ក្នុងមន្ទីរឃុំឃាំងខេត្តសៀមរាបអំពីទោសមិនគោរពវិន័យអង្គការ ។ មីង ដៃ វ៉ែន នៅភូមិធ្លក ធ្លាប់បានបដិសេធមិនព្រមរៀបការជាមួយបុរសចំណាស់ម្នាក់ អង្គការខ្មែរក្រហមចាប់គាត់ចងស្លាបសេក រួចបញ្ជូនមកគុកភ្នំកូនខ្លែងដើម្បីសួរចម្លើយនិងបង្ខំធ្វើការជាទម្ងន់ ។

ទោះបីជាការរៀបចំអាពាហ៍ពិពាហ៍របស់ប្រជាជនសាមញ្ញនិងកម្មាភិបាលខ្មែរក្រហមមានលក្ខណៈខុសគ្នាខ្លះក៏ដោយ ស្ថានភាពក្រោយពេលរៀបការក៏មានលក្ខណៈស្រដៀងគ្នាខ្លះដែរគឺក្រោយពេលរៀបការបានពីរឬបីថ្ងៃគូស្វាមីភរិយាត្រូវតែរស់នៅបែកគ្នាទៅបម្រើការងាររបស់អង្គការយូរៗទើបអាចជួបមុខគ្នាម្តង ។ អ្នកមីងក៏បានលើកជាគំរូខ្លួនគាត់ថា ក្នុងរយៈពេល១០ថ្ងៃទើបគាត់បានជួបមុខប្តីគាត់ម្តង នេះដោយសារតែប្តីរបស់គាត់ជាអ្នកបើករថយន្តឲ្យពួកខ្មែរក្រហមនៅតាមតំបន់ឆ្ងាយៗ ។

អាពាហ៍ពិពាហ៍ក្រោមរបបខ្មែរក្រហមនេះបានធ្វើឲ្យ មីង ហ៊ាង ប៊ុនណា នៅភូមិដីឆ្នង នៅតែឆ្ងល់ ហើយចោទជាសំណួរថាហេតុអ្វីខ្មែរក្រហមចាំបាច់បង្ខំឲ្យប្រជាជនរៀបការ? បើក្រោយពីរៀបការ គូស្វាមីភរិយាអាចរស់នៅជួបមុខគ្នាបានតែមួយយប់ប៉ុណ្ណោះ ហើយក្រោយពីនោះត្រូវរស់នៅបែកគ្នា ។

**ហ៊ុយ ឆេងរតនា**

# ការកាត់ទោសប្រហារជីវិតដោយពុំមានការជំនុំជម្រះក្តីត្រឹមត្រូវ

គេមិនអាចប្រកែកបានទេថា ការហាមប្រាមប្រឆាំងនឹងការកាត់ទោសប្រហារជីវិតដោយពុំមានការជំនុំជម្រះក្តីត្រឹមត្រូវ គឺជាបទដ្ឋានដាច់ខាត ។ ធម្មនុញ្ញតុលាការយោធាអន្តរជាតិកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចខាងក្រោម÷ “អំពើមនុស្សឃាត ការសម្លាប់ផុតពូជ ការនិរទេស និងអំពើផ្សេងទៀតដែលប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិល មុនឬអំឡុងពេលសង្រ្គាម ឬការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ សាសនា ក្នុងសមត្ថកិច្ច ឬមានទាក់ទងទៅនឹងឧក្រិដ្ឋកម្មក្នុងដែនសមត្ថកិច្ចរបស់តុលាការ” ។ ការហាមប្រាមដូចគ្នានេះមាននៅក្នុងមាត្រា៣នៃអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៤៩: “ទោះបីជាក្នុងកាលៈទេសៈណាក៏ដោយរាល់អំពើទាំងឡាយណាដែលត្រូវបានហាមឃាត់ខាងលើជាអំពើហិង្សាមកលើមនុស្សនិងការធ្វើឲ្យបាត់បង់ជីវិត ជាពិសេសគឺការសម្លាប់មនុស្សគ្រប់រូបភាពទាំងអស់ ហើយនិងការកាត់ទោសប្រហារជីវិតដោយពុំមានការជំនុំជម្រះក្តីត្រឹមត្រូវ ដែលប្រកាសដល់តុលាការមួយដែលមានជាប្រចាំ ។ ត្រូវផ្តល់នូវសិទ្ធិទទួលនិតិវិធីត្រឹមត្រូវនានាដែលធានាដោយតុលាការ ហើយដែលជាសិទ្ធិមិនអាចអត់បានដែលប្រជាជនមានអរិយធម៌ជឿនលឿនបានទទួលស្គាល់” ។

ការដែលថាសិទ្ធិរស់រានមានជីវិតត្រូវបានបញ្ចូលយ៉ាងច្បាស់នៅក្នុងលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិជាច្រើន បង្ហាញថា សិទ្ធិនេះមានសារសំខាន់ជាសារវ័ន្តក្រោមច្បាប់អន្តរជាតិ ។ សិទ្ធិរស់រានមានជីវិតគឺមិនមានលក្ខណៈដាច់ខាតឡើយ ។ រដ្ឋមួយអាចកាត់ទោសប្រហារជីវិតបុគ្គលម្នាក់បាន បន្ទាប់ពីរកឃើញថាមានទោសបែបនេះ ឬអាចសម្លាប់ជននោះក្នុងលក្ខណៈការពារខ្លួន ។ ទោះបីជាយ៉ាងណាក៏ដោយ យោងទៅតាមគណៈកម្មាធិការសិទ្ធិមនុស្ស ការដកហូតជីវិតដោយអាជ្ញាធរនៃរដ្ឋនោះគឺជាបញ្ហានៃការរំលោភដ៏ធ្ងន់ធ្ងរបំផុត ។ ហេតុដូចនេះហើយ ច្បាប់ត្រូវកំណត់និងត្រួតពិនិត្យលក្ខខណ្ឌឬកាលៈទេសៈដែលបុគ្គលម្នាក់អាចត្រូវបានដកហូតជីវិតដោយអាជ្ញាធរទាំងនេះ ។

សហគមន៍អន្តរជាតិភាគច្រើនបានអនុម័តយល់ព្រមចំពោះការហាមប្រាមប្រឆាំងនឹងការកាត់ទោសប្រហារជីវិតដោយពុំមានការជំនុំជម្រះក្តីត្រឹមត្រូវ ។ សេចក្តីប្រកាសនៃគោលការណ៍យុត្តិធម៌ជាមូលដ្ឋានសម្រាប់ជនរងគ្រោះដោយអំពើឧក្រិដ្ឋកម្មនិងរំលោភបំពានលើសិទ្ធិអំណាចបានអំពាវនាវសុំឲ្យរដ្ឋាភិបាលទាំងអស់ធ្វើការតាមដានស៊ើបអង្កេតការស្លាប់ដែលបណ្តាលមកពីភ្នាក់ងារអនុវត្តច្បាប់ ។ គោលការណ៍អនុវត្តហាមប្រាមមិនឲ្យភ្នាក់ងារសាធារណៈមានអភ័យឯកសិទ្ធិបែបនោះឡើយ ។ ក្នុងឆ្នាំ១៩៨២ អង្គការសហប្រជាជាតិបានបង្កើតឡើងនូវគណៈកម្មការពិសេសមួយស្តីអំពីការប្រហារជីវិតស្រេចនឹងចិត្តនិងពុំមានការជំនុំជម្រះក្តីត្រឹមត្រូវ ។ នៅឆ្នាំ១៩៨៩មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តគោលការណ៍ស៊ើបអង្កេតនិងទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពទៅលើការប្រហារជីវិតហួសពីដែនកំណត់ច្បាប់ការប្រហារជីវិតស្រេចតែទំនើងចិត្តនិងគ្មានការជំនុំជម្រះត្រឹមត្រូវ ។ គោលការណ៍ច្បាប់ទាំងនោះអំពាវនាវសុំឲ្យមានការតាមដានស៊ើបអង្កេតជាបន្ទាន់និងពេញលេញមួយចំពោះការរំលោភបំពានដែលមានការសង្ស័យទាំងអស់នោះ ។ គណៈកម្មាធិការអន្តរអាមេរិកាំងបានឈានដល់សេចក្តីសន្និដ្ឋានដូចគ្នាមួយថាទោះក្នុងកាលៈទេសៈណាក៏ដោយ ក៏រដ្ឋាភិបាលទាំងអស់មិនអាចប្រើប្រាស់ការកាត់ទោសប្រហារជីវិតជីវិតមិនស្របច្បាប់ ឬដោយមិនមានការជំនុំជម្រះក្តីត្រឹមត្រូវ ក្នុងគោលបំណងស្តាររបៀបរៀបរយសាធារណៈដែរ ។ វិធានការនេះត្រូវបានហាមប្រាមដោយរដ្ឋធម្មនុញ្ញនៃសហរដ្ឋអាមេរិកនិងដោយលិខិតូបករណ៍អន្តរជាតិទាំងឡាយដែលការការពារសិទ្ធិជាសារវ័ន្តរបស់បុគ្គល ។

## ការបាត់ខ្លួន

ឧក្រិដ្ឋកម្មនៃការបាត់ខ្លួនគឺរួមមាន ការចាប់ពង្រត់បុគ្គលទាំងឡាយដោយបន្ទំដែលតាមធម្មតាធ្វើឡើងដោយក្រុមប៉ូលិស ឬក្រុមបុគ្គលិកយោធាចម្រុះក្រោមការបញ្ជាដោយអាជ្ញាធររដ្ឋា-ភិបាល ឬដោយមានការយល់ព្រមជាចំហពីអាជ្ញាធរទាំងនោះ

និងដោយមានការបដិសេធពីសំណាក់រដ្ឋាភិបាលមិនព្រមទទួលស្គាល់ការចាប់ឃុំឃាំងបុគ្គលនោះ ។ ជារឿយៗ ជនរងគ្រោះគឺជាបុគ្គលដែលត្រូវបានចាត់ទុកថាប្រឆាំងនឹងរដ្ឋាភិបាល មានគ្រោះថ្នាក់ ឬបក្ខនូវវិទ្ធង្សនាប្រឆាំងនឹងរដ្ឋាភិបាល ។ ជនដែលត្រូវឃុំឃាំងអាចប្រឈមមុខទៅនឹងការធ្វើទារុណកម្មឬការកាត់ទោសប្រហារជីវិតដោយពុំមានការជំនុំជម្រះក្តីត្រឹមត្រូវ ហើយអាជ្ញាធរបដិសេធមិនព្រមប្រាប់អំពីកន្លែងឃុំឃាំងជនរងគ្រោះ និងការទាត់ចោលការទទួលខុសត្រូវជាលក្ខណៈរដ្ឋទៅលើអំពើនេះ ។ ការបាត់ខ្លួនគឺពិបាកនឹងជំនុំជម្រះក្តីណាស់ ពីព្រោះប្រសិនបើរកអ្នកបាត់ខ្លួននោះមិនឃើញទេ ក៏ពុំអាចរកភ័ស្តុតាងបង្ហាញថាឧក្រិដ្ឋកម្មនោះកើតឡើងបានដែរ ។ គណៈកម្មាធិការអន្តរអាមេរិកាំងស្តីអំពីសិទ្ធិមនុស្សបានដោះស្រាយបញ្ហានេះនៅក្នុងករណីមួយប្រឆាំងនឹងរដ្ឋហុងឌូរាស ហើយបានអនុម័តនូវច្បាប់ភ័ស្តុតាងទូលំទូលាយជាងនេះ ដើម្បីរកការពិតនៃគ្រប់ទិដ្ឋភាពសំខាន់ៗទាំងអស់របស់ឧក្រិដ្ឋកម្មនេះ ។ ជាការលំបាកខ្លាំងណាស់សម្រាប់អ្នកប្តឹងក្នុងការបង្ហាញឲ្យឃើញថា ការបាត់ខ្លួននោះគឺមានការឯកភាពដោយរដ្ឋ ពីព្រោះមិនអាចរកភ័ស្តុតាងដែលមានកម្រិតឥទ្ធិពលដល់ថ្នាក់នេះទេ ។ (នៅក្នុងរឿងក្តីវេឡាស្កេស) តុលាការបានពិចារណាភ័ស្តុតាងជាប្រយោលជាច្រើន (មានន័យថាមានកើតឡើងនូវការបាត់ខ្លួនជាច្រើន ដែលមានសណ្ឋានជាប្រព័ន្ធក្នុងរឿងក្តីរដ្ឋហុងឌូរាស) ដើម្បីទាញសេចក្តីសន្និដ្ឋានថាសិទ្ធិរបស់ជនរងគ្រោះត្រូវបានរំលោភ ។

អ្នកអត្ថាធិប្បាយជាច្រើនបានទាញហេតុផលថា ការហាមប្រាមប្រឆាំងនឹងការបាត់ខ្លួនដោយបង្ខំ ឬដោយគ្មានការស្ម័គ្រចិត្ត កំពុងតែវិវត្តក្លាយទៅជាបទដ្ឋានដាច់ខាតមួយនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ នៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ អង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ស្តីអំពីជនដែលបាត់ខ្លួន ដោយអំពាវនាវឲ្យរដ្ឋាភិបាលទាំងឡាយអនុវត្តតាមដានស៊ើបអង្កេតទៅលើរបាយការណ៍នៃការបាត់ខ្លួន ដើម្បីធានាឲ្យប្រាកដថាអាជ្ញាធរសន្តិសុខនិងអាជ្ញាធរអនុវត្តច្បាប់ត្រូវតែដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើនៅក្នុងពេលបំពេញភារកិច្ចបុគ្គលទាំងនោះប្រព្រឹត្តខុសពីគោលការណ៍ច្បាប់ ហើយដើម្បីឲ្យអាជ្ញាធរទាំងនោះចៀសវាងការរំលោភបំពានលើសិទ្ធិអំណាចរបស់បុគ្គល ។ សេចក្តីសម្រេចនេះត្រូវបានអនុម័តដោយពុំមានកំណត់ត្រានៃការបោះឆ្នោតទុកជាផ្លូវការឡើយ ។

លើសពីនេះទៅទៀត នៅក្នុងឆ្នាំ១៩៨០ គណៈកម្មការសិទ្ធិមនុស្សបានបង្កើតឡើងនូវក្រុមការងារមួយស្តីពីការបាត់ខ្លួនដោយបង្ខំ ឬដោយគ្មានការស្ម័គ្រចិត្ត ដើម្បីលើកកម្ពស់សមត្ថភាពរបស់អង្គការសហប្រជាជាតិក្នុងការដោះស្រាយបញ្ហានៃការបាត់ខ្លួនទាំងនេះ ។ ទន្ទឹមគ្នានោះ គណៈកម្មការនេះបង្កើតឡើងនូវក្រុមអ្នករាយការណ៍ពិសេសមួយស្តីអំពីការប្រហារជីវិតស្រេចតែនឹងចិត្ត ឬដោយពុំមានការជំនុំជម្រះក្តីត្រឹមត្រូវ ការធ្វើទារុណកម្មអំពើហិង្សាផ្នែកសាសនា និងការជួលទាហានស៊ីឈ្នួល ។ អង្គការច្បាប់ទាំងពីររួមគ្នាបានរៀបចំនូវរបាយការណ៍ជាសាធារណៈមួយ ត្រួតពិនិត្យការអនុវត្តរបស់រដ្ឋ ព្រមទាំងដាក់បង្ខំឲ្យរដ្ឋទាំងឡាយការពារខ្លួនឯងនៅចំពោះមុខគណៈកម្មការនេះ ។ នៅក្នុងខែធ្នូ ឆ្នាំ១៩៩២ មហាសន្និបាតរបស់អង្គការសហប្រជាជាតិបានអនុម័តដោយពុំមានការបោះឆ្នោត នូវសេចក្តីប្រកាសស្តីពីការការពារសិទ្ធិមនុស្សទាំងឡាយឲ្យរួចផុតបាត់ខ្លួនដោយបង្ខំ ។ “ខ” ទាំងឡាយនៃសេចក្តីប្រកាសនេះរួមមានដូចតទៅ÷

◆ រដ្ឋនីមួយៗត្រូវខិតខំប្រឹងប្រែងទប់ស្កាត់នូវរាល់ការបាត់ខ្លួនដោយដឹងក្នុងដែនដីរបស់ខ្លួន ។ មាត្រា៣ ។

◆ សកម្មភាពទាំងអស់នៃការបាត់ខ្លួនដោយបង្ខំត្រូវតែជាបទល្មើសក្រោមច្បាប់ព្រហ្មទណ្ឌ ។ មាត្រា៤ ។

◆ ពុំមានការអនុញ្ញាតឲ្យធ្វើបដិបញ្ញ ។ មាត្រា៥ និង៧ ។

◆ ជនរងគ្រោះនិងគ្រួសាររបស់ខ្លួនត្រូវទទួលនូវសិទ្ធិធ្វើការប្តឹងផ្តល់ ហើយត្រូវមានសិទ្ធិទទួលការសងជំងឺចិត្តគ្រប់គ្រាន់ ។ មាត្រា១៩ ។ សេចក្តីប្រកាសស្រដៀងគ្នានេះមួយត្រូវបានប្រកាសដោយអនុសញ្ញាអន្តរអាមេរិកាំង ។

តុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង បានបញ្ជាក់លក្ខណៈបាត់ខ្លួនថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងរឿងក្តីវេឡាស្កេស ។ ប្រសិនបើមានលក្ខណៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបាត់ខ្លួននេះឋិតនៅក្រោមគោលការណ៍ច្បាប់នៅនូរិមប៊ឺក ហើយ

អនុសញ្ញាអន្តការសហប្រជាជាតិស្តីអំពីការមិនអនុវត្តដែនអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

ក្នុងរឿងក្តី ហ៊័រទី ប្រឆាំងនឹង ស៊ូរ៉េម៉ាសុង *694 F Supp. 707 (N.D.Call 1988)* តុលាការស្រុករបស់សហរដ្ឋអាមេរិកយល់ឃើញថា ការបាត់ខ្លួនគឺជាបទល្មើសមួយដែលត្រូវបានទទួលស្គាល់ជាសកលក្រោមច្បាប់នៃជាតិ ។ ក្នុងគោលបំណងផ្តល់នូវដែនសមត្ថកិច្ច ការប្រព្រឹត្តកំហុសអន្តរជាតិជាឯកជន ឬរដ្ឋប្បវេណីត្រូវបានកំណត់ថាជាការរំលោភបំពានលើច្បាប់ទំនៀមទម្លាប់នាពេលបច្ចុប្បន្នដែលជាការមូលមតិគ្នាជាសកលនៅក្នុងសហគមន៍អន្តរជាតិ ចំពោះឋានៈនៃការចងភ្ជាប់ទៅនឹងច្បាប់ ហើយនិងការព្រមព្រៀងរបស់ពួកគេ ។ ពោលគឺមានន័យថា ការបាត់ខ្លួនទាំងនោះមានលក្ខណៈទូទៅអាចកំណត់និយមន័យបាន ហើយថាជាបទដ្ឋានអន្តរជាតិជាកាតព្វកិច្ច ។ តុលាការនៅហ៊័រទីពឹងផ្អែកមួយផ្នែកទៅលើលិខិតថ្លែងសច្ចាដែលដាក់ឲ្យពិនិត្យដោយក្រុមប្រឹក្សាចៅក្រមអន្តរជាតិ ដែលបានកំណត់ការបាត់ខ្លួនទាំងនេះថា ១) ជាការចាប់ពង្រត់ដោយមន្ត្រីរដ្ឋមួយ ឬដោយបុគ្គលមួយចំនួនដែលប្រព្រឹត្តតាមការយល់ព្រម ឬតាមអាជ្ញារដ្ឋ ២) ការបដិសេធដោយរដ្ឋថាខ្លួនពុំបានដឹងអំពីការចាប់ពង្រត់និងកន្លែងឃុំឃាំងជនរងគ្រោះ ហើយក្រុមប្រឹក្សាចៅក្រមនោះបានផ្តល់នូវកសិណសុំឲ្យធ្វើការថ្កោលទោសជាសកលចំពោះការអនុវត្តបែបនេះ ។ ទោះបីជាកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយពុំបានបញ្ចូលដោយផ្ទាល់នូវការបាត់ខ្លួននេះក៏ដោយ ក៏គណៈកម្មការសិទ្ធិមនុស្សរបស់កតិកាសញ្ញានេះបានដាក់បន្ទុកឲ្យរដ្ឋទាំងឡាយមានកាតព្វកិច្ចតាមដានស៊ើបអង្កេតការបាត់ខ្លួនបែបនេះ នៅពេលដែលការបាត់ខ្លួនកើតឡើង ។

ជាងនេះទៅទៀត ការទាញហេតុផលបញ្ជាក់របស់មជ្ឈមណ្ឌលនានា ការបាត់ខ្លួនទាំងឡាយគឺជាការរំលោភលើការធានាសិទ្ធិទាំងឡាយដែលបានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិមាត្រា៩ដែលចែងថា «ជនគ្រប់រូបមានសិទ្ធិទទួលសិទ្ធិសេរីភាពនិងសន្តិសុខផ្ទាល់ខ្លួន ។ គ្មាននរណាម្នាក់រងនូវការចាប់ខ្លួននិងឃុំឃាំងស្រេចតែអំពើចិត្តឡើយ» ហើយមាត្រា១៤ «ជនគ្រប់រូបមានសិទ្ធិទទួលនូវការជំនុំជម្រះក្តីជាសាធារណៈនិងដោយយុត្តិធម៌ដោយតុលាការមួយមានសមត្ថកិច្ចគ្រប់គ្រាន់មានឯករាជ្យភាព មិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់» ។ ការថ្កោលទោសបន្ថែមមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលធានាថាគ្មាននរណាម្នាក់ទទួលរងការចាប់ខ្លួនឃុំឃាំង ស្រេចតែអំពើចិត្តនោះទៀតឡើយ ដោយសារថាការបាត់ខ្លួនគឺជាឧក្រិដ្ឋកម្មមួយធ្ងន់ជាងការចាប់ឃុំឃាំងស្រេចតែចិត្តទៅទៀត ។ ទោះបីជាយ៉ាងណាក៏ដោយ ការធានាសិទ្ធិការពារទាំងនេះត្រូវបានរារាំងដោយអនុសញ្ញាអន្តរជាតិ ដែលចែងពីការព្យួរទុកជាបណ្តោះអាសន្ននូវការធានាសិទ្ធិមួយចំនួន «រួមមានមាត្រា៩និង១៤» ក្នុងពេលរដ្ឋស្ថិតនៅក្នុងភាពអាសន្ន ។

**អាលីហ្សាប៊ែត វ៉ាន់ស្កាក់**



វិចិត្រករៈ វ៉ាន់ ណាត
អតីតអ្នកទោសនៅមន្ទីរស-២១

# តុលាការនៅទីម័រខាងកើត
## ក្រុមប្រឹក្សាអ្នកច្បាប់ពិសេសខាងព្រហ្មទណ្ឌកម្រិតធ្ងន់

***"តុលាការក្នុងស្រុកកម្រិតជាតុលាការអន្តរជាតិ"ទី១ សម្រាប់កាត់សេចក្តីទៅលើអំពើឃោរឃៅ និងមូលហេតុដែលតុលាការនេះមានការពាក់ព័ន្ធជាមួយកម្ពុជា***

*(អត្ថបទនេះសរសេរចេញពីគំនិតរបស់បុគ្គល មិនមែនជាគំនិតរបស់ស្ថាប័នដែលអ្នកនិពន្ធធ្វើការជាមួយនោះទេ)*

### I.សេចក្តីផ្តើម

ក្នុងតួនាទីជាអ្នកគ្រប់គ្រងបណ្តោះអាសន្នសម្រាប់ទីម័រខាងកើត រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើតបានបើកសវនាការបណ្តើរៗ ដើម្បីជំនុំជម្រះទោសទៅលើជនទាំងឡាយណាដែលមានការពាក់ព័ន្ធទៅនឹងអំពើឃោរឃៅដែលបានកើតឡើងនៅឆ្នាំ១៩៩៩ ។ សាលក្រមដំបូងក្នុងករណីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានចេញនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០១ ។ អង្គជំនុំជម្រះទាំងអម្បាលម៉ាននេះត្រូវបានធ្វើឡើងក្នុងតុលាការក្នុងស្រុកឌីលី ដែលនៅទីនោះចៅក្រមអន្តរជាតិនិងទីម័រខាងកើតដែលមានជំនាញពិសេសខាងព្រហ្មទណ្ឌ មានដែនសមត្ថកិច្ចជំនុំជម្រះទៅលើអ្វីដែលហៅថា "បទឧក្រិដ្ឋធ្ងន់ធ្ងរ" ដូចជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ទារុណកម្ម និងការរំលោភមួយចំនួនទៀតទៅលើច្បាប់ក្នុងស្រុកដែលហៅថាក្រមព្រហ្មទណ្ឌឥណ្ឌូនេស៊ី ។ អ្វីដែលត្រូវបានរៀបចំគម្រោងសម្រាប់ប្រទេសកម្ពុជាតាមរយៈអង្គជំនុំជម្រះវិសាមញ្ញ គឺអាចប្រៀបធៀបជាមួយនឹងប្រព័ន្ធនេះ ។

គម្រោងការអំពីបទឧក្រិដ្ឋកម្រិតធ្ងន់ដែលយកលំនាំតាមគំរូពីមុនរបស់ប្រទេសកម្ពុជា ហើយតាមរបាយការណ៍ថា ច្បាប់នេះក៏បានយកលំនាំតាមគម្រោងឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មលើជនជាតិភាគតិចនៃប្រទេសកូសូវ៉ូ ដែលគម្រោងនេះត្រូវបានបោះបង់ចោលរួចទៅហើយ ។ ទីម័រខាងកើតបានបង្កើតមធ្យោបាយថ្មីមួយមុនគេបង្អស់ សម្រាប់ឲ្យមានយុត្តិធម៌កម្រិតអន្តរជាតិពោលគឺតាមរយៈ "តុលាការក្នុងស្រុកកម្រិតអន្តរជាតិ" ដែលផ្សាំនៅលើរចនាសម្ព័ន្ធតុលាការរបស់ជាតិមួយដែលពោរពេញទៅដោយការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនិងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ ក្រុមប្រឹក្សាតុលាការព្រហ្មទណ្ឌពិសេសរបស់ទីម័រខាងកើត មិនមែនជាតុលាការអន្តរជាតិពិសេស(អាដហុក) ដែលបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជា-ជាតិនោះទេ ហើយក៏មិនមែនជាដំណើរការនៃតុលាការក្នុងស្រុកសុទ្ធសាធនោះដែរ ។ រដ្ឋអាជ្ញានិងចៅក្រមក្នុងស្រុកមានលទ្ធភាពចូលរួមនៅក្នុងដំណើរការកាត់សេចក្តីជាមួយសមភាគីអន្តរជាតិពោលគឺខុសពីតុលាការអន្តរជាតិដែលអាដហុកបង្កើតឡើងសម្រាប់ប្រទេសយូហ្គោស្លាវីនិងរ៉្វាន់ដា ។ តុលាការនៅប្រទេសយូហ្គោស្លាវី និងរ៉្វាន់ដា មិនឲ្យមានការចូលរួមបែបនេះឡើយដោយបារម្ភថា វានឹងធ្វើឲ្យមានភាពលម្អៀងនិងមិនឯករាជ្យក្នុងតុលាការ ។

តុលាការព្រហ្មទណ្ឌពិសេសនេះ(ដែលពីមុនមានតែមួយហើយឥឡូវនេះមានពីរ) បាននិងកំពុងប្រតិបត្តិអស់រយៈពេលមួយឆ្នាំ ហើយផ្តល់នូវមេរៀនដ៏មានសារប្រយោជន៍សម្រាប់ប្រទេសកម្ពុជានិងសេរ៉ាឡេអូន ដែលប្រទេសទាំងពីរ អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលក្នុងស្រុកបានចរចាគ្នាដើម្បីបង្កើតតុលាការពិសេសមួយដែលមានលក្ខណៈជា"តុលាការក្នុងស្រុកកម្រិតអន្តរជាតិ"ដូចគ្នានេះដែរ ។ និក្ខេបបទនេះគឺជានិក្ខេបបទទីមួយហើយដែលរិះរកមធ្យោបាយទាញអង្គជំនុំជម្រះវិសាមញ្ញរបស់កម្ពុជា(តុលាការខ្មែរក្រហម) ឲ្យចូលក្នុងមូលបទអន្តរជាតិច្រើនដោយផ្តោតសំខាន់ទៅលើទីម័រខាងកើតនិងការងាររបស់ក្រុមប្រឹក្សាអ្នកច្បាប់ខាងព្រហ្មទណ្ឌពិសេសរបស់ខ្លួន ។ ទោះបីជាមានការខុសប្លែកគ្នាខ្លះក៏ដោយ ប៉ុន្តែមានភាពស្រដៀងគ្នាច្រើនជាង ។ និក្ខេបបទនេះចង់ទាញយកបទពិសោធមកពីទីម័រខាងកើតនិងក្រុមប្រឹក្សាអ្នកច្បាប់ខាងព្រហ្មទណ្ឌពិសេសរបស់ប្រទេសនេះក្នុងការ

ដោះស្រាយទៅលើរឿងឃោរឃៅ ។ កិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការយល់ដឹងអំពីទីម័រខាងកើតដែលទាក់ទាក់នឹងកម្ពុជា ត្រូវបានធ្វើឡើងក្នុងក្តីសង្ឃឹមថានឹងផ្តល់នូវវិភាគទានដ៏មានប្រយោជន៍ចំពោះការស្វែងរកយុត្តិធម៌របស់ប្រទេសកម្ពុជា ។

## II.សាវតាររបស់ទីម័រខាងកើត

ឆ្នាំ១៩៧៥ គឺជាឆ្នាំប្រកបដោយសោកនាដកម្មរបស់ប្រទេសកម្ពុជានិងទីម័រ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់បក្សកុម្មុយនិស្តកម្ពុជា ។ នៅថ្ងៃទី៧ខែធ្នូ ឆ្នាំ១៩៧៥ អ្វីដែលគេហៅនៅពេលនោះថា អាណានិគមព័រទុយហ្កាល់ ឬ«ទឹកដីដែលមិនគ្រប់គ្រងដោយខ្លួនឯង»នោះ ត្រូវបានលុកលុយឈ្លានពានដោយកងកម្លាំងប្រដាប់អាវុធនៃសាធារណរដ្ឋឥណ្ឌូនេស៊ី ក្រោមការដឹកនាំរបស់ប្រធានាធិបតី ស៊ូហាតូ ។ ក្នុងរយៈពេល២៤ឆ្នាំនៃការកាន់កាប់នេះ ប្រជាជនឥណ្ឌូនេស៊ីបានជួបប្រទះនូវចលនាតស៊ូរបស់ជនជាតិភាគតិច ដែលមានរូបភាពតូចតាច ប៉ុន្តែមានភាពស្រួចស្រាល់ ។ ក្រុមចលនានេះមានឈ្មោះថា ហ្វាលីនទីល ដែលទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់ប្រជាជនមូលដ្ឋាន ។ កងទ័ពឥណ្ឌូនេស៊ីសម័យទំនើបដែលទទួលហ្វឹកហ្វឺននិងប្រដាប់ដោយអាវុធរបស់ប្រទេសលោកខាងលិច ត្រូវបានបណ្តោយឲ្យដេញតាមបង្ក្រាបចលនារំដោះជាតិព្រមទាំងជនស៊ីវិលដែលផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់ចលនានេះ ។ កងកម្លាំងប្រដាប់អាវុធឥណ្ឌូនេស៊ីត្រូវបានបង្កើតនិងគាំទ្រដោយកងជីវពលក្នុងស្រុក និងក្រុមទាហានប៉ារ៉ានានា ដែលជាញឹកញយជួយប្រយុទ្ធគ្នាទៅវិញទៅមក ហើយបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងអំពើឃោរឃៅក្នុងឆ្នាំ១៩៩៩ ។ របាយការណ៍ស្តីពីអំពើឃោរឃៅជាច្រើនបណ្តាលឲ្យមានការចោទប្រកាន់ថា អាជ្ញាធរប្រទេសឥណ្ឌូនេស៊ីមានការទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ តាមការពិត ការចោទប្រកាន់កម្រិតធ្ងន់បំផុតនោះគឺថាអាជ្ញាធរប្រទេសឥណ្ឌូនេស៊ីបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើប្រជាជនរបស់កោះដែលស្ថិតក្រោមការកាន់កាប់របស់ខ្លួន ។

ក្រោយពីប្រធានាធិបតី ស៊ូហាតូ លាលែងពីតំណែង ហើយស្ថានការណ៍ក្នុងស្រុកប្រែប្រួលយ៉ាងលឿននៅឆ្នាំ១៩៩៧និង១៩៩៨ ពាក់ព័ន្ធទៅនឹងវិបត្តិហិរញ្ញវត្ថុអាស៊ីនោះ ប្រទេសឥណ្ឌូនេស៊ីបានយល់ព្រមធ្វើប្រជាមតិចង់ដឹងថាតើប្រជាជននៅទីម័រខាងកើតចង់គ្រប់គ្រងនិងសម្រេចវាសនារបស់ខ្លួនឯងដែរឬទេ ។ ប្រជាមតិត្រូវបានរៀបចំឡើងដោយអង្គការសហប្រជាជាតិនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩៩ ។ ជនជាតិទីម័រប្រមាណ៧៨,៥ភាគរយបានបោះឆ្នោតចង់ដកខ្លួនចេញពីការគ្រប់គ្រងរបស់ប្រទេសឥណ្ឌូនេស៊ី ទោះបីជាមានការបំភិតបំភ័យនិងអំពើហិង្សាយ៉ាងណាក៏ដោយ ។ ក្នុងចន្លោះពេលប៉ុន្មានម៉ោងនៃការប្រកាសលទ្ធផលបោះឆ្នោត សភាពការណ៍ទីម័រទាំងមូលកាន់តែធ្ងន់ធ្ងរទៅៗ ។ មានមនុស្សឃាត ការចាប់ជម្រិត ការចាប់រំលោភ បំផ្លាញទ្រព្យសម្បត្តិ ចោរលួច និងដុតបំផ្លាញទីតាំងយោធា ការិយាល័យ និងផ្ទះសម្បែងដែលជនស៊ីវិលកំពុងរស់នៅ ។ អំពើទាំងនេះប្រព្រឹត្តឡើងដោយកងជីវពលដែលគាំទ្រដោយប្រទេសឥណ្ឌូនេស៊ី ។ មានជនស៊ីវិលរាប់ពាន់នាក់ត្រូវបានប្រមូលកៀងគរទៅកាន់ទីម័រខាងលិចតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ។ អង្គការសហប្រជាជាតិត្រូវបានឡោមព័ទ្ធជុំវិញឲ្យនៅតែក្នុងទីតាំងរបស់ខ្លួនមួយកន្លែង ហើយបង្ខំឲ្យជម្លៀសបុគ្គលិករបស់ខ្លួន ព្រមជាមួយនឹងជនស៊ីវិលទីម័រដែលអង្គការសហប្រជាជាតិកំពុងតែផ្តល់ជម្រកឲ្យស្នាក់នៅ ។ ដោយមានការគាំទ្រពីកងកម្លាំងប្រដាប់អាវុធឥណ្ឌូនេស៊ី កងជីវពលបានប្រព្រឹត្តមកលើទឹកដីទីម័រខាងកើតដូចកម្រោលចូល ។ កងកម្លាំងអន្តរជាតិដែលក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិចាត់តាំងមកបានមកដល់ទីម័រនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៩ ហើយចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួនដើម្បីស្តារសណ្តាប់ធ្នាប់ច្បាប់ឡើងវិញ ។ ការកាន់កាប់របស់ប្រទេសឥណ្ឌូនេស៊ីត្រូវបានបញ្ចប់ជាផ្លូវការនៅពេលប្រទេសឥណ្ឌូនេស៊ីប្រគល់អំណាចនិងការកាន់កាប់ទឹកដីទីម័រខាងកើតមកឲ្យអង្គការសហប្រជាជាតិនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៩ ព្រមទាំងការដកទ័ពឥណ្ឌូនេស៊ីដែលសេសសល់ទាំងប៉ុន្មានចេញទាំងអស់ ។

បច្ចុប្បន្ននេះ អង្គការសហប្រជាជាតិបាននិងកំពុងគ្រប់គ្រងទឹកដីទីម័រខាងកើតតាមរយៈ«រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត»ដែលដឹកនាំដោយតំណាង

ពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការរៀបចំការបោះឆ្នោតលើកដំបូងបង្អស់សម្រាប់ប្រទេសនេះ ធ្វើឡើងនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ។ ឥឡូវនេះអតីតអាណានិគមព័រទុយហ្កាល់ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលបណ្ដោះអាសន្នដែលមានសមាសភាពដឹកនាំជាជនជាតិទីម័រទាំងអស់ ។ រដ្ឋាភិបាលនេះដំណើរការដោយមានការជួយឧបត្ថម្ភជ្រោមជ្រែងពីសំណាក់អង្គការសហប្រជាជាតិ ។ឯករាជ្យពេញលេញនឹងលេចចេញជារូបរាងពិតប្រាកដនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២ ។

### III. ការស្វែងរកយុត្តិធម៌នៅទីម័រខាងកើត

ភាពច្របូកច្របល់កើតចេញពីអំពើឃោរឃៅនៅទីម័រខាងកើតកាលពីខែកញ្ញា ឆ្នាំ១៩៩៩ បានកើតឡើងនៅចំពោះមុខប្រព័ន្ធផ្សព្វផ្សាយរបស់ពិភពលោកនិងបុគ្គលិកអង្គការសហប្រជាជាតិ ។ រូបភាពទាំងអស់នៅលើកញ្ចក់ទូរទស្សន៍និងឯកសារបោះពុម្ពផ្សាយនៅទូទាំងពិភពលោក នាំឲ្យមានកំហឹងជាអន្តរជាតិ និងការអំពាវនាវសុំឲ្យយកជនទាំងឡាយណាដែលទទួលខុសត្រូវមកជំនុំជម្រះទោសតាមច្បាប់ ។ អង្គការសហប្រជាជាតិបានចាត់តាំងឲ្យជំនាញការរបស់ខ្លួនមកត្រួតពិនិត្យជាក់ស្ដែងលើអ្វីដែលបានកើតឡើងនៅឆ្នាំ១៩៩៩ និងកំណត់អត្តហេតុឲ្យច្បាស់ថាជនណាមួយដែលត្រូវទទួលខុសត្រូវ ។ អ្នករាយការណ៍ពិសេសបីរូបនិងគណៈកម្មាធិការស៊ើបអង្កេតអន្តរជាតិមួយ ត្រូវបានបញ្ជូនមកកាន់តំបន់នេះ ។ បុគ្គលិកស៊ើបអង្កេតនិងគណៈកម្មាធិការបានរកឃើញគម្រូយ៉ាងច្បាស់ស្ដីពីការវាយប្រហារក្នុងទ្រង់ទ្រាយធំប្កជាប្រព័ន្ធមកលើប្រជាជនស៊ីវិលនៃទីម័រខាងកើត ដែលពាក់ព័ន្ធនឹងការចូលរួមរបស់រដ្ឋ ដែលជាធាតុផ្សំមួយដ៏សំខាន់បង្កើតបានជាបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ គណៈកម្មាធិការស៊ើបអង្កេតអន្តរជាតិបានរកឃើញភ័ស្តុតាងបញ្ជាក់ថាកងទ័ពឥណ្ឌូនេស៊ីនិងអាជ្ញាធរស៊ីវិលនៅទីម័រខាងកើតនិងមួយចំនួនទៀតនៅទីក្រុងហ្សាកាតា បានអនុវត្តតាមនយោបាយធ្វើឲ្យកងជីវពលមានឥទ្ធិពលទៅលើលទ្ធផលនៃការពិគ្រោះយោបល់របស់ប្រជាជន ។ គណៈកម្មាធិការនេះសង្កត់ធ្ងន់ថា ការបំភិតបំភ័យ អំពើភេរវកម្ម ការបំផ្លាញទ្រព្យសម្បត្តិ ការយកចេញទៅកន្លែងផ្សេង និងការជម្លៀសប្រជាជន មិនអាចធ្វើទៅបានទេប្រសិនបើគ្មានការចូលរួមយ៉ាងសកម្មពីសំណាក់កងទ័ពឥណ្ឌូនេស៊ី និងការដឹងឮព្រមទាំងការយល់ព្រមពីសំណាក់មេបញ្ជាការយោធាជាន់ខ្ពស់នោះ ។ គណៈកម្មាធិការស៊ើបអង្កេតបានទាញសន្និដ្ឋានថា កងទ័ពឥណ្ឌូនេស៊ីជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះការបំភិតបំភ័យ ភេរវកម្ម ការសម្លាប់ និងអំពើឃោរឃៅផ្សេងៗទៀត ដែលប្រជាជនទីម័រខាងកើតបានទទួលរងមុននិងក្រោយពេលប្រជាជនទាំងនោះជួបជុំពិគ្រោះយោបល់គ្នា ។ អ្នកស៊ើបអង្កេតនៅឥណ្ឌូនេស៊ីធ្វើការនៅក្នុងគណៈកម្មាធិការសិទ្ធិមនុស្ស បានរកឃើញភ័ស្តុតាងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលកើតចេញពីការរំលោភលើសិទ្ធិមនុស្សធ្ងន់ធ្ងរដែលធ្វើឡើងដោយមានផែនការច្បាស់លាស់និងមានលក្ខណៈប្រព័ន្ធ មនុស្សឃាត ការបំផ្លិចបំផ្លាញយ៉ាងដំណំ អំពើទាសភាព ការផ្លាស់ប្ដូរទីលំនៅនិងជម្លៀសដោយបង្ខំ និងអំពើអមនុស្សធម៌ដទៃទៀតប្រព្រឹត្តមកលើជនស៊ីវិលដែលមានដូចជា ទារុណកម្ម និងការធ្វើបាប ការបាត់ខ្លួន អំពើឃោរឃៅមកលើស្ត្រីនិងកុមារមានដូចជាការរំលោភ និងទាសករបម្រើផ្លូវភេទ ព្រមទាំងការអនុវត្តយុទ្ធនាការកម្ទេចអ្វីៗគ្រប់យ៉ាង ។ ប៉ុន្តែជាការសំខាន់ណាស់ក្នុងការបញ្ជាក់ថា ការរកឃើញអត្តហេតុរបស់បេសកកម្មនៃគណៈកម្មាធិការស៊ើបអង្កេតដែលមិនធ្វើការវាយតម្លៃទៅលើភ័ស្តុតាងដោយប្រើបទដ្ឋានដាក់លាក់ដែលតុលាការតម្រូវនោះទេ ។ សំខាន់គឺអាស្រ័យទៅលើតុលាការជាអ្នកសម្រេច ដែលមានការកិច្ចវាយតម្លៃភស្តុតាងដែលផ្ដល់ដោយភាគីនានា និងចេញសេចក្ដីសម្រេចដោយយកបទដ្ឋានច្បាប់ដែលមានដែនអនុវត្តមកប្រើ ។

អ្នករាយការណ៍ពិសេសនិងគណៈកម្មាធិការស៊ើបអង្កេតអន្តរជាតិ បានសុំឲ្យមានតុលាការអន្តរជាតិមួយដើម្បីកាត់សេចក្ដីទៅលើអំពើឃោរឃៅឆ្នាំ១៩៩៩នៅទីម័រខាងកើត ។ នៅក្នុងអ្វីដែលប្រែក្លាយជាការទស្សន៍ទាយមិនខុសនោះ គឺអ្នករាយការណ៍ពិសេសបានប្រមើលមើលទុកជាមុនថា ប្រព័ន្ធតុលាការរបស់ទីម័រខាងកើតដែលមិនទាន់កើតចេញជារូបរាងនៅឡើយនោះ មិនអាចសង្ឃឹមថានឹងអាចធ្វើការស៊ើបអង្កេតលើករណីអំពើឃោរឃៅ

របៀបនេះបានទេ ហើយថាកិច្ចខិតខំប្រឹងប្រែងឥតសំចៃប្រហែលជាមិនអាចនាំដល់ការស៊ើបអង្កេតទៅលើបទឧក្រិដ្ឋឲ្យបានពេញលេញបានឡើយ ។ គណៈកម្មាធិការស៊ើបអង្កេតសិទ្ធិមនុស្សបានឲ្យយោបល់ថា គួរតែពង្រឹងសមត្ថភាពស៊ើបអង្កេតរបស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត ជាមធ្យោបាយសម្រាប់ចន្លោះពេលតុលាការទីម័រមិនទាន់ចេញជារូបរាងហើយមិនទាន់មានការសម្រេចបង្កើតតុលាការអន្តរជាតិ ។ ប៉ុន្តែសហគមន៍អន្តរជាតិសូមផ្អែកក្តីសង្ឃឹមទៅលើការសន្យារបស់ប្រទេសឥណ្ឌូនេស៊ីដែលថានឹងនាំយកជនដៃដល់មកកាត់ទោសក្នុងតុលាការប្រទេសឥណ្ឌូនេស៊ី ។ សហគមន៍អន្តរជាតិពេញចិត្តចំពោះវិវឌ្ឍន៍នៃសមត្ថភាពស៊ើបអង្កេតនៅទីម័រខាងកើត ។

គម្រោងស្វែងរកយុត្តិធម៌នៅទីម័រខាងកើតតាមរយៈ "តុលាការកម្រិតអន្តរជាតិ" ធ្វើដំណើរយ៉ាងលឿន គឺប្រហែលជាប៉ុន្មានខែប៉ុណ្ណោះឈានដល់ការបង្កើតរដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត ពោលគឺវាផ្ទុយទៅនឹងការចរចាដ៏យូរនិងស្មុគស្មាញរវាងអង្គការសហប្រជាជាតិនិងមេដឹកនាំកម្ពុជាដែលត្រូវបានបោះឆ្នោតជ្រើសតាំងឡើង ។ ប្រព័ន្ធតុលាការថ្មីមួយទើបតែត្រូវបានបង្កើតចេញពីគំនរផេះផង់បន្សល់ទុកដោយកងកម្លាំងប្រដាប់អាវុធឥណ្ឌូនេស៊ី ។ តុលាការនេះមានបុគ្គលិកជាជនជាតិទីម័រដែលមិនដែលមានបទពិសោធន៍លើកិច្ចការនេះទាល់តែសោះមុនពេលដែលខ្លួនត្រូវបានតែងតាំងឲ្យចូលកាន់ការិយាល័យចៅក្រមនិងព្រះរាជអាជ្ញា ហើយអ្នកទាំងនេះត្រូវតែចាប់ផ្តើមការងារដោយខ្វះខាតការហ្វឹកហ្វឺននិងការបង្ហាញព្រមទាំងខ្វះខាតភ័ស្តុភារនិងសម្ភារ ។ មិនតែប៉ុណ្ណោះ គ្មានបុគ្គលណាម្នាក់ទទួលការហ្វឹកហាត់ផ្នែកគ្រប់គ្រងតុលាការឡើយ ។

ក្នុងនាមជារដ្ឋបាលតាមព្រឹត្តន័យ និងមានសិទ្ធិពេញលេញក្នុងការគ្រប់គ្រងលើទឹកដីទីម័រខាងកើត រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើតបានអនុម័តច្បាប់បង្កើតតុលាការក្នុងស្រុកកម្រិតអន្តរជាតិ ដើម្បីកាត់សេចក្តីអំពើឃោរឃៅ ដែលមានទីតាំងនៅតុលាការស្រុកឌីលី ។ ការសម្រេចចិត្តដ៏សំខាន់ដែលមានផលវិបាកលើសលប់នេះមិនមែនកើតឡើងចេញពីការពិភាក្សាឲ្យបានល្អិតល្អន់វែងឆ្ងាយជាសាធារណៈជាមួយជនជាតិទីម័រខាងកើតទេ ហើយសូម្បីតែប្រធានតុលាការ



គណប្រតិភូទីម័រខាងកើតធ្វើទស្សនកិច្ចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ស្រុកឌីលីក៏មិនបានពិភាក្សាជាមួយដែរ ទោះបីជាច្បាប់តម្រូវឲ្យពិភាក្សាក៏ដោយ ។ អ្នកស្រុកមានការខឹងសម្បាយ៉ាងខ្លាំងទៅនឹងទង្វើនេះ ។ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងសង្គមស៊ីវិលគាំទ្រយ៉ាងខ្លាំងចំពោះការបង្កើតតុលាការអន្តរជាតិពិសេសនេះឡើង ដូចជានៅប្រទេសយូហ្គោស្លាវីនិងរ៉ាន់ដា ដើម្បីកាត់សេចក្តីជនទាំងឡាយដែលទទួលខុសត្រូវចំពោះអំពើឃោរឃៅនៃការកាន់កាប់ទឹកដីទីម័រអស់រយៈពេល២៤ឆ្នាំមកហើយ ដែលការកាន់កាប់នេះបណ្តាលឲ្យកើតមានអំពើឃោរឃៅពេញទំហឹងនៅឆ្នាំ១៩៩៩ ។ យុទ្ធនាការអន្តរជាតិមួយកំពុងតែដំណើរការក្នុងគោលបំណងដាក់ទម្ងន់ធ្ងើយ៉ាងម៉េចបង្កើតឲ្យបាននូវតុលាការអន្តរជាតិពិសេសនេះ ។ តាមការពិត ការសុំឲ្យមានតុលាការអន្តរជាតិចេះតែកើនឡើងជាលំដាប់នៅពេលដែលភាពរៀបចំខ្លួនរួចជាស្រេចនិងកិច្ចខិតខំប្រឹងប្រែងរដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើតត្រូវបានចាត់ទុកថាមិនបាននាំមកនូវយុត្តិធម៌ ។ ក្នុងខណៈដែលរដ្ឋាភិបាលកម្ពុជាបដិសេធមិនចង់ឲ្យមានតុលាការអន្តរជាតិ ការសុំហើយសុំទៀតពីជនជាតិទីម័រខាងកើត អ្នកជំនាញការនិងអង្គការក្រៅរដ្ឋាភិបាល ឲ្យមានតុលាការអន្តរជាតិសម្រាប់កាត់សេចក្តីទៅលើអំពើឃោរឃៅនៅទីម័រខាងកើត ឥតបានប្រយោជន៍អ្វីសោះ ។

យុត្តិធម៌ ការលើកលែងទោសនិងការផ្សះផ្សា ឥឡូវនេះក្លាយជាបញ្ហាក្តៅគគុកនៅទីម័រខាងកើត ។ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ការធ្វើនិយតកម្មបង្កើតគណៈកម្មាធិការទទួលពាក្យបណ្តឹងស្វែងរកការពិតនិងផ្សះផ្សាសម្រាប់ទីម័រខាងកើត ត្រូវបានអនុម័តរួចហើយ ។ នៅអំឡុងពេលសរសេរច្បាប់នេះ មានបេក្ខជនដាក់ឈ្មោះសុំចូលបម្រើក្នុងជួរគណៈកម្មាធិការកំពុងតែត្រូវបានជម្រុះចោលបណ្តើរៗ ។ មានទិដ្ឋភាពពីរក្នុងដំណើរការនេះ ។ ទី១ ការងាររបស់គណៈកម្មាធិការទទួលពាក្យបណ្តឹងស្វែងរកការពិតនិងផ្សះផ្សាសម្រាប់ទីម័រខាងកើត ដែលនឹងខិតខំយ៉ាងណាចងក្រងឯកសារឲ្យបានហ្មត់ចត់ទាក់ទងអ្វីដែលកើតឡើងនៅទីម័រ ដោយត្រួតពិនិត្យគំរូនិងវិសាលភាពនៃការរំលោភសិទ្ធិមនុស្សទាក់ទងនឹងប្រវត្តិសាស្ត្រដ៏ខ្លោចផ្សាររបស់ប្រទេសនេះចាប់តាំងពីឆ្នាំ១៩៧៤ ។ ទី២ គឺការបង្កើតដំណើរការបង្រួបបង្រួមផ្សះផ្សាក្នុងសហគមន៍ដែលនឹងជួយសម្រួលឲ្យជនដែលបានប្រព្រឹត្តកំហុសស្រាលវិលត្រឡប់មករួមរស់នៅក្នុងសហគមន៍របស់ខ្លួនវិញតាមរយៈការលើកលែងទោស ។ ដំណើរការបង្រួបបង្រួមផ្សះផ្សាក្នុងសហគមន៍នេះគឺធ្វើឡើងដើម្បីឲ្យការិយាល័យនេះទាញយកនូវទិន្នន័យដ៏សន្ធឹកសន្ធាប់ដើម្បីធ្វើការស៊ើបអង្កេតនិងកាត់សេចក្តីទៅលើបទឧក្រិដ្ឋកម្រិតធ្ងន់នៅទីម័រខាងកើត ។ ឥទ្ធិពលនៃទង្វើនេះគឺថា ប្រសិនបើមានការលើកលែងទោសមែន បានតែបទល្មើស លហុ ប៉ុណ្ណោះដែលមិនអាចចូលជាកម្រិតធ្ងន់ និងដោយមានការយល់ព្រមពីអាជ្ញាធរដែលមានភារៈជាអាជ្ញាសាលាផង ។ **(នៅមានត)** **ស៊ូហ្សាណា លីនតុន**

## ពាក្យសុំសច្ចាចំពោះឆន្ទបក្ស

(កំណត់ហេតុ០៧១)

១) ប្តេជ្ញាចិត្តធ្វើសកម្មភាពក្នុងអង្គការរបស់សមាគមកសិករ គោរពអង្គការវិន័យរបស់សមាគមកសិករ ។

២) ប្តេជ្ញាបង់វិភាគទានជូនបក្សតាមការកំណត់ស្ម័គ្រចិត្តដាច់ខាត ។

៣) ប្តេជ្ញាចូលរួមប្រាស្រ័យជីវភាពសមាគមកសិករ ពង្រីកពង្រឹងឥទ្ធិពលបក្ស តស៊ូសតិអារម្មណ៍ និងអំពើប្រព្រឹត្តដែលមានភាពអន្តរាយដល់កិត្តិនាមរបស់សមាគមកសិករដាច់ខាត ។

៤) ប្តេជ្ញាចិត្តធ្វើការទាក់ទងជិតស្និទ្ធនិងប្រជាជន មហាជន ធ្វើសកម្មភាពក្នុងមហាជន បម្រើមហាជនដោយសកម្មរៀនសូត្រ សួរនាំសិក្សាអំពីមហាជន ។

៥) ប្តេជ្ញាតស៊ូរក្សាការពារឯករាជ្យ សន្តិភាព អព្យាក្រឹត បូរណភាពប្រជាធិបតេយ្យ ជីវភាពសំបូររុងរឿងនិងការពារសន្តិភាពសាកលលោក ។

៦) ប្តេជ្ញាតស៊ូព្យាយាមសិក្សាលើកតម្កើងឲ្យខ្ពស់នូវសមត្ថភាពនយោបាយ ហាត់ពត់លត់ដំ សតិអារម្មណ៍របស់ខ្លួនរៀនសូត្រទ្រឹស្តីនិងមាគ៌ាគោលនយោបាយលទ្ធិម៉ាក្ស-ឡេនីន ។

៧) ប្តេជ្ញាចិត្តរក្សាការសម្ងាត់របស់បក្សហើយរក្សាការពារសាមគ្គីភាពឯកភាពផ្ទៃក្នុងដាច់ខាត ។

៨) ប្តេជ្ញាអនុវត្តធ្វើការទិតៀនស្វ័យទិតៀនខ្លួននិងសមមិត្តដទៃតាមស្មារតីស្នេហាកសាងតាមលាក់ការណ៍សម្ងាត់ ។

# មិនយុត្តិធម៌ក្នុងអយុត្តិធម៌

***តាម៉ុក និង ឌុច ត្រូវបានឃុំឃាំងខ្លួនបណ្តោះអាសន្នអស់រយៈពេលជិត៣ឆ្នាំ ដោយផ្អែកតាមច្បាប់ដែលអនុញ្ញាតឲ្យមានការឃុំឃាំងខ្លួនបែបនេះត្រឹម៣ឆ្នាំ ។ ចំណោទសួរថា ប្រសិនរយៈពេលនៃការឃុំឃាំងខ្លួនធ្វើឡើងគម្រប់៣ឆ្នាំតាមច្បាប់ហើយនោះតើ តាម៉ុក និង ឌុច គួរត្រូវបានដោះលែងឬយ៉ាងណា?***

វាក្យខណ្ឌទី៤ក្នុងមាត្រាទី៣៨នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាចែងថា "ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយឬប្រព្រឹត្តកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំងឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនឲ្យធ្វើឡើយ..." ។ ក្នុងមាត្រាដដែលនេះ ត្រង់វាក្យខណ្ឌទី៦ ក៏បានចែងបន្ថែមទៀតថា "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ" ។ រីឯវាក្យខណ្ឌទី៧និងទី៨សរសេរថា "ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ" និង "ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវច្បាប់" ។ តាមច្បាប់រដ្ឋធម្មនុញ្ញនិងច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាទស្សនាទានច្បាប់ដទៃៗទៀតដែរ ដរាបណាតុលាការមិនទាន់បានធ្វើការជំនុំជម្រះទោសជាស្ថាពរទេនោះ គឺ តាម៉ុក និង ឌុច ត្រូវបានចាត់ទុកជាជនឥតមានទោស ។

តាម៉ុក ដែលមានឈ្មោះផ្សេងៗជាច្រើនទៀតដូចជា ឯក ជឿន, ឈិត ជឿន, តា១៥ ជាប្រធានសេនាធិការយោធារបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា និងមានឈ្មោះល្បីល្បាញនៅភូមិភាគនិរតីក្នុងអំឡុងពេលនៃការកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៧ តាម៉ុក ជាលេខាបក្សប្រចាំភូមិភាគនិរតី និងជាអគ្គមេបញ្ជាការយោធាប្រចាំភូមិភាគនេះ) ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាប់ខ្លួននៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩ ។ ចំណែកឯ ឌុច ដែលមានឈ្មោះដើម កាំង ហ្គិចអៀវ ជាប្រធានមន្ទីរម-១៣អមលាំងក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដែលក្រោយមកទៀតជាប្រធានមន្ទីរស-២១ (ដែលស្គាល់ជាទូទៅថាគុកទួលស្លែង) ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ គឺរំលងបាន៣ខែបន្ទាប់ពីមានការចាប់ខ្លួន តាម៉ុក ។ រហូតមកដល់បច្ចុប្បន្ននេះ តាម៉ុក និង ឌុច មិនទាន់ដែលត្រូវបានតុលាការណាមួយធ្វើការកាត់ទោសនៅឡើយទេហើយកំពុងស្ថិតនៅក្នុងការឃុំឃាំងខ្លួនជាបណ្តោះអាសន្នរបស់តុលាការយោធាទម្រាំមានការកាត់ទោសពីសំណាក់អង្គតុលាការមួយ ។

ផ្អែកលើច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ឡាយព្រហស្តលេខាប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ តាម៉ុក និងឌុច អាចត្រូវបានចាត់ទុកថាជាជនសង្ស័យហើយអាចធ្វើការចោទប្រកាន់ទោស ។ បន្ទាប់ពីពេលនោះមកអ្នកទាំង២ក្លាយជាជនជាប់ចោទរបស់តុលាការនិងត្រូវបានឃុំខ្លួនជាបណ្តោះអាសន្នដើម្បីរង់ចាំការកាត់ទោសពីសំណាក់តុលាការ ។ ដូច្នេះផ្អែកលើមាត្រាទី៣៨នៃរដ្ឋធម្មនុញ្ញ ឬ/និងទស្សនាទានច្បាប់ផ្សេងៗទៀត ក៏ដោយរាល់ការធ្វើសេចក្តីសម្រេចចិត្តខាងវិស័យច្បាប់នៅក្នុងដំណាក់កាលនេះ ដែលពាក់ព័ន្ធត្រង់ៗលើរូប តាម៉ុក និងឌុច ត្រូវផ្តល់ភាពចំណេញដល់អ្នកទាំងពីររូបនេះ ពីព្រោះ តាម៉ុក, ឌុច គឺសុទ្ធតែជាជនជាប់ឃុំឃាំង ហើយបច្ចុប្បន្ននេះកំពុងត្រូវបានឃុំឃាំងនៅក្នុងមន្ទីរឃុំឃាំងនៃតុលាការយោធានៅឡើយ ។ ផ្ទុយទៅវិញ អ្នកទាំងពីរមិនត្រឹមតែមិនបានទទួលនូវភាពចំណេញតែប៉ុណ្ណោះទេ ប៉ុន្តែបែរជាត្រូវទទួលបាននូវការពន្យារពេលការឃុំខ្លួនទៅវិញ ។

ការសុំឲ្យមានការបន្តការឃុំឃាំងលើរូប តាម៉ុក និង ឌុច បានត្រូវធ្វើឡើងម្តងរួចមកហើយ ដោយសារមូលហេតុថា បទបញ្ញត្តិ

ស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌនិងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលអនុញ្ញាតឲ្យមានការឃុំខ្លួនជាបណ្តោះអាសន្នក្នុងរយៈពេលមិនឲ្យលើសពី៤ខែ និងអាចឈានដល់៦ខែប្រសិនបើមានការចាំបាច់សម្រាប់ធ្វើការស៊ើបអង្កេត (មាត្រាទី១៤ វាក្យខណ្ឌទី៤) ។ ការពន្យាពេលនេះស្តែងឲ្យឃើញតាមរយៈសេចក្តីស្នើច្បាប់ស្តីអំពីវិសោធនកម្មមាត្រា១៤នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌនិងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ។ វិសោធនកម្មនេះត្រូវបានរដ្ឋសភាជាតិ អនុម័តនៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ គឺអនុញ្ញាតឲ្យមានការឃុំខ្លួនជាបណ្តោះអាសន្ន ដោយមិនមានការកាត់ទោសរយៈពេលពី៦ខែទៅ៣ឆ្នាំ ចំពោះជនណាដែលត្រូវបានចោទប្រកាន់ពីបទខក្រិដ្ឋកម្មសង្គ្រាម ខក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ រយៈពេលនៃការឃុំខ្លួនរបស់អ្នកទាំងពីរនិងមានរយៈពេលគម្រប់៣ឆ្នាំ នៅដើមឆ្នាំ២០០២ ។ ដូច្នេះ ប្រសិនបើរយៈពេលនៃការឃុំខ្លួនចប់សព្វគ្រប់ក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ខាងលើ តាម៉ុក និង ឌុច មានសិទ្ធិគ្រប់គ្រាន់ក្នុងការស្នើសុំឲ្យតុលាការដោះលែងឲ្យនៅក្រៅឃុំ ។ គ្មានហេតុផលអ្វីនឹងត្រូវធ្វើឡើងដើម្បីបន្តឃុំឃាំង តាម៉ុក និង ឌុច តទៅទៀត ដោយសារថាការពន្យាពេលឃុំឃាំងត្រូវធ្វើម្តងរួចមកហើយ ។ ចំពោះការកាត់សេចក្តីនៅក្នុងដំណើរការរបស់តុលាការយ៉ាងណាៗទៅលើរូបតាម៉ុក និង ឌុច គឺជារឿងបច្ចេកទេសច្បាប់មួយផ្សេងទៀតនៃអង្គតុលាការវិសាមញ្ញមួយដែលសង្ឃឹមថានឹងកើតមានឡើងក្នុងពេលឆាប់ៗខាងមុខនេះ ។


តាម៉ុក


ឌុច

ការសុំពន្យារពេលឃុំឃាំងលើរូប តាម៉ុក និង ឌុច ជាលើកទី២គឺមិនយុត្តិធម៌នៅក្នុងផ្លូវច្បាប់ ។ ក៏ប៉ុន្តែប្រសិនបើមានការដោះលែង តាម៉ុក និង ឌុច វិញនោះ ភាពអយុត្តិធម៌នឹងកើតមានឡើងយ៉ាងធ្ងន់ធ្ងរចំពោះជនរងគ្រោះរាប់លាននាក់ដែលបានស្លាប់បាត់បង់ជីវិតនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យរវាងឆ្នាំ១៩៧៥-៧៩ ។ ជនរងគ្រោះសង្ឃឹមថា ភាគីខាងកម្ពុជានិងភាគីអង្គការសហប្រជាជាតិក៏ដូចជាសហគមន៍អន្តរជាតិដែរនិងឆាប់រួសរាន់ក្នុងការបង្កើតតុលាការមួយដើម្បីធ្វើការវិនិច្ឆ័យទោសទៅលើអំពើឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ ។ ដោយមិនរាប់ទាំងមេដឹកនាំនៃរបបកម្ពុជាប្រជាធិប-តេយ្យដទៃទៀតរួមមាន នួន ជា, អៀង សារី, ខៀវ សំផន និង តាម៉ុក មានវ័យកាន់តែចាស់ហើយ ថែមទាំងមានជំងឺបេះដូង ចំណែកឯ ឌុច ក៏ដូច្នេះដែរគឺមានជំងឺក្អកនិងត្រចៀក ។ បច្ច័យអាក្រក់នៃការគ្មានមេដឹកនាំខ្មែរក្រហមណាម្នាក់ដោយសារការស្លាប់ដោយភាពចាស់ជរា ឬជំងឺ នៅពេលមានតុលាការនឹងអាចកើតមានបាន ។

ប៉ុល ពត ដែលមានឈ្មោះដើមថា សាឡុត ស ជាលេខាបក្សកុម្មុយនិស្តកម្ពុជា និងជាបងលេខ១នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានស្លាប់នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៩៨ ដោយពុំមានបន្សល់ទុកអ្វីបន្តិចបន្តួចសោះសម្រាប់តុលាការ ក៏ប៉ុន្តែបែរជាបន្សល់ទុកនូវភាពស្រពិចស្រពិលដ៏ច្រើនក្រាស់ក្រែលសម្រាប់ប្រជាជនកម្ពុជាក៏ដូចជាសម្រាប់ជនរងគ្រោះរាប់លាននាក់ទៅវិញ ។

**ឆាន់ថាន់ ពៅដារ៉ា**

# តុលាការក្នុងស្រុកឱ្យតែមានបទដ្ឋានយុត្តិធម៌អន្តរជាតិ

***ឆ្លើយតបទៅនឹងអត្ថបទៈ "ច្បាប់ព្រហ្មទណ្ឌអន្តរជាតិគ្មានបំណងជំនួសច្បាប់ព្រហ្មទណ្ឌក្នុងស្រុកទេ" ចុះផ្សាយក្នុងលេខ២៤ ខែធ្នូ ឆ្នាំ២០០១***

***ការពិភាក្សាអំពីដែនសមត្ថកិច្ច (គ្រាន់តែជាទ្រឹស្តី) និងមិនទាក់ទងគ្នា?***

ខ្ញុំមិនយល់ស្របតាមគំនិតនេះទេ ។ តាមពិត ការពិភាក្សាលើប្រធានបទនេះមានការទាក់ទងក្នុងកម្រិតខ្ពស់ណាស់ បើទោះជាប្រធានបទនេះត្រូវស្ថិតនៅក្រោមការសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក៏ដោយ (ការពិតទៅ ជាចំណុចមួយត្រឹមត្រូវដែលថាអង្គជំនុំជម្រះប្រហែលជាមិនអាចដោះស្រាយបញ្ហាបច្ចេកទេសច្បាប់បែបនេះបាន) ។ ហេតុផលមួយក្នុងចំណោមហេតុផលទាំងឡាយដែលថាការពិភាក្សាលើប្រធានបទនេះមានសារសំខាន់ គឺគោលការណ៍គ្រឹះនៃតុលាការព្រហ្មទណ្ឌដែលហាមឃាត់មិនឲ្យជនណាម្នាក់ត្រូវបានកាត់ឲ្យជាប់ទោសពីបទអ្វីមួយដែលមិនមែនជាបទឧក្រិដ្ឋកម្មនៅអំឡុងពេលដែលអំពើនេះត្រូវបានប្រព្រឹត្តឡើង ។ នេះគឺជាបញ្ហាពិសេសមួយនៅក្នុងដំណើរការកាត់ក្តីដែលការព្យាយាមជំនុំជម្រះទៅលើអំពើឃោរឃៅជាលក្ខណៈប្រវត្តិសាស្ត្រ ក្នុងពេលដែលច្បាប់មានការច្របូកច្របល់និងចាំបាច់ត្រូវតែបំភ្លឺបញ្ជាក់ប្រសិនបើវាជាដំណើរការជម្រះក្តីមួយធ្វើឡើងត្រឹមត្រូវតាមនីតិវិធី ។

ការពិភាក្សាដែលលើកមកវែកញែកពីមុននៅលើទំព័រទស្សនាវដ្តីស្វែងរកការពិតលេខ២២និងលេខ២៣ គឺជាការពិភាក្សារវាងបុគ្គលពីររូបដែលប្រកាន់យកគំនិតសត្យានុម័តដោយអានច្បាប់ហើយធ្វើការសាកល្បងមើលទៅលើអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា(លោកស្កាបាស) និងបុគ្គលដែលប្រកាន់យកគំនិតអត្តនោម័តិ ដែលរៀបចំស្ថានការណ៍យ៉ាងប៉ិនប្រសប់ឲ្យចូលទៅក្នុងច្បាប់(លោកស្តែនតុន) ។ អ្នកទាំងពីរនេះសុទ្ធតែមានចេតនាល្អ ហើយយល់ស្របតាមគំនិតរៀងៗខ្លួន ។ ប៉ុន្តែខ្ញុំជឿជាក់ថា ទ្រឹស្តីរបស់លោក ស្កាបាស់ គឺជាទ្រឹស្តីត្រឹមត្រូវ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំចង់ឃើញការពិនិត្យពិច័យប្រកបដោយន័យស្ថាបនាលើការពិភាក្សានៅពេលនេះថាតើយើងចាំបាច់ត្រូវគិតពិចារណាសាជាថ្មីនូវអនុសញ្ញាស្តីអំពីការបង្ការនិងផ្តន្ទាទោស ចំពោះបទឧក្រិដ្ឋកម្មនៃការប្រល័យពូជសាសន៍ដោយគិតពីអាជ្ញាយុកាលច្បាប់ផង ។ ទាំងប្រទេសកម្ពុជានិងទីម័រខាងកើតដែលជាជនរងគ្រោះនៃអ្វីដែលអ្នកមិនសូវមានជំនាញច្បាប់ទម្លាប់ហៅថាអំពើប្រល័យពូជសាសន៍នោះ មានបញ្ហាក្នុងការទាញឲ្យចូលទៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍ ទោះបីជាអ្វីដែលកើតឡើងកន្លងមកមានសភាពធ្ងន់ធ្ងរបែបណាក៏ដោយ ។ លោក រ៉ូមិន ចូហាន់សាន់ (ទស្សនាវដ្តីស្វែងរកការពិតលេខ២៤) ហាក់ដូចជាសន្និដ្ឋានថា ការជ្រើសរើសប្រធានបទអំពីដែនសមត្ថកិច្ចចំពោះតុលាការខ្មែរក្រហមមានន័យថា មានសេចក្តីសម្រេចរួចស្រេចទៅហើយថារឿងរ៉ាវទាំងនេះពិតជាបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ដូច្នេះស្ថិតនៅត្រង់ថា ត្រូវសម្រេចថាតើជនជាប់ចោទត្រូវបានចោទប្រកាន់ចំពោះអ្វីដែលខ្លួនបានប្រព្រឹត្តដែរឬទេ ។ ខ្ញុំសូមមិនគាំទ្រទេ ទោះបីជាខ្ញុំទទួលស្គាល់ថាអ្នកធ្វើសេចក្តីព្រាងច្បាប់យកការយល់ឃើញស្ថានភាពមួយដាក់លាក់ មកដាក់ឲ្យតុលាការក៏ដោយ (ដូចជាការកំណត់ថាឧក្រិដ្ឋកម្មសង្គ្រាមជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ។ អ្នកធ្វើសេចក្តីព្រាងទាំងនោះសម្រេចរួចទៅហើយថាមានជម្លោះប្រដាប់អាវុធរួចទៅហើយ) ។នៅត្រង់ចំណុចនេះជនជាប់ចោទក៏នៅតែអាចបញ្ចេញយោបល់ប្រឆាំងរបស់ខ្លួនចំពោះដែនសមត្ថកិច្ចនេះដែរ ឧទាហរណ៍ដូចជាយកហេតុផលថានៅពេលមានបទល្មើសកើតឡើងអំពើណាមួយនោះមិនមែនជាបទឧក្រិដ្ឋ ហើយមិនអាចយកមកកាត់សេចក្តីបាន ។ តួនាទីរបស់តុលាការគឺសម្រេចដោយឈរលើភ័ស្តុតាងបណ្តឹងដាក់ជូនដោយភាគីនានា ថាតើធាតុផ្សំទូលំទូលាយឬធាតុផ្សំជាក់លាក់ណាខ្លះអាចយកជាការបាន ។ ឧទាហរណ៍នៅពេលពិនិត្យមើលបញ្ញត្តិ

នៃបទល្មើសធ្ងន់ធ្ងរនោះសម្រេចបានថាតើ ១) មានជម្លោះប្រដាប់អាវុធលេខឬទេ ២) ជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិឬទេ ៣) អនុសញ្ញាទីក្រុងហ្សឺណែវដែលយកមកអនុវត្តបានដែរឬទេ ៤) ថាតើមានធាតុផ្សំឲ្យចូលជាបទល្មើសធ្ងន់ធ្ងរដែរឬអត់ ជនរងគ្រោះជាបុគ្គលឬទ្រព្យសម្បត្តិដែលការពារដោយច្បាប់ ជនជាប់ចោទពាក់ព័ន្ធទៅនឹងភាគីមួយ នៅក្នុងជម្លោះដែរឬទេ ។

ដូចគ្នានេះដែរ ការកាត់សេចក្តីត្រូវតែបង្ហាញឲ្យឃើញថាអំពើប្រល័យពូជសាសន៍ពិតជាកើតមានមែននៅក្នុងប្រទេសកម្ពុជា ហើយមានតែពេលនោះទេដែលអាចចោទថាអំពើរបស់ជនជាប់ចោទជាបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។

## ដើមកំណើតនៃគំនិតយល់ឃើញថា ជាអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

លោក រ៉េមិុន ចូហាន់សាន់ និយាយត្រឹមត្រូវថា សម្ព័ន្ធប្រដាប់អាវុធនៅក្នុងនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិគឺជាការប្រឌិត ។ បើគ្មានការផ្សារភ្ជាប់ទៅនឹងជម្លោះប្រដាប់អាវុធ (នៅពេលដែលច្បាប់សង្គ្រាមអាចអនុវត្តបាន និងពេលដែលច្បាប់នេះមិនសូវមានការចម្រូងចម្រាស) ម៉្លេះសមបទឧក្រិដ្ឋកម្មជាច្រើនដែលត្រូវបានប្រព្រឹត្តមកលើជនជាតិជ្វីហ្វ និងជនស៊ីវិលអាល្លឺម៉ង់ ត្រូវបានចាត់ទុកថាស្ថិតនៅក្នុងដែនសមត្ថកិច្ចក្នុងស្រុករបស់រដ្ឋអាល្លឺម៉ង់រួចស្រេចទៅហើយ មិនមែនជារឿងរបស់អ្នកណាក្រៅពីនេះទៀតទេ ។ ជាក់ស្តែងឃើញថា ការចោទប្រកាន់អំពីបទសម្លាប់រង្គាលគឺជាផ្នែកតូចមួយនៃបណ្តឹងប្រឆាំងនឹងថ្នាក់ដឹកនាំ ។ ការទាញភ្ជាប់ទៅនឹងជម្លោះប្រដាប់អាវុធបានធ្វើឲ្យអំពើនេះក្លាយជាកិច្ចការរបស់រដ្ឋដទៃទៀត ហើយធ្វើឲ្យបទឧក្រិដ្ឋកម្មត្រូវបានកាត់សេចក្តីដោយរដ្ឋនានា ដែលផ្ទុយទៅវិញបែរជារំលោភគោលការណ៍ដ៏សំខាន់នៃអធិបតេយ្យភាពក្នុងស្រុក ។ ជាទូទៅមានការទទួលស្គាល់ថា សម្ព័ន្ធបែបនេះរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាមត្រូវតែជាដែនសមត្ថកិច្ចរបស់តុលាការនៅនូរិមប៊ឺក ។ សម្ព័ន្ធនេះមិនត្រូវបានយកមកប្រើឡើយ នៅក្នុងច្បាប់ទម្លាប់អន្តរជាតិពោលគឺវាបានបាត់ស្រមោលពីនិយមន័យ នៅក្នុងមាត្រាទីII (១)(c) នៃច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ។ ប្រសិនបើបុគ្គលម្នាក់ទទួលស្គាល់អំពើប្រល័យពូជសាសន៍ថាជាប្រភេទមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ វាមានការទាក់ទងគ្នាតាំងពីឆ្នាំ១៩៤៨ ដែលឧក្រិដ្ឋកម្មនេះមិនត្រូវបានយល់ឃើញថាមានសម្ព័ន្ធភាពជាមួយនឹងជម្លោះប្រដាប់អាវុធ ។ វាហាក់ដូចជាថានៅត្រឹមឆ្នាំ១៩៧៥ សម្ព័ន្ធភាពនេះមិនមែនស្ថិតក្នុងលក្ខណៈសម្បត្តិជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមច្បាប់ទម្លាប់អន្តរជាតិទេ ដោយសំអាងលើការអនុវត្តជាក់ស្តែងរបស់រដ្ឋនិងគំនិតរបស់ក្រុមប្រឹក្សាអ្នកច្បាប់ ។ ប៉ុន្តែលោក ស្កាបាស់ និយាយត្រឹមត្រូវដែលថា នៅក្នុងអំឡុងឆ្នាំ១៩៤៥ដល់ឆ្នាំ១៩៩៣ សម្ព័ន្ធ (ជម្លោះប្រដាប់អាវុធ) មិនត្រូវបានយកមកអនុវត្តទេ ។ បញ្ហានេះវាអាស្រ័យទៅលើតុលាការជាអ្នកសម្រេចថាវានៅតែជាធាតុផ្សំនៃបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឬយ៉ាងណានៅក្នុងអំឡុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ។ ដូច្នេះបើតាមគំនិតខ្ញុំ វាហាក់ដូចជាគ្មានប្រយោជន៍អ្វីមកជាប់គាំងលើបញ្ហានេះ ឬក៏ថាមូលហេតុអ្វីបានជានិយាយដល់ធម្មនុញ្ញតុលាការសឹកអន្តរជាតិទៅវិញ ។

អំពើប្រល័យពូជសាសន៍គឺជាបទឧក្រិដ្ឋកម្មមានជារូបរាងឡើងក្រោយពេលការបង្កើតអនុសញ្ញាអំពើប្រល័យពូជសាសន៍ ហើយត្រូវបានលើកមកជំនុំជម្រះលើកទីមួយប្រកបដោយជោគជ័យ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិដែលបង្កើតឡើងសម្រាប់ប្រទេសរ៉្វាន់ដា ក្នុងរឿងក្តីរបស់អាកាយេស៊ូ ឆ្នាំ១៩៩៧-១៩៩៨ ។ និយមន័យនេះត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលមួយមុនសង្គ្រាមត្រជាក់ដែលមានសន្ទុះខ្លាំង និងនៅពេលដែលពិភពលោកកំពុងតែព្រះពារស្វែងយល់ពីនៃទំហំអំពើឃោរឃៅប្រព្រឹត្តដោយពួកណាហ្ស៊ី និងសម្រេចចិត្តទប់ស្កាត់កុំឲ្យអំពើនេះកើតឡើងសាជាថ្មី ។ អំពើប្រល័យពូជសាសន៍ត្រូវបានបង្កើតឡើងក្នុងការសំដៅលើការសម្លាប់មនុស្ស ពោលគឺអ្វីដែលបានកើតឡើងនៅអំឡុងពេលនៃការសម្លាប់រង្គាល ។ លោក រ៉េមិុន ចូហាន់សាន់ ត្រូវតែប្រយ័ត្នប្រយែងក្នុងការភ្ជាប់អំពើប្រល័យពូជសាសន៍ទៅនឹងវិវឌ្ឍន៍នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈធម្មនុញ្ញតុលាការនិងយោធាអន្តរជាតិវិនិច្ឆ័យ ។ ខ្ញុំមិនហៅថា

នេះជាការឲ្យនិយមន័យតាមនិន្នាការនយោបាយទេ ប៉ុន្តែសូមហៅថាជានិយមន័យដែលកើតចេញដោយផ្ទាល់ពីបទពិសោធន៍សង្គ្រាម និងឆ្លុះបញ្ចាំងពីវិវឌ្ឍន៍នៃហេតុការណ៍ជាក់ស្តែងតាមពេលវេលា ។ អ្វីដែលយើងគួរតែពិនិត្យមើលគឺថា តើពេលវេលានេះជាពេលត្រឹមត្រូវក្នុងការពិចារណាថានឹងត្រូវពិនិត្យទៅលើអនុសញ្ញាប្រល័យពូជសាសន៍ដែរឬយ៉ាងណា ។

## ការដណ្តើមយកដែនសមត្ថកិច្ចរបស់តុលាការក្នុងស្រុក

ដោយផ្អែកលើទស្សីករណ៍របស់លោក វ៉េមិន ចូហាន់សាន់ ហាក់ដូចជាមានជំនឿថា សហគមន៍អន្តរជាតិមានបំណងចង់ "លួច" ដែនសមត្ថកិច្ចរបស់តុលាការក្នុងស្រុក ។ ប៉ុន្តែតាមពិតមិនមែនដូច្នេះទេ ។ ឯកសារកំណត់ប្រវត្តិដែលមិនបានផលល្អស្តីពីយុត្តិធម៌ ក្រោយពីមានតុលាការនៅនូរិមប៊ឺកបង្ហាញនូវហេតុការណ៍ពិតនៃការមិនអើពើនិងការខកខានមិនបានដោះស្រាយ ទោះបីជាមានបទឧក្រិដ្ឋកម្មដ៏អាក្រក់កើតឡើងជាក់ស្តែងក៏ដោយ ។ មានតែតុលាការព្រហ្មទណ្ឌអន្តរជាតិពិសេស២ប៉ុណ្ណោះ ដែលត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិហើយតុលាការទាំងពីរទទួលស្គាល់នូវតួនាទីដូចគ្នារបស់តុលាការក្នុងស្រុក ទោះបីជាតុលាការនេះមានអាទិភាពក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួនក៏ដោយ ។ ទាំងតុលាការព្រហ្មទណ្ឌបង្កើតឡើងសម្រាប់ប្រទេសយូហ្គោស្លាវីនិងសម្រាប់ប្រទេសរ៉្វាន់ដា មិនបានប្រានចោលអង្គជំនុំជម្រះក្រោមច្បាប់ក្នុងស្រុកទេ ។ នៅប្រទេសបូស្នៀមានផែ្ទរឿងមួយមានឈ្មោះថា *"Rules of the Road"* ដែលសភាចារបុរសអនុម័តយល់ព្រមតាមបណ្តឹងទាមទារឲ្យមានការជំនុំជម្រះក្នុងស្រុក(ក្រមព្រហ្មទណ្ឌរបស់ប្រទេសបូស្នៀទទួលស្គាល់ឧក្រិដ្ឋកម្មសង្គ្រាម) ។ មន្ទីរឃុំឃាំងនៅប្រទេសរ៉្វាន់ដាមានមនុស្សណែនណាន់តាន់តាប់រង់ចាំការជម្រះក្តីដោយតុលាការក្នុងស្រុក ។ មកដល់សព្វថ្ងៃនេះមានតែតុលាការមួយគត់ដែលដំណើរការជាលក្ខណៈចម្រុះ ពោលគឺតុលាការក្នុងស្រុកដែលមានលក្ខណៈអន្តរជាតិ ។ តុលាការនេះមានការិយាល័យនៅស្រុកឌីលីនៃប្រទេសទីម័រខាងកើត ។ តុលាការអន្តរជាតិត្រូវបានស្ថាបនាឡើងតាមទស្សនៈសម្រាប់បង្គ្រប់ ពោលគឺតុលាការក្នុងស្រុកជាកន្លែងឈប់សំចតទីមួយ ។ ប្រសិនបើតុលាការទាំងនេះមិនអាចឬមិនចង់បំពេញកាតព្វកិច្ចជាអន្តរជាតិ ហើយមានជាប់លក្ខខណ្ឌក្នុងលក្ខន្តិកៈនេះ តុលាការអន្តរជាតិអាចអនុវត្តដែនសមត្ថកិច្ចរបស់ខ្លួនបាន ។

នៅជិតចុងបញ្ចប់នៃអត្ថបទពិភាក្សា លោក វ៉េមិន ចូហាន់សាន់ បាននិយាយបញ្ចិតបញ្ចៀងទៅនឹងព្រឹត្តិការណ៍ថ្ងៃទី ១១ ខែកញ្ញា (នៅសហរដ្ឋអាមេរិក) ។ ខ្ញុំគិតថា នេះពិតជាអ្វីដែលលោកបានសរសេរខ្លួនឯងជាជាងរឿងកម្ពុជាជាក់ស្តែង ។ ការអំពាវនាវឲ្យមានដំណោះស្រាយ ករណីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរក្នុងក្របខ័ណ្ឌអន្តរជាតិ តែងតែមានកម្លាំងខ្លាំងជាងនៅពេលដែលមានការព្រួយបារម្ភអំពីអសមត្ថភាពឬអចេតនារបស់រដ្ឋក្នុងការបំពេញការទទួលខុសត្រូវតាមផ្លូវច្បាប់នៅក្នុងស្រុក ។ គ្មានអ្នកណាម្នាក់បដិសេធទេថា សហរដ្ឋអាមេរិកមានដែនសមត្ថកិច្ចនិងសិទ្ធិក្នុងការកាត់ទោសជនទាំងឡាយណាដែលមានការពាក់ព័ន្ធនឹងការវាយប្រហារដ៏អាក្រក់នៅថ្ងៃទី១១ ខែកញ្ញា ។ ប៉ុន្តែលោក វ៉េមិន ចូហាន់សាន់ ចាំបាច់ត្រូវតែស្វែងយល់ពីមូលហេតុថាអ្នកសង្កេតការណ៍មួយចំនួនមានទំនោរទៅរកទម្រង់តុលាការអន្តរជាតិសម្រាប់កាត់ទោស អូសា្ម ប៊ីនឡាដិន និងក្រុមភេរវករបស់អូសា្ម ។ អាមេរិកាំងនិងច្បាប់របស់ខ្លួនដែលអនុម័តរួចហើយបានថ្កោលទោសបុគ្គលម្នាក់នេះ ហើយជាលទ្ធផល ប៊ីនឡាដិនត្រូវបានកាត់ឲ្យជាប់ទោសនៅក្នុងគំនិតសាធារណជនទូទៅ ។ ប្រជាជាតិមូស្លីមជាច្រើនជឿជាក់ថា អាមេរិកាំងកំពុងតែធ្វើទុក្ខបុកម្នេញមកលើជនជាតិមូស្លីម ហើយនឹងសងសឹកវិញតាមរយៈការផ្តន្ទាទោសជនទាំងឡាយណាដែលគ្រាន់តែការពារមិនឲ្យមានការវាយប្រហារមកលើប្រទេសរបស់ខ្លួន ។ ម្នាក់ៗគិតតែពីបើកទូរទស្សន៍ស៊ី.អិន.អិន និងស្តាប់អ្នករាយការណ៍ពត៌មាន ស្តាប់មេដឹកនាំអាមេរិកាំងនិងសាធារណជនទូទៅ ដើម្បីទាញយកនូវការគិតមួយថា មូលហេតុអ្វីបានជាមានបុគ្គលមួយចំនួនមានអារម្មណ៍ថា អាចមានបញ្ហាពិតប្រាកដទាក់ទងនឹងការជម្រះក្តីនៅលើទឹកដីអាមេរិកាំង ។

## តើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានលក្ខណៈធ្ងន់ធ្ងរជាងឧក្រិដ្ឋកម្មក្នុងស្រុកឬ?

លោក វ៉េមិន ចូហាន់សាន់ និយាយត្រូវថា មនុស្សឃាត

ទ្រង់ទ្រាយធំគឺ (និងតែងតែជា) ការរំលោភច្បាប់ក្នុងស្រុកជានិច្ច ។ នេះជារឿងពិតដែលមិនអាចប្រកែកបាន ។ ហេតុដូច្នេះហើយបានជាច្បាប់ក្នុងស្រុកមាននៅក្នុងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ ទន្ទឹមគ្នានេះដែរក៏មានការទទួលស្គាល់អធិបតេយ្យភាពជាតិ ហើយនឹងមានការដើរថយក្រោយ ប្រសិនបើសាលាកាត់ក្តីមិនអាចបង្ហាញថាមានឧក្រិដ្ឋកម្មអន្តរជាតិទេនោះ ។ ប៉ុន្តែបញ្ហាវានៅត្រង់ថា តើបទឧក្រិដ្ឋមួយចំនួនអាក្រក់គួរឲ្យខ្លាចរហូតដល់គេគិតថាត្រូវតែចាត់ឲ្យនៅក្នុងកម្រិតដាច់ដោយឡែកពីបទឧក្រិដ្ឋដទៃទៀត ហើយដាក់ឲ្យមានការជម្រះក្តីដោយរដ្ឋឬអង្គតុលាការអន្តរជាតិឬយ៉ាងណា ។

លោក រ៉ែមុិន ចូហាន់សាន់ យល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មានកម្រិតធ្ងន់ធ្ងរជាងឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងស្រុក ។ លោកនិយាយខុសថា មានតែអ្នកជំនាញច្បាប់និងអ្នកដែលមាននាទីប្រហាក់ប្រហែលគ្នានេះដែលមានគំនិតថាមានបទឧក្រិដ្ឋខ្លះមានលក្ខណៈធ្ងន់ធ្ងរជាងឧក្រិដ្ឋកម្មផ្សេងៗទៀត ។ មានគំនិតជាយូរមកហើយថា បទឧក្រិដ្ឋមួយចំនួនធ្វើឲ្យមនុស្សជាតិតក់ស្លុតរហូតដល់ប៉ះពាល់លើសពីដែនសមត្ថកិច្ចជាប្រពៃណីនៃអធិបតេយ្យភាពរបស់រដ្ឋ ហើយទាមទារឲ្យមានការទទួលខុសត្រូវពីសំណាក់សហគមន៍អន្តរជាតិទាំងមូល ។ មានឧទាហរណ៍ជាក់ស្តែងជាច្រើន ។ ការធ្វើអន្តរាគមន៍បែបមនុស្សធម៌បានកើតឡើងដើម្បីជាការឆ្លើយតបទៅនឹងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សប្រព្រឹត្តឡើងនៅលើទឹកដីរបស់គ្រិស្តសាសនិកដែលកាន់កាប់ដោយពួកអូតូម៉ែន ហើយអធិបតេយ្យរបស់រដ្ឋត្រូវស្ថិតនៅក្រោមការបង្គាប់បញ្ជា ទោះបីជាទង្វើនេះកើតមានដោយបណ្តោះអាសន្នយ៉ាងណាក៏ដោយ ។ ក្រោយសង្គ្រាមលោកលើកទី១ ចក្រភពអង់គ្លេសមានការប៉ុនប៉ងជំនុំជម្រះក្តីអំពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅប្រទេសទួរគី ក្នុងករណីការសម្លាប់រង្គាលលើជនជាតិអាមេនាន ប៉ុន្តែគម្រោងការនេះត្រូវបានបោះបង់ចោលទៅវិញ ។ យើងទាំងអស់គ្នាពិតជាដឹងអំពីសង្គ្រាមលោកលើកទី២ និងតុលាការយោធានៅនូរិមប៊ឺកសម្រាប់ជំនុំជម្រះបទឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ក្រោយមកទើបមានអនុសញ្ញាស្តីអំពីការបង្ការនិងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋកម្មនៃការប្រល័យពូជសាសន៍និងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ ជាការច្បាស់ណាស់ថាវាជាច្បាប់អន្តរជាតិ ដែលចាត់ទុកបទឧក្រិដ្ឋកម្មមួយចំនួនថាមានលក្ខណៈធ្ងន់ធ្ងរនិងគួរតែត្រូវបានសហគមន៍អន្តរជាតិផ្តោតការយកចិត្តទុកដាក់ មិនមែនដូចអ្នកសិក្សាស្រាវជ្រាវមួយចំនួនបានលើកឡើងតាមតែនឹកឃើញខុសពីគេឯងនោះទេ ។

ដូច្នេះឃើញថាតើអ្វីទៅជាបទឧក្រិដ្ឋអន្តរជាតិ? ជាបទឧក្រិដ្ឋកម្មលើសពីឧក្រិដ្ឋកម្មក្នុងស្រុក និងចូលក្នុងនិយមន័យច្បាប់ទម្លាប់អន្តរជាតិឬអនុសញ្ញាអន្តរជាតិ ។ បទឧក្រិដ្ឋកម្មប្រភេទនេះមានលក្ខណៈធ្ងន់ធ្ងររហូតដល់បណ្តាលឲ្យមានផលវិបាកតាមផ្លូវច្បាប់សម្រាប់រដ្ឋ ។ ផលវិបាកទី១ គឺដែនសមត្ថកិច្ចសកល ។ នៅពេលមានបទឧក្រិដ្ឋកម្មអន្តរជាតិកើតឡើងដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋ-កម្មសង្គ្រាម (រដ្ឋទាំងអស់រួមទាំងរដ្ឋដែលមានករណីនេះកើតឡើងផង) មានកាតព្វកិច្ចស៊ើបអង្កេត នាំយកជនសង្ស័យមកជំនុំជម្រះទោស ឬផ្តន្ទាទោសទៅតាមដែនសមត្ថកិច្ចរបស់ផងខ្លួនទាក់ទងនឹងបទឧក្រិដ្ឋកម្មទាំងនោះ ឬធ្វើបត្យាប័នប្រគល់ជនសង្ស័យទាំងនេះទៅឲ្យរដ្ឋមួយទៀតដើម្បីយកទៅកាត់ទោស ។ ការបកស្រាយគំនិតជាមូលដ្ឋាននេះជំរុញឲ្យរដ្ឋចង់"ចូលរួមធ្វើកិច្ចការរបស់ខ្លួន" ដោយស្វែងរកចាប់ខ្លួនជនសង្ស័យនៅក្នុងប្រទេសដែលមិនបាន"ធ្វើកិច្ចការរបស់ខ្លួន"ទាល់តែសោះនោះ ។ ជនទាំងឡាយណាដែលត្រូវបានចោទថាបានប្រព្រឹត្តបទឧក្រិដ្ឋកម្មអន្តរជាតិអាចត្រូវបានចាប់ខ្លួននិងកាត់ទោសដោយរដ្ឋណាក៏បាន ។ តាមការពិត រដ្ឋនានាមានកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការចាត់វិធានការ ។ វិធានការនេះមិនមែនធ្វើឡើងចំពោះមនុស្សឃាតធម្មតានោះទេ (ទោះជាមនុស្សឃាតមានទំហំធំយ៉ាងណាក៏ដោយ) ដែលត្រូវបានសំអាងទៅលើការយល់ឃើញថាជនជាប់ចោទនឹងត្រូវយកមកកាត់ទោសនៅក្នុងរដ្ឋដែលមានដែនសមត្ថកិច្ច ហើយថាការចាប់ខ្លួនជនជាប់ចោទនឹងត្រូវស្ថិតនៅក្រោមការគ្រប់គ្រងតាមវិធានការស្តីពីកិច្ចសហប្រតិបត្តិការអន្តររដ្ឋនៅក្នុងច្បាប់ស្តីអំពីការបង្ការនិងការធ្វើបត្យាប័ន ។ សភាពការណ៍បច្ចុប្បន្ននេះ

មានភាពស្មុគស្មាញដោយសារអង្គច្បាប់អន្តរជាតិដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិពិសេសដែលក្នុងនោះគ្មានបុគ្គលណាម្នាក់អាចធ្វើបត្យាប័នបានឡើយ ប៉ុន្តែអាច«ផ្ទេរ»បុគ្គលណាមួយទៅឲ្យតុលាការដើម្បីជំនុំជម្រះទោស ។ ការធ្វើរបៀបនេះវាអាចទៅរួច ក៏ប៉ុន្តែគួរតែច្បាស់លាស់ថា អង្គច្បាប់ទាំងនេះមិនត្រូវបដិសេធការអនុវត្តដែនសមត្ថកិច្ចរបស់តុលាការជាតិទេ ។

លោក វ៉េម៉ិន ចូហាន់សាន់ ហាក់ដូចជាមិនទទួលស្គាល់ថា យុត្តិធម៌អន្តរជាតិមិនមានន័យថាត្រូវតែមានតុលាការអន្តរជាតិឡើយ ។ មានន័យថារដ្ឋនានាចាំបាច់ត្រូវតែអនុវត្តតាមកាតព្វកិច្ចរបស់ផងខ្លួនចំពោះគ្នាទៅវិញទៅមក ដើម្បីចូលរួមថែរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិដោយប្រើច្បាប់ក្នុងស្រុកទប់ទល់ជាមួយបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរទាំងនេះ ។ អង្គតុលាការអន្តរជាតិទាំងនេះលេចរូបរាងឡើងដោយសារអសមត្ថភាពឬអចេតនារបស់រដ្ឋដែលមិនបានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួន ។ ចំពោះការឲ្យយោបល់ថា បទឧក្រិដ្ឋអន្តរជាតិមិនដែលត្រូវបានយកមកជំនុំជម្រះនៅក្នុងតុលាការអន្តរជាតិនោះ ខ្ញុំសូមរំឭកលោក វ៉េម៉ិន ចូហាន់សាន់ ឲ្យចាប់អារម្មណ៍ទៅលើប្រការទាំងឡាយដែលចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ស្តីអំពីបែបបទតម្រូវឲ្យភាគីផ្លាស់សម្រួលច្បាប់របស់ខ្លួនដើម្បីយកអនុវត្តឲ្យបានត្រឹមត្រូវ ហើយការកាត់ទោសជាឧបករណ៍សំខាន់ក្នុងការធានាការគោរពច្បាប់មនុស្សធម៌អន្តរជាតិ ។ ថែមពីលើនេះទៀត ខ្ញុំក៏សូមកត់សម្គាល់ថា អំពើប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទារុណកម្ម និងឧក្រិដ្ឋកម្មសង្គ្រាម កំពុងតែបានយកមកជំនុំជម្រះក្នុងតុលាការក្នុងស្រុកកាន់តែច្រើនឡើងៗ ។ ឧទាហរណ៍ ឧក្រិដ្ឋជនសង្គ្រាមនៅតំបន់បាល់កង់ត្រូវបានយកមកកាត់ទោស មិនត្រឹមតែនៅតំបន់បាល់កង់នោះទេ ប៉ុន្តែប្រទេសផ្សេងៗទៀត ក៏គេយកធ្វើជាកន្លែងជម្រះទោសឧក្រិដ្ឋជនទាំងនេះដែរ ដូចជានៅតុលាការក្នុងស្រុករបស់ប្រទេសស្វ៊ីស ប្រទេសន័រវេ ប្រទេសអាល្លឺម៉ង់និងប្រទេសហូល្លង់ ។ នេះគ្រាន់តែរាប់ជាត្រួសៗប៉ុណ្ណោះ ។ ជនជាតិអេស្ប៉ាញល្បីឈ្មោះដោយសាររឿងក្តីឧត្តមសេនីយ៍ពីណូចេ ។ ប្រជាជនបែលហ្ស៊ិកបានកាត់ទោសពួកប្រល័យពូជសាសន៍មកពីប្រទេសរ៉្វាន់ដា ហើយឥឡូវនេះល្បីដោយសារតាមធ្វើក្តីឬកាត់ទោស អារៀលសារ៉ូន ក្នុងករណីសម្លាប់រង្គាលនៅសាប្រានិងសាធីលឡា ។ ខ្ញុំក៏សូមសង្កត់ធ្ងន់បន្ថែមដែរថា ច្បាប់ក្នុងស្រុកត្រូវបានអនុវត្តនៅតំបន់ដែលស្ថិតក្រោមការត្រួតត្រានៅប្រទេសអាល្លឺម៉ង់ ។ ប្រជាជនកាណាដាយកច្បាប់កាណាដាមកប្រើ ចំណែកឯជនជាតិអង់គ្លេសប្រើព្រះរាជដីកាឆ្នាំ១៩៤៥ ដែលមាននិយតកម្មភ្ជាប់ជាមួយច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ដែលគេយកមកប្រើប្រាស់នៅសហរដ្ឋអាមេរិកយកតាមធម្មនុញ្ញតុលាការយោធាអន្តរជាតិមួយភាគធំ ។ តុលាការអាល្លឺម៉ង់ប្រើច្បាប់អាល្លឺម៉ង់ក្នុងការកាត់ទោសឧក្រិដ្ឋជនសង្គ្រាមជនជាតិអាល្លឺម៉ង់ ។ ប្រជាជនអ៊ីស្រាអែលប្រើច្បាប់ក្នុងស្រុកក្នុងការកាត់ទោស អាដុល្ហ អេចក្មាន់ ។ល ។

## លំដាប់ថ្នាក់បទឧក្រិដ្ឋកម្មអន្តរជាតិ

នេះជាប្រធានបទអាចមានការចម្រូងចម្រាស ។ អ្នកខ្លះយល់ថាការឈ្លានពាននៅលើគេ បន្ទាប់មកអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយចុងក្រោយគឺឧក្រិដ្ឋកម្មសង្គ្រាម ។ មានអ្នកផ្សេងទៀតនិយាយថា ការចូលទៅដល់ដំណើរការរាប់ចំនួនជនរងគ្រោះនិងកំណត់កម្រិតឈឺចាប់ រួចហើយកំណត់ពីចំណាត់ថ្នាក់បទឧក្រិដ្ឋទី១ ទី២ ពិតជាមិនមានសីលធម៌ឡើយ ។ មានអ្នកខ្លះនិយាយថា សញ្ញាណគំនិតចាត់ថ្នាក់ឧក្រិដ្ឋកម្មបែបនេះមិនមានបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រអន្តរជាតិទេ ។ ផ្ទុយមកវិញ មានអ្នកខ្លះទៀតយល់ថាមាននៅក្នុងយុទ្ធសាស្ត្រអន្តរជាតិ ។ មានការពិភាក្សាល្អមួយចំនួនទៅលើបញ្ហានេះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិបង្កើតឡើងសម្រាប់ប្រទេសយូហ្គោស្លាវី ជាពិសេសទាក់ទងទៅនឹងការដែលថាតើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានកម្រិតធ្ងន់ធ្ងរជាងឧក្រិដ្ឋកម្មសង្គ្រាមដែរ ឬយ៉ាងណា ។

វាហាក់ដូចជាបញ្ហាមួយដែលមានរូបរាងជាទ្រឹស្តី ក៏ប៉ុន្តែតាមការពិតវាមានសារសំខាន់ ជាពិសេសនៅពេលដែលតុលាការពិចារណាទៅដល់ការវិនិច្ឆ័យទោស ។

## តើតុលាការអន្តរជាតិអាចប្រើច្បាប់ក្នុងស្រុកដែរឬទេ? តើតុលាការក្នុងស្រុកអាចប្រើច្បាប់អន្តរជាតិដែរឬទេ?

ដោយស្ថិតនៅក្រោមប្រព័ន្ធច្បាប់អន្តរជាតិ តុលាការ

និងសាលាក្តីអន្តរជាតិអាចអនុវត្តបានតែច្បាប់អន្តរជាតិតែប៉ុណ្ណោះ ។ តុលាការនិងសាលាជម្រះក្តីនេះពិតជាទទួលបានសេចក្តីណែនាំពីច្បាប់ក្នុងស្រុកនៅក្នុងស្ថានការណ៍មួយចំនួន ប៉ុន្តែអាចទទួលបានដោយការប្រយ័ត្នប្រយែង ដោយសារវិធានទាំងនោះមិនអាចផ្ទេរកន្លែងចូលទៅក្នុងឆាកអន្តរជាតិទេ ។ ដូច្នេះចៅក្រមតុលាការអន្តរជាតិត្រឹមតែមើលបទឧក្រិដ្ឋអន្តរជាតិ និងពាក្យយល់ស្របក្នុងការស្នើមតិអ្វីមួយប៉ុណ្ណោះ ដែលការណ៍នេះបង្ហាញថាបទឧក្រិដ្ឋអន្តរជាតិពិតជាត្រូវបានចាត់ទុកថាជាប្រភេទនៃបទឧក្រិដ្ឋពិសេសដែលសមតែទទួលរបបពិសេស ។ ប៉ុន្តែនៅពេលដែលយើងឈានដល់ដំណាក់កាលបែបនេះ ហើយនោះស្ថានការណ៍ដែលបាននាំទៅដល់បទឧក្រិដ្ឋដែលកំពុងតែត្រូវបានប្រព្រឹត្តនឹងត្រូវក្លាយជាស្ថានការណ៍ដ៏ធ្ងន់ធ្ងរមួយរួចជាស្រេចទៅហើយ ពោលគឺជាទូទៅស្ថានការណ៍ដែលនាំដល់ការបង្កើតតុលាការជាវិធានការស្តារឡើងវិញនូវសន្តិភាពនិងសន្តិសុខអន្តរជាតិ ។

ការពិនិត្យទៅលើតុលាការក្នុងស្រុកដោយកាត់សេចក្តីបទឧក្រិដ្ឋអន្តរជាតិ បង្ហាញថាតុលាការភាគច្រើនពិនិត្យច្បាប់អន្តរជាតិនិងយុទ្ធសាស្ត្ររបស់ខ្លួននៅក្នុងសំណុំរឿងដែលមានចំពោះមុខ ។ ប៉ុន្តែភាគច្រើនគឺអាស្រ័យទៅលើគុណសម្បត្តិរបស់ចៅក្រម ហើយជាទូទៅវាលម្អៀងទៅរកគំនិតក្នុងស្រុកនិងបញ្ញត្តិនានា ដោយសារច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅតែស្ថិតនៅក្នុងដំណាក់កាលមួយកំពុងមានការវិវឌ្ឍន៍ ។ អ្វីដែលមានលក្ខណៈច្បាស់គឺថា សេចក្តីសង្ឃឹមដែលចេះតែកើនឡើងកំពុងតែត្រូវបានផ្អែកទៅលើយុទ្ធសាស្ត្រប្រសូត្រចេញពីតុលាការអន្តរជាតិបង្កើតឡើងសម្រាប់ប្រទេសរ៉្វាន់ដានិងប្រទេសយូហ្គោស្លាវី ។ តែងតែមានការរិះគន់មិនពេញចិត្តអំពីការជំនុំជម្រះក្នុងស្រុកដែលមិនសូវមានយុត្តិធម៌ត្រឹមត្រូវ ។ ពេលខ្លះតុលាការផ្តល់យុត្តិធម៌ ប៉ុន្តែជួនកាលមិនផ្តល់យុត្តិធម៌ទេ ។ ជនរងគ្រោះនៃអំពើឃោរឃៅអាចនឹងចូលចិត្តដំណើរការតុលាការអន្តរជាតិដូចដែលលោក រ៉េមិុន ចូហាន់សាន់ បានលើកឡើងដែរ ពីព្រោះគេយល់ថាតុលាការអន្តរជាតិនឹងផ្តល់យុត្តិធម៌ “ប្រសើរជាង” ។ ស្ថិតនៅក្រោមដំណើរការជំនុំជម្រះក្តីអន្តរជាតិ ទើបទទួលបាននូវកម្រិតអន្តរជាតិ ។ ខ្ញុំសូមឲ្យយោបល់ថា សិទ្ធិត្រូវបានការពារជាទូទៅនៅក្នុងដំណើរការជំនុំជម្រះក្តីជាលក្ខណៈអន្តរជាតិ ។ ប្រសិនបើមានតុលាការជម្រះក្តីក្នុងស្រុកគឺប្រហែលដោយសារតែវាជាវិធីទៅរួចតែមួយដែលអាចផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនៃអំពើឃោរឃៅ ។ ការមិនធ្វើទូទៅនីយកម្មលើបទដ្ឋានយុត្តិធម៌ក្នុងស្រុកដែលមានការខុសប្លែកគ្នាដាច់ស្រឡះពីមួយទៅមួយនោះ វានឹងធ្លាក់ចូលដល់ការជំនុំជម្រះក្តីដោយតុលាការក្នុងស្រុកជាមិនខាន ឬគ្មានការជំនុំជម្រះអ្វីទាំងអស់ ។ យុត្តិធម៌អន្តរជាតិកម្រមានណាស់នៅក្នុងបរិបទថាៈ តើមានការកាត់ឲ្យជាប់ទោសប៉ុន្មាននាក់ និងការឲ្យរួចខ្លួនពីការចោទប្រកាន់ប៉ុន្មាននាក់ ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិបង្កើតឡើងសម្រាប់ប្រទេសយូហ្គោស្លាវីនិងប្រទេសរ៉្វាន់ដាអាចយកកាត់ក្តីបាន ឲ្យសមនឹងជនរងគ្រោះរាប់លាននាក់ដែលកូនក្តីបានប្រព្រឹត្តមកលើនោះ? ។

ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថា អត្ថិភាពនៃអង្គច្បាប់អន្តរជាតិដែលមានដែនសមត្ថកិច្ច មិនមែនមានន័យថាដែនសមត្ថកិច្ចក្នុងស្រុករបស់រដ្ឋអធិបតេយ្យនៅក្រោមបង្គាប់នោះទេ ។ ជាទូទៅ តុលាការអន្តរជាតិត្រូវបានបង្កើតឡើងសម្រាប់កាត់ទោសមេដឹកនាំនិងជនទាំងឡាយណាដែលមានការទទួលខុសត្រូវខ្ពស់បំផុត នៅក្នុងកាលៈទេសៈដែលរដ្ឋនោះមិនអាចឬក៏គ្មានឆន្ទៈចង់ធ្វើការស៊ើបអង្កេត កាត់ទោស និងផ្តន្ទាទោស ។ យើងកំពុងតែនិយាយអំពីបទឧក្រិដ្ឋដែលមានលក្ខណៈជាសាកលនិងមានផលប្រយោជន៍លើសពីផលប្រយោជន៍របស់រដ្ឋ ។ នៅក្នុងស្ថានការណ៍បែបនេះ សិទ្ធិអធិបតេយ្យភាពរបស់រដ្ឋមិនអាចនិងមិនគួរទាញយកអាទិភាពរបស់ខ្លួនមុនសិទ្ធិរបស់សហគមន៍អន្តរជាតិទេ ។ សិទ្ធិរបស់សហគមន៍អន្តរជាតិមានតម្លៃរួមសម្រាប់មនុស្សជាតិទាំងអស់ និងមានឥទ្ធិពលទៅលើប្រជាជាតិទាំងអស់នៅលើពិភពលោក ។ តុលាការអន្តរជាតិដែលរៀបចំឡើងតាមលក្ខណៈសមស្របអាចកាត់សេចក្តីបទឧក្រិដ្ឋជំនួសមុខឲ្យសហគមន៍អន្តរជាតិ ប៉ុន្តែអាចត្រូវទទួលយកនូវសេចក្តីសម្រេចចិត្តដែលពិនិត្យពិច័យធ្វើការជំនុំជម្រះនោះនៅក្នុងតុលាការក្នុងស្រុក ដែលក្នុងនោះរួមមានទាំងបញ្ហាថាតើដំណើរការនេះស្របទៅតាមបទដ្ឋានត្រឹមត្រូវនិងយុត្តិធម៌ជាលក្ខណៈអន្តរជាតិដែរឬយ៉ាងណា? ។

**ស៊ូហ្សាណា លីនតុន**

# អន្តរាគមន៍របស់អង្គការណាតូនៅកូសូវ៉ូៈ ជាការលើកស្ទួយឬក៏បំផ្លាញច្បាប់អន្តរជាតិដែលមានសព្វថ្ងៃ?

**(តចប់)** ក្រុមប្រឹក្សាសន្តិសុខបានអនុម័តសេចក្តីសម្រេច លេខ១១៩៩ ខែកញ្ញា ឆ្នាំ១៩៩៨ ។ ប្រទេសចិនមិនចូលរួមបោះឆ្នោតគាំទ្រសេចក្តីសម្រេចនេះទេ ដោយយកហេតុផលថា មានការធ្វើអន្តរាគមន៍ទៅលើកិច្ចការផ្ទៃក្នុងរបស់សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ។ ពេលនេះក្រុមប្រឹក្សាសន្តិសុខបានសម្រេចចិត្តថា វិបត្តិនៅកូសូវ៉ូគឺជា“ការគំរាមកំហែងដល់សន្តិភាព និងសន្តិសុខនៅក្នុងតំបន់” ។ សេចក្តីសម្រេចបានទាមទារឲ្យភាគីទាំងពីរបញ្ឈប់ជម្លោះជាលក្ខណៈយោធា និងស្នើសុំឲ្យសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីចាត់វិធានការសមស្របនានាដើម្បីទទួលបានសន្តិភាពសម្រាប់តំបន់ ។ សេចក្តីសម្រេចបន្តទៀតថា ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានសម្រេចថា “ល្គឹកណាមិនមានចំណាត់វិធានការជាក់ស្តែងដូចដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចនេះ និងសេចក្តីសម្រេចលេខ១១៦៨ (ឆ្នាំ១៩៩៨) ទេនោះ (ក្រុមប្រឹក្សាសន្តិសុខ) នឹងសម្រេចចិត្តនិងចាត់វិធានការថែមទៀតដើម្បីថែរក្សា ស្តារសន្តិភាពនិងស្ថិរភាពនៅក្នុងតំបន់ឡើងវិញ” ។

ទោះបីជាសេចក្តីសម្រេចទាំងពីរនេះបញ្ជាក់ឲ្យឃើញថាការធ្វើអន្តរាគមន៍ប្រដាប់អាវុធនៅកូសូវ៉ូត្រូវតែមានការអនុញ្ញាតពីសំណាក់ក្រុមប្រឹក្សាសន្តិសុខយ៉ាងណាក៏ដោយ ក៏ប៉ុន្តែអង្គការណាតូបានទាញហេតុផលថា ខ្លួនអាចរកហេតុផលដើម្បីប្រើការវាយប្រហារដោយអាវុធមកលើសាធារណរដ្ឋសហព័ន្ធយូហ្គោ-ស្លាវីដោយយកសេចក្តីសម្រេចលេខ១១៩៩ធ្វើជាមូលដ្ឋាន ។ ប្រទេសចិន រុស្ស៊ី និងសមាជិកដទៃទៀតនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានបដិសេធទឡ្ហីករណ៍នេះ ។ ប្រទេសរុស្ស៊ីសន្យាថានឹងជំទាស់រាល់សេចក្តីព្រាងទាំងឡាយណាដែលធ្វើឡើងដោយក្រុមប្រឹក្សាសន្តិសុខដែលទាមទារឲ្យមានចំណាត់ការខាងយោធា ដោយនិយាយថាទង្វើនេះនឹងធ្វើឲ្យស្ថានការណ៍នៅកូសូវ៉ូកាន់តែដុនដាបថែមមួយកម្រិតទៀត ។ ការអះអាងរបស់ប្រទេសចិននេះមានលក្ខណៈត្រឹមត្រូវ ។ ដោយសារថាការអនុញ្ញាតឲ្យប្រើកម្លាំងប្រដាប់អាវុធទាមទារឲ្យមានមតិយល់ស្របជាឯកច្ឆន្ទពីសំណាក់សមាជិកក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ប្រទេសរុស្ស៊ីនិងប្រទេសចិនចេញមុខជំទាស់ទៅនឹងការប្រើកម្លាំងប្រដាប់អាវុធ ដែលជាការរារាំងមិនឲ្យមានចំណាត់ការយោធាដោយមានការយល់ព្រមពីសំណាក់អង្គការសហប្រជាជាតិមកលើកូសូវ៉ូ ។

ប្រសិនបើគ្មានការអនុញ្ញាតពីសំណាក់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិអាចមានផ្លូវមួយទៀតសម្រាប់អង្គការណាតូក្នុងការស្វែងរកការអនុញ្ញាតពីមហាសន្និបាតអង្គការសហប្រជាជាតិក្រោមមាត្រា IV នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុញ្ញាតឲ្យមានការបង្កើតបេសកកម្មមិនមែនយោធាដូចជាកម្លាំងប្រដាប់អាវុធជួយសង្គ្រោះបន្ទាន់របស់អង្គការសហប្រជាជាតិ ការត្រួតពិនិត្យការរៀបចំបោះឆ្នោតឆ្នាំ១៩៩០នៅប្រទេសហៃទី និងក្រុមប្រឹក្សាអង្គការសហប្រជាជាតិស្តីពីប្រទេសណាមីប៊ី ។ ប៉ុន្តែអង្គការណាតូមិនបានប៉ុនប៉ងស្វែងរកការអនុញ្ញាតពីក្រុមប្រឹក្សាសន្តិសុខឬមហាសន្និបាតអង្គការសហប្រជាជាតិឡើយ មុនពេលចាប់ផ្តើមធ្វើសង្គ្រាមជាមួយសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ។

ដូច្នេះទង្វើរបស់អង្គការណាតូមកលើសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីជាការរំលោភលើមាត្រាទី២(៤) នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ហើយមិនចូលក្នុងករណីលើកលែងពិសេសក្នុងការការពារខ្លួន ឬចូលក្នុងចំណាត់ការដែលមានការអនុញ្ញាតពីសំណាក់ក្រុមប្រឹក្សាសន្តិសុខឬមហាសន្និបាតអង្គការសហប្រជាជាតិ ។ ហេតុផលមួយទៀតដែលអង្គការណាតូយកមកប្រើប្រាស់គឺថា ខ្លួនធ្វើអន្តរាគមន៍ក្នុងលក្ខណៈមនុស្សធម៌ ។ អង្គការណាតូថ្លែងថា ត្រូវតែមានកម្លាំងប្រដាប់អាវុធដើម្បីការពារជនជាតិអាល់បានីកុំឲ្យមានការបោសសម្អាតជនជាតិភាគតិចដែលកំពុងតែធ្វើឡើងដោយសាធារណរដ្ឋសហព័ន្ធយូហ្គោ-ស្លាវី ។ ប្រទេសចំនួន៩នៃសមាជិករបស់អង្គការណាតូបានប្រើ

ពាក្យ "មហន្តរាយបង្កឡើងចំពោះមនុស្សជាតិ" ។ ចំណែកឯប្រទេសបែលហ្ស៊ិកប្រើពាក្យថា "ការធ្វើអន្តរាគមន៍មនុស្សធម៌ប្រដាប់អាវុធ" ។ អង្គការណាតូអះអាងថាការប្រើពាក្យថា "មហន្តរាយបង្កឡើងដោយមនុស្សជាតិ"វាស្របទៅនឹងមាត្រា២(៤)នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។ នៅក្នុងការទាញជាទឡ្ហីករណ៍ថា ការប្រើកម្លាំងប្រដាប់អាវុធរបស់អង្គការណាតូជាអន្តរាគមន៍បែបមនុស្សធម៌នោះ ប្រទេសបែលហ្ស៊ិកបានទទួលស្គាល់ថា ទ្រឹស្តីសាស្ត្រនេះមិនចុះសម្រុងជាមួយច្បាប់អន្តរជាតិឡើយ ។

ទ្រឹស្តីសាស្ត្រនៃពាក្យថាការធ្វើអន្តរាគមន៍បែបមនុស្សធម៌មិនទាន់មានអ្នកណាទទួលយកថាជាហេតុផលត្រឹមត្រូវសម្រាប់ការប្រើកម្លាំងប្រដាប់អាវុធដោយឯកតោភាគីដោយរដ្ឋមួយឬរដ្ឋច្រើនមកលើរដ្ឋដទៃទៀតឡើយ ទោះបីជារដ្ឋនោះបានរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរទៅលើប្រជាជនរបស់ខ្លួនយ៉ាងណាក៏ដោយ ។ ប៉ុន្តែការធ្វើអន្តរាគមន៍ដោយយកហេតុផលថាជាទង្វើផ្នែកសិទ្ធិមនុស្សអាចចូលជាច្បាប់អន្តរជាតិ ប្រសិនបើមានការយល់ស្របពីសំណាក់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិជំពូកVII ដូចជាឧទាហរណ៍ថ្មីៗនេះមានការប្រើកម្លាំងប្រដាប់អាវុធមកលើប្រទេសបូស្នៀនិងរ៉្វាន់ដាដោយមានការយល់ព្រមពីអង្គការសហប្រជាជាតិ ។ ជំពូក VII ទាក់ទងនឹងចំណាត់ការ "ទៅលើការគំរាមកំហែងដល់សន្តិភាព បទល្មើសលើសន្តិភាព និងអំពើឈ្លានពាន" ។ ក្នុងជំពូក VII ក្រុមប្រឹក្សាសន្តិសុខអាចចាត់វិធានការយោធាដោយប្រើកម្លាំងប្រដាប់អាវុធរបស់រដ្ឋនានា ។ ក្នុងករណីខ្លះ ក្រុមប្រឹក្សាសន្តិសុខប្រហែលជាអាចអនុញ្ញាតឲ្យអង្គការក្នុងតំបន់មានអំណាចក្រោមជំពូក VII ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ប្រសិនបើការប្រើកម្លាំងប្រដាប់អាវុធមិនត្រូវបានបង្ហាញថាជាហេតុផលការពារខ្លួនឬអនុញ្ញាតដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិតាមជំពូក VII ទេនោះ ការប្រើកម្លាំងប្រដាប់អាវុធរបៀបនេះនឹងត្រូវចាត់ទុកថាជាការរំលោភទៅលើច្បាប់អន្តរជាតិ ដោយមិនខ្វល់ថាតើរដ្ឋ ឬ អង្គការនោះទាញហេតុផលថាខ្លួនធ្វើឡើងក្នុងនាមជា "ការធ្វើអន្តរាគមន៍បែបមនុស្សធម៌ក៏ដោយ" ។ បើគ្រាន់តែប្រជាជនមានការឈឺចាប់ឬជួបវិបត្តិផ្ទៃក្នុងដែលបណ្តាលឲ្យមានការផ្លាស់ប្តូរទីលំនៅនោះ វាមិនគ្រាប់គ្រាន់សម្រាប់រដ្ឋមួយឬរដ្ឋផ្សេងទៀតយកជាហេតុផលដើម្បីធ្វើជាអន្តរាគមន៍បែបមនុស្សធម៌បានទេ ។ នៅក្នុងការវិនិច្ឆ័យក្តីក្នុងករណីប្រទេសនីការ៉ាហ្គ័រ តុលាការអន្តរជាតិបញ្ជាក់ច្បាស់ថា ជនភៀសខ្លួនច្រើនសន្ធឹកសន្ធាប់រត់ចេញពីរដ្ឋមួយដែលបណ្តាលមកពីការរំលោភសិទ្ធិមនុស្ស មិនចាំបាច់រហូតដល់ប្រើការវាយប្រហារដោយអាវុធឡើយ ។ ការវាយប្រហារដោយអាវុធនេះនឹងធ្វើឲ្យមានការគំរាមកំហែងឬការប្រើកម្លាំងប្រដាប់អាវុធដោយរដ្ឋផ្សេងទៀត ។ នៅក្នុងការទាញហេតុផលទៅនឹងការប្រើទ្រឹស្តីសាស្ត្រនេះសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីបានកត់សម្គាល់លើសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេសចក្រភពអង់គ្លេសប្រឆាំងនឹងការធ្វើអន្តរាគមន៍ផ្នែកមនុស្សធម៌÷

"ទស្សនៈផ្លូវច្បាប់ច្រើនលើសលប់ប្រឆាំងនឹងសិទ្ធិប្រើអន្តរាគមន៍បែបមនុស្សធម៌ដោយហេតុផលបីយ៉ាង÷ ទី១ ធម្មនុញ្ញអង្គការសហប្រជាជាតិនិងក្រមច្បាប់អន្តរជាតិទំនើប ហាក់ដូចជាមិនស្របគ្នាទៅនឹងសិទ្ធិបែបនេះឡើយ ។ ទី២ ការអនុវត្តរបស់រដ្ឋកាលពី២សតវត្សរ៍មុន ហើយជាពិសេសចាប់តាំងពីឆ្នាំ១៩៤៥មក ផ្តល់យ៉ាងច្រើនត្រឹមតែករណីអន្តរាគមន៍បែបមនុស្សធម៌ជាក់ស្តែងមួយចំនួនតូចប៉ុណ្ណោះ ក្រៅពីនោះគ្មានទាល់តែសោះ ។ ទី៣ វិសាលភាពនៃការរំលោភសិទ្ធិជាការទាញហេតុផលប្រឆាំងនឹងការបង្កើតសិទ្ធិធ្វើអន្តរាគមន៍បែបមនុស្សធម៌នេះ..." ។ ដូច្នេះជាការសំខាន់ណាស់ករណីប្រឆាំងនឹងការធ្វើអន្តរាគមន៍បែបមនុស្សធម៌ដែលជាករណីលើកលែងមួយ នៅក្នុងគោលការណ៍គ្មានការធ្វើអន្តរាគមន៍គឺថាផលប្រយោជន៍ដែលប្រកបដោយភាពងឿងឆ្ងល់មិនត្រូវមានតម្លៃខ្ពស់ជាងការគោរពច្បាប់អន្តរជាតិឡើយ ។

នៅពេលដាក់សំណុំបែបបទទៅតុលាការអន្តរជាតិ ប្រទេសនៅក្នុងអង្គការណាតូមិនបានលើកឡើងនូវអំណាចណាមួយដែលគាំទ្រដល់ការប្រើកម្លាំងប្រដាប់អាវុធដោយឈរលើមូលហេតុមនុស្សធម៌ឡើយ ហើយក៏មិនបានទាញហេតុផលថាការវាយតម្លៃរបស់ប្រទេសអង់គ្លេសបានអស់សុពលភាពដោយសារការវិវត្តន៍នៃច្បាប់អន្តរជាតិសព្វថ្ងៃនេះដែរ ។

សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីបានធ្វើការបោស

សម្ពាធទៅលើជនជាតិភាគតិចដូចដែលបានចោទប្រកាន់មែន ចុះហេតុអ្វីបានជាសហរដ្ឋអាមេរិក ប្រទេសអេស្ប៉ាញ និងប្រទេសជាសមាជិកអង្គការណាតូផ្សេងៗទៀត បដិសេធមិនយល់ព្រមទៅលើដែនសមត្ថកិច្ចរបស់តុលាការអន្តរជាតិ? ជាពិសេសនៅពេលដាក់ពាក្យមកតុលាការអន្តរជាតិដែលបដិសេធដែនសមត្ថកិច្ចរបស់តុលាការនេះ សហរដ្ឋអាមេរិកបានរំឭកក្នុងតុលាការថា ខ្លួនមិនយល់ព្រមទាំងស្រុងទៅនឹងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ទេ ដោយមិនយល់ព្រមឲ្យតុលាការអន្តរជាតិបើកសវនាការសម្រាប់ដោះស្រាយរឿងក្តីកើតឡើងពីអនុសញ្ញានេះបើគ្មានការយល់ស្របពីសហរដ្ឋអាមេរិក ។ នៅក្នុងករណីសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី តុលាការអន្តរជាតិបានធ្វើតាមលក្ខខណ្ឌនេះដោយនិយាយថា «ការមិនយល់ស្របចំពោះមាត្រាទី I (ខ) មិនមែនជាការផ្ទុយទៅនឹងកម្មវត្ថុនិងគោលបំណងរបស់អនុសញ្ញានេះទេ» ។

អង្គការណាតូក៏បានយកភាពចាំបាច់ក្នុងផ្លូវច្បាប់មកប្រើក្នុងការចាត់វិធានការតាមផ្លូវយោធា ។ យោងតាមមាត្រាទី៣៣ នៃសេចក្តីព្រាងមាត្រាមួយចំនួនអំពីការទទួលខុសត្រូវរបស់រដ្ឋចំពោះគណៈកម្មាធិការច្បាប់អន្តរជាតិនៅឆ្នាំ១៩៨០ បានឲ្យដឹងថា÷ «ក្នុងករណីណាក៏ដោយ គ្មានរដ្ឋណាមួយអាចយកភាពជាការចាំបាច់មកធ្វើជាហេតុផលក្នុងការទប់ស្កាត់អំពើខុសច្បាប់បានទេ ក) ប្រសិនបើកាតព្វកិច្ចច្បាប់ជាអន្តរជាតិដែលក្នុងនោះអំពើរបស់រដ្ឋមានលក្ខណៈមិនស្របគ្នាបានកើតឡើងចេញផុតពីបទដ្ឋានដាច់ខាតនៃច្បាប់អន្តរជាតិទូទៅ ឬ ខ) ប្រសិនបើរដ្ឋខាងលើនេះបានរួមចំណែកឲ្យមានការកើតឡើងនូវភាពចាំបាច់របស់រដ្ឋ» ។

រដ្ឋដែលអើពើចំពោះការប្តឹងផ្តល់របស់សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ដូចជាសហរដ្ឋអាមេរិក ប្រទេសបារាំង ប្រទេសអ៊ីតាលី ប្រទេសបែលហ្សិក ប្រទេសអាល្លឺម៉ង់ ប្រទេសហូល្លង់ និងប្រទេសកាណាដា បានផ្តល់ហិរញ្ញវត្ថុចំពោះកងទ័ពរំដោះយូហ្គោស្លាវីតាមរយៈស្ថាប័នហិរញ្ញវត្ថុនានានៅក្នុងប្រទេសរៀងៗខ្លួន ។ គណនីធនាគារតម្កល់ប្រាក់ទុកសម្រាប់កងទ័ពរំដោះយូហ្គោស្លាវី ថែមទាំងត្រូវបានផ្សព្វផ្សាយនៅតាមបណ្តាប្រទេសដែលមានការអើពើទាំងនោះ ទាំងតាមប្រព័ន្ធផ្សព្វផ្សាយទាំងតាមអ៊ីនធ័រនែត ។ ការគាំទ្ររបស់ប្រទេសជាសមាជិកអង្គការណាតូមកលើកងទ័ពរំដោះយូហ្គោស្លាវី អាចនិយាយបានថាបានជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ដែលផ្ទុយទៅនឹងសេចក្តីប្រកាសជាសាកលឆ្នាំ១៩៧០ ស្តីពីគោលការណ៍ច្បាប់អន្តរជាតិទាក់ទងនឹងទំនាក់ទំនងមិត្តភាពនិងកិច្ចសហប្រតិបត្តិការ ។ ដូច្នេះឃើញថា អង្គការណាតូមិនអាចយកលក្ខខណ្ឌការពារខ្លួនតាមលក្ខណៈនៃភាពចាំបាច់ជាហេតុផលសម្រាប់វាយប្រហារតាមផ្លូវអាកាសរបស់ខ្លួនឡើយ ។

### តើអង្គការណាតូបានប្រព្រឹត្តបទឧក្រិដ្ឋឈ្លានពានទឹកដីដែរឬទេ?

ឧក្រិដ្ឋកម្មមួយត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មអន្តរជាតិបាន លុះត្រាណាការខូចខាតបណ្តាលមកពីឧក្រិដ្ឋកម្មនេះធ្វើឲ្យគ្រោះថ្នាក់ដល់សន្តិសុខរបស់រដ្ឋទាំងអស់នៅក្នុងពិភពលោក ។ សកម្មភាពរបស់អង្គការណាតូអាចចូលជាអំពើឈ្លានពានមកលើសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ។ ប៉ុន្តែបើនិយាយតាមប្រវត្តិសាស្ត្រវិញគឺមានបញ្ហាច្រើនណាស់ក្នុងការឲ្យនិយមន័យទៅលើពាក្យថា«ឈ្លានពាន» និងមានបញ្ហាក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពិតប្រាកដក្នុងច្បាប់អន្តរជាតិស្តីពីអ្វីដែលបង្កើតបានជាបទឧក្រិដ្ឋនៃអំពើឈ្លានពាន ។

នៅឯតុលាការនូរិមប៊ឺក ក្រោយពីសង្គ្រាមលោកលើកទីពីរបានផុតរលត់ទៅ តុលាការសឹកអន្តរជាតិមានទឡ្ហីករណ៍ថា ច្បាប់អន្តរជាតិគាំទ្រសេចក្តីសម្រេចឲ្យមានការទទួលខុសត្រូវចំពោះ«បទឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព» ពោលគឺឧក្រិដ្ឋកម្មនៃអំពើឈ្លានពាន ។ តុលាការនេះគាំទ្រដល់សេចក្តីសម្រេចឲ្យមានការទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មឈ្លានពាន ។ មាត្រា៦(ក) នៃធម្មនុញ្ញទីក្រុងឡុង ចែងថា÷ «ការផ្តើមគំនិតឈ្លានពានទៅលើប្រទេសដទៃ និងសង្គ្រាមឈ្លានពានដែលជាការរំលោភច្បាប់និងអនុសញ្ញាអន្តរជាតិ រួមទាំង(តែមិនកំណត់ចំពោះ)ការរៀបចំផែនការការប្រុងប្រៀបរួចជាស្រេច ឬការធ្វើសង្គ្រាមឈ្លានពាន ឬសង្គ្រាមដែលជាការរំលោភលើអនុសញ្ញាកិច្ចព្រមព្រៀងឬការធានាអន្តរជាតិ ឬការចូលរួមក្នុងផែនការឬសមគំនិតប្រព្រឹត្តអំពើដែលរៀបរាប់រួចមកហើយនេះ» ។

ទោះបីជាមានការកាត់សេចក្តីទៅលើការប្រព្រឹត្តឧក្រិដ្ឋកម្ម

នៃអំពើឈ្លានពាននៅនូរិមប៊ឺកក៏ពិតមែន ប៉ុន្តែគ្មានចុងចោទណាម្នាក់ត្រូវបានកាត់ទោសប្រហារជីវិតពីបទឈ្លានពាន(ទឹកដី) ឡើយ ។ ជាទូទៅ អ្នកដែលត្រូវបានកាត់ទោសប្រហារជីវិតគឺជាជនដែលគេរកឃើញថាបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម ។

នៅឆ្នាំ១៩៤៦ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តជាឯកច្ឆន្ទនូវនិយមន័យនៃពាក្យថាឈ្លានពាន នៅក្នុងសេចក្តីសម្រេចលេខ៩៥(១) ។ នៅក្នុងការបញ្ជាក់សាជាថ្មីទៅលើច្បាប់នៅតុលាការនូរិមប៊ឺកឆ្នាំ១៩៥០ ក្រុមអ្នកច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិបានកំណត់“ក្រិដ្ឋកម្មប្រឆាំងសន្តិភាព” តាមគោលការណ៍លេខ VI(ក) ថា÷

១) ការដាក់ផែនការ ការរៀបចំទុកជាស្រេច ការផ្តើមគំនិតរួចជាស្រេច ឬ ការធ្វើសង្គ្រាមឈ្លានពាន ឬធ្វើសង្គ្រាមដែលជាការរំលោភទៅលើសិទ្ធិសញ្ញាកិច្ចព្រមព្រៀងឬការធានាជាអន្តរជាតិ ។ (និង)

២) ការចូលរួមនៅក្នុងផែនការមួយ ឬចូលសមគំនិតប្រព្រឹត្តអំពើទាំងឡាយដែលមានចែងនៅក្នុងមាត្រា(១) ។

មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចមួយនៅឆ្នាំ១៩៧៤ ដែលបញ្ជាក់ច្បាស់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្មឈ្លានពាន ។ និយមន័យដែលរៀបរាប់រួចមកហើយទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឬឧក្រិដ្ឋកម្មឈ្លានពានបញ្ជាក់អំពីលទ្ធភាពដាក់ឲ្យទទួលខុសត្រូវជាលក្ខណៈបុគ្គល ប៉ុន្តែសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិផ្តោតសំខាន់តែទៅលើការទទួលខុសត្រូវជាលក្ខណៈរដ្ឋ ។ មាត្រា១នៃសេចក្តីសម្រេចលេខ៣៣១៤ចែងថា អំពើឈ្លានពាន “ជាអំពើទាំងឡាយដែលធ្វើឡើងដោយរដ្ឋមកលើរដ្ឋដទៃទៀត ដែលគំរាមកំហែងដល់បូរណភាពទឹកដី ឬឯករាជភាពនយោបាយ ឬការរំលោភទៅលើធម្មនុញ្ញអង្គការសហប្រជាជាតិ ។ ច្បាស់ជាងនេះទៀត អំពើឈ្លានពានគឺអំពើទាំងឡាយណាដែលរួមមាន÷ ក) ការចូលលុកលុយ ការវាយប្រហារ ការកាន់កាប់ទឹកដីដោយប្រើកម្លាំងប្រដាប់អាវុធយោធាពីសំណាក់រដ្ឋមួយទៅលើរដ្ឋមួយទៀត ។ ខ) ការទម្លាក់គ្រាប់បែករបស់រដ្ឋមួយទៅលើរដ្ឋមួយទៀត ។ គ) ការបិទផ្លូវកំពង់ផែ ។ និង ឃ) ការវាយប្រហារមកលើដែនសមុទ្រនិងដែនអាកាស ។

សេចក្តីសម្រេចលេខ៣៣១៤មិនបង្គាប់ឲ្យរដ្ឋដែលជាសមាជិករបស់អង្គការសហប្រជាជាតិគោរពតាមឡើយ ។ ចំណែកឯការឲ្យនិយមន័យលើឧក្រិដ្ឋកម្មឈ្លានពានត្រូវបានអនុម័តយល់ព្រមដោយតុលាការអន្តរជាតិនៅក្នុងករណីប្រទេសនីការ៉ាហ្គ័រ ។ នៅក្នុងករណីនោះ មតិភាគច្រើននៃតុលាការអន្តរជាតិនិយាយថាសេចក្តីសម្រេចលេខ៣៣១៤ជាការដាក់ឧក្រិដ្ឋកម្មឈ្លានពានទៅក្នុងច្បាប់ទម្លាប់អន្តរជាតិ ។

នៅក្នុងឆ្នាំ១៩៨៧ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តលើសេចក្តីប្រកាសស្តីអំពីការលើកកម្ពស់ប្រសិទ្ធភាពនៃគោលការណ៍ទប់ស្កាត់មិនឲ្យមានការគំរាមកំហែង ឬការប្រើកម្លាំងប្រដាប់អាវុធនៅក្នុងទំនាក់ទំនងអន្តរជាតិ” ។ សេចក្តីប្រកាសនេះបញ្ជាក់ពីសេចក្តីសម្រេចលេខ៣៣១៤ ហើយចែងថា ការប្រើកម្លាំងប្រដាប់អាវុធត្រូវតែហាមឃាត់ជានិរន្តរ៍ ពោលគឺគ្មានការគិតពិចារណាអំពីមូលហេតុដែលនាំឲ្យប្រើកម្លាំងប្រដាប់អាវុធនោះទេ ។ នៅឆ្នាំ១៩៩៦ គណៈកម្មាធិការច្បាប់អន្តរជាតិនៃអង្គការសហប្រជាជាតិបានចេញសេចក្តីព្រាងច្បាប់របស់ខ្លួនស្តីអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ រួមបញ្ចូលទាំងការឲ្យនិយមន័យនៃឧក្រិដ្ឋកម្មឈ្លានពានមួយផង ។ នៅក្នុងសេចក្តីព្រាងច្បាប់នេះ អង្គការសហប្រជាជាតិត្រឡប់ទៅរកទស្សនាទាននៃតុលាការនូរិមប៊ឺក ស្តីពីការទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះឧក្រិដ្ឋកម្មឈ្លានពាន ។ មកដល់សព្វថ្ងៃនេះវាហាក់ដូចជាអាចទៅរួចដែលថា ទាំងរដ្ឋនិងបុគ្គលអាចដាក់ឲ្យទទួលខុសត្រូវពីបទប្រព្រឹត្តឧក្រិដ្ឋកម្មឈ្លានពាន ។ កន្លងមកមិនដែលមានករណីនេះទេ មានតែតុលាការនូរិមប៊ឺកនិងសេចក្តីព្រាងច្បាប់នេះទេដែលដាក់បុគ្គលឲ្យមានការទទួលខុសត្រូវ ហើយគ្រាន់តែបង្កើតច្បាប់ថ្មីបែបនេះក៏មិនមែនជាការខុសច្បាប់អ្វីដែរ ។

ដោយសាររដ្ឋនានាដូចជាសហរដ្ឋអាមេរិកក្នុងករណីប្រទេសនីការ៉ាហ្គ័រជាដើម យល់ថា ការប្រើកម្លាំងប្រដាប់អាវុធជាមានផលប្រយោជន៍នយោបាយ ឬផលប្រយោជន៍ជាតិ រដ្ឋទាំងឡាយនោះមានការស្ទាក់ស្ទើរមិនហ៊ានបោះបង់ជម្រើសដែលអាចងាកទៅប្រើការឈ្លានពាននៅពេលមានជម្លោះ ។ នេះប្រហែលជា

មូលហេតុដែលបណ្តាលឲ្យគ្មានការមូលមតិគ្នាក្នុងចំណោមរដ្ឋនានា ហើយមានផលប្រយោជន៍តិចតួចក្នុងការធ្វើច្បាប់ហាមប្រាមមិនឲ្យឈ្លានពាន ។ ប៉ុន្តែទោះជាការឈ្លានពានមិនទាន់មានកំណត់និយមន័យឲ្យបានច្បាស់លាស់និងចេញជាច្បាប់ក៏ដោយ ក៏មិនមានន័យថាអំពើឈ្លានពានរបស់រដ្ឋមួយមិនចូលជាឧក្រិដ្ឋកម្មអន្តរជាតិនោះឡើយ ។ ការហាមប្រាមមិនឲ្យមានអំពើឈ្លានពានគឺជាវិធាននៃបទដ្ឋានដាច់ខាត និងជាច្បាប់ទម្លាប់អន្តរជាតិ ដែលនាំឲ្យមានការដាក់ទណ្ឌកម្មក្នុងកម្រិតទោសរដ្ឋប្បវេណីនិងព្រហ្មទណ្ឌ ។

### IV. ការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌនិងរដ្ឋប្បវេណីរបស់រដ្ឋនីមួយៗនៃអង្គការណាតូ

ដូចដែលបានទាញហេតុផលខាងលើរួចមកហើយ រដ្ឋទាំង ១០ ដែលជាសមាជិកនៃអង្គការណាតូបានរំលោភលើច្បាប់អន្តរជាតិ ដោយសារខ្លួនប្រើប្រាស់កម្លាំងប្រដាប់អាវុធមកលើសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីដោយគ្មានការឲ្យហេតុផលតាមផ្លូវច្បាប់ត្រឹមត្រូវ ។ ជាងនេះទៅទៀត ទង្វើរបស់អង្គការណាតូគឺជាឧក្រិដ្ឋកម្មឈ្លានពាន ។ មាត្រា១ នៃសេចក្តីព្រាងស្តីពីការទទួលខុសត្រូវជាលក្ខណៈរដ្ឋចែងថា «រាល់អំពើខុសច្បាប់អន្តរជាតិរបស់រដ្ឋណាមួយរដ្ឋនោះត្រូវតែទទួលខុសត្រូវជាអន្តរជាតិ» ។ រាល់ការប្រព្រឹត្តបទល្មើសទៅលើកាតព្វកិច្ចអន្តរជាតិត្រូវតែមានការទទួលខុសត្រូវជាសំណងវិញ ។ យោងតាមតុលាការអន្តរជាតិអចិន្ត្រៃយ៍បានឲ្យដឹងថា÷ «គោលការណ៍សំខាន់ដែលមាននៅក្នុងសញ្ញាណជាក់ស្តែងនៃទង្វើខុសច្បាប់ដែលជាគោលការណ៍ ហាក់ដូចជាកើតឡើងតាមរយៈការអនុវត្តជាអន្តរជាតិ និងជាពិសេសតាមរយៈសេចក្តីសម្រេចរបស់តុលាការគ្មានលម្អៀង គឺថាសំណងនៃការខូចខាតត្រូវតែលុបលើផលវិបាកទាំងអស់កើតឡើងដោយសារអំពើល្មើសច្បាប់ ហើយធ្វើឲ្យសភាពការណ៍វិលទៅរកសភាពដើមវិញតាមលទ្ធភាពដែលអាចធ្វើទៅបាន» ។

ក្នុងចំណោមការជួសជុលសំណងការខូចខាតទាំងបីយ៉ាងពោលគឺសំណង ការទូទាត់ និងការបំពេញចិត្ត នៅក្នុងករណីសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ការទូទាត់ចំពោះការខូចខាតអាចមានលក្ខណៈសមរម្យបំផុត ពីព្រោះ«សំណង»អាចជាការដាក់សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ឲ្យវិលទៅរកភាពដើមមុនពេលមានការរំលោភច្បាប់ ។ ករណីនេះមិនអាចទៅរួចទេ ពីព្រោះជីវិតមនុស្សនិងទ្រព្យសម្បត្តិត្រូវបាត់បង់រួចទៅហើយ ។ ចំណែកការទូទាត់អាចពាក់ព័ន្ធដល់ការគិតពិចារណាការដាក់ឲ្យទទួលខុសត្រូវជាលក្ខណៈរដ្ឋច្រើនរួមគ្នា ។ តុលាការអន្តរជាតិគួរតែគិតពិចារណាទៅលើទោសប្រហាក់ប្រហែលគ្នារបស់រដ្ឋទាំងឡាយដែលជាសមាជិកអង្គការណាតូ ដោយឲ្យរដ្ឋនីមួយៗទូទាត់តម្លៃដែលត្រូវសងរៀងៗខ្លួន ។ ចំពោះការបំពេញចិត្តវិញ អាចជាការសុំទោស ប្រកាសទទួលយកការទទួលខុសត្រូវ ការធានាឈប់ឲ្យមានអំពើបែបនេះកើតឡើងសាជាថ្មី និងការដាក់ទណ្ឌកម្មលើអ្នកប្រព្រឹត្តផ្ទាល់ ។

នៅក្នុងសំណុំបែបបទដាក់ជូនតុលាការអន្តរជាតិ អ្នកតំណាងស្របច្បាប់នៃសមាជិកអង្គការណាតូបានអះអាងថា អំពើជាក្រុមខ្សែសង្វាក់មិនអាចសន្មតថាជាអំពើរបស់រដ្ឋជាសមាជិកណាមួយទេ ដូច្នេះរដ្ឋជាសមាជិកមិនអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវបានឡើយ ។ ដោយទាញហេតុផលថាអង្គការណាតូជាអង្គការអន្តរជាតិត្រូវទទួលខុសត្រូវដោយឡែកចំពោះសកម្មភាពផ្នែកយោធានោះ អង្គការណាតូប៉ុនប៉ងទប់ទល់មិនឲ្យមានរដ្ឋណាមួយទទួលខុសត្រូវចំពោះអំពើដែលអង្គការនេះបានប្រព្រឹត្តឡើយ ។ អង្គការណាតូគឺជាអង្គការអន្តរជាតិដែលមិនអាចមានលក្ខណៈសម្បត្តិជាអន្តរជាតិគ្រប់គ្រាន់ក្នុងការប្តឹងនិងឲ្យគេប្តឹង ។ ហេតុដូចនេះ ប្រសិនបើអង្គការណាតូទទួលបានជោគជ័យតាមរយៈទឡ្ហីករណ៍របស់ខ្លួនមែននោះ ទាំងអង្គការណាតូនិងរដ្ឋនានាដែលជាសមាជិកអាចគេចវេះរួចខ្លួនពីការទទួលខុសត្រូវជាអន្តរជាតិ ។

ប៉ុន្តែទោះជាមានទឡ្ហីករណ៍ដូច្នេះ នៅក្នុងករណីសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីដ៏ដោយ ក៏កូនសៀវភៅណែនាំរបស់អង្គការណាតូសរសេរនៅឆ្នាំ១៩៩៨ដែលចែងពី«គោលនយោបាយនិងវេទិកាក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់អង្គការណាតូដែលជាក្រុមប្រឹក្សាអាត្លង់ទិកខាងជើង» បានថ្កោលទោសរាល់កំហុសទាំងឡាយណាដែលអាចកើតឡើងចំពោះរដ្ឋជាសមាជិកនីមួយៗ ។ សៀវភៅនោះសរសេរថា÷

«នៅពេលធ្វើសេចក្តីសម្រេចចិត្ត ត្រូវតែមានការយល់ព្រមជាឯកច្ឆន្ទនិងប្រកបដោយសុភនិច្ឆ័យ ។ គ្មានការបោះឆ្នោត

ឬសម្រេចដោយមតិភាគច្រើនទេ ។ រដ្ឋនីមួយៗដែលជាតំណាងនៅក្រុមប្រឹក្សាឬគណៈកម្មាធិការនានា ត្រូវរក្សានូវអធិប-តេយ្យភាពនិងការទទួលខុសត្រូវចំពោះការសម្រេចចិត្តរបស់ខ្លួន" ។

ជាងនេះទៀត សៀវភៅនោះក៏បញ្ជាក់ដែរថា ឥស្សរជននយោបាយរបស់រដ្ឋនីមួយៗ ក៏អាចដាក់ឲ្យទទួលខុសត្រូវចំពោះសេចក្តីសម្រេចចិត្តរបស់ខ្លួនដែរ ។ សៀវភៅនោះបញ្ជាក់ច្បាស់ថា៖ "យោងតាមគោលការណ៍ជាសារវន្តដែលជាបទដ្ឋានទំនាក់ទំនងរវាងស្ថាប័ននយោបាយនិងយោធារបស់រដ្ឋប្រកាន់លទ្ធិប្រជាធិបតេយ្យ រចនាសម្ព័ន្ធយោធាដែលធ្វើសមាហរណកម្មចូលគ្នារួចហើយនៅតែស្ថិតនៅក្រោមការគ្រប់គ្រងនយោបាយ និងក្រោមមាគ៌ារបស់ថ្នាក់លើគ្រប់ពេលវេលាទាំងអស់" ។

ដូច្នេះការអះអាងរបស់អង្គការណាតូដែលថារដ្ឋនានាដែលជាសមាជិករបស់ខ្លួនមិនមានការទទួលខុសត្រូវចំពោះការប្រើកម្លាំងប្រដាប់អាវុធយោធា សមតែត្រូវបរាជ័យ ។ មិនតែប៉ុណ្ណោះបុគ្គលដែលបញ្ជាឲ្យមានការវាយប្រហារតាមផ្លូវអាកាស និងអ្នកដែលត្រូវបង្ខំឲ្យធ្វើតាមបញ្ជា ក៏អាចដាក់ឲ្យទទួលទោសព្រហ្មទណ្ឌក្រោមច្បាប់អន្តរជាតិដែរ ។

នៅក្នុង"ការអនុវត្តនៃអនុសញ្ញាស្តីពីការទប់ស្កាត់និងការផ្តន្ទាទោសបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍" (ករណីប្រទេសបូស្នៀ និងហឺហ្ស៊ីហ្គោវីណា ជាមួយប្រទេសយូហ្គោស្លាវី) តុលាការអន្តរជាតិទាក់ទងនឹងមាត្រា I (ឃ) នៃអនុសញ្ញាស្តីពីការទប់ស្កាត់និងការផ្តន្ទាទោស ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ បានបញ្ជាក់ថា ទោះបីជាបទឧក្រិដ្ឋកម្មអន្តរជាតិដែលប្រព្រឹត្តឡើងដោយបុគ្គលក៏ដោយ ប៉ុន្តែរដ្ឋឬអង្គភាពពាក់ព័ន្ធអាចដាក់ឲ្យទទួលខុសត្រូវក្រោមវិធានទូទៅនៃការទទួលខុសត្រូវជាអន្តរជាតិ ។ តុលាការនៅបានពន្យល់ថែមទៀតថា ទោះបីជាឧក្រិដ្ឋកម្មអន្តរជាតិមិនពាក់ព័ន្ធដល់រដ្ឋឬអង្គភាពនានារបស់រដ្ឋក៏ដោយ ប៉ុន្តែបុគ្គលត្រូវតែទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើង ។

តើអ្វីទៅជាការជួយសង្គ្រោះបន្ទាន់សម្រាប់សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីដែលជារដ្ឋទទួលការខូចខាតក្រោមច្បាប់អន្តរជាតិនោះ? សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីអាចប្តឹងទៅតុលាការអន្តរជាតិដោយផ្អែកលើគោលការណ៍ច្បាប់អន្តរជាតិស្តីពីតួនាទីសងការខូចខាតដែលជាលទ្ធផលនៃការរំលោភកាតព្វកិច្ចអន្តរជាតិមាត្រា៤៥ នៃមាត្រាព្រាងដែលតម្រូវឲ្យមានការប៉ះប៉ូវការបញ្ឈប់អំពើខុសច្បាប់ សំណង ការទូទាត់ និងការធានាថាមិនឲ្យអំពើនេះកើតឡើងសាជាថ្មី ។ តាមមើលទៅសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីហាក់ដូចជាគ្មានទទួលបាននូវការជួយសង្គ្រោះប្រាកដប្រជាឡើយ សូម្បីតែពីអាមេរិក និងអេស្ប៉ាញក៏មិនមានផង ។ ដោយសាររដ្ឋទាំងអស់នេះមិនស្ថិតនៅក្រោមដែនសមត្ថកិច្ចបង្ខំរបស់តុលាការអន្តរជាតិ ដូច្នេះអាចមានក្រឡារួចខ្លួនពីការទទួលខុសត្រូវ ។ ប៉ុន្តែប្រសិនបើប្រទេសជាសមាជិកទាំង៤ឬសមាជិកណាមួយរបស់អង្គការណាតូត្រូវដាក់ឲ្យទទួលខុសត្រូវពីបទឈ្លានពាន ពេលនោះទាំងសហរដ្ឋអាមេរិកនិងប្រទេសអេស្ប៉ាញក៏ត្រូវតែសងការខូចខាតដល់សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីដែរក្រោមគោលការណ៍ទទួលខុសត្រូវរួមគ្នា និងដោយឡែក ។ ប្រទេសដទៃទៀតដូចជា ប្រទេសម៉ាសេដូនីនិងប្រទេសអាល់បានីដែលអនុញ្ញាតឲ្យអង្គការណាតូប្រើប្រាស់ទឹកដីរបស់ខ្លួនសម្រាប់វាយប្រហារមកលើសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ក៏នឹងជាប់ទាក់ទិនទៅនឹងការទទួលខុសត្រូវនេះដែរ ។

## សេចក្តីសន្និដ្ឋាន

ក្រោមច្បាប់អន្តរជាតិដែលប្រើសព្វថ្ងៃ ការលុកលុយដោយប្រើអាវុធរបស់អង្គការណាតូចូលក្នុងទឹកដីសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី គឺគ្មានហេតុផលត្រឹមត្រូវតាមផ្លូវច្បាប់ទេ ។ ទង្វើនេះមិនមានការអនុញ្ញាតពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឬមហាសន្និបាតអង្គការសហប្រជាជាតិទេ ហើយមិនមែនជាករណីការពារខ្លួនដែរ ។ ជាងនេះទៅទៀត ការធ្វើអន្តរាគមន៍ប្រដាប់អាវុធតាមបែបមនុស្សធម៌ក៏មិនអាចទទួលយកបានក្រោមច្បាប់អន្តរជាតិដែរ ។ ការហូរចេញនូវជនភៀសសឹកពីប្រទេសកូសូវ៉ូ និងការរំលោភសិទ្ធិមនុស្ស ទោះបីជាការរំលោភនោះមានកម្រិតធ្ងន់យ៉ាងណា ឬមានទំហំប៉ុនណា ក៏ច្បាប់អន្តរជាតិមិនអនុញ្ញាតឲ្យមានការវាយប្រហារដោយអាវុធដែរ ។ មិនតែប៉ុណ្ណោះសោត ការយកហេតុផលថាជា"ការធ្វើអន្តរាគមន៍បែបមនុស្សធម៌" គឺជាការគ្រោះថ្នាក់ណាស់ ពីព្រោះទង្វើនេះធ្វើដោយឯកឯងតាមទិន្នាការនយោបាយនិងផលប្រយោជន៍

របស់រដ្ឋរៀងៗខ្លួន ។ ចំណុចមួយទៀតគឺថា ក្រោមច្បាប់អន្តរជាតិ រដ្ឋមិនត្រូវបានអនុញ្ញាតឲ្យជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋអធិបតេយ្យមួយទៀតឡើយ ។ សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីជារដ្ឋអធិបតេយ្យ ។

មិនមានការជំទាស់ថាមានការរំលោភសិទ្ធិមនុស្សនៅកូសូវ៉ូ ហើយថាទាំងជនជាតិអាល់បានីនិងជនជាតិស៊ែបត្រូវបានសម្លាប់នៅក្នុងអំឡុងមានវិបត្តិនៅកូសូវ៉ូនោះទេ ប៉ុន្តែវិបត្តិនៅកូសូវ៉ូកន្លងមកគឺជាជម្លោះកើតឡើងរវាងរដ្ឋស្របច្បាប់មួយក្រោមច្បាប់អន្តរជាតិ (សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី) ជាមួយនឹងខេត្ត (កូសូវ៉ូ) ដែលកំពុងតែរិះរកផ្លូវបំបែកពីរដ្ឋអធិបតេយ្យតាមរយៈការបះបោរប្រដាប់អាវុធខុសច្បាប់ ។ ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិនិងអង្គការណាតូមិនបានរិះរកផ្លូវបង្ហាញថាវាជាជម្លោះផ្ទៃក្នុងទេ ។ តាមពិត ទាំងជនជាតិអាល់បានីនិងជនជាតិស៊ែបសុទ្ធតែជាជនរងគ្រោះដូចគ្នា ។ ជម្លោះនេះមានផ្លូវច្រើនដែលត្រូវដោះស្រាយតាមសន្តិវិធីយោងតាមគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។

ហេតុដូចនេះ សកម្មភាពរបស់អង្គការណាតូជាការរំលោភទៅលើច្បាប់អន្តរជាតិ ។ ក្រោមច្បាប់អន្តរជាតិ រដ្ឋនីមួយៗគួរតែត្រូវដាក់ឲ្យទទួលខុសត្រូវទាំងដោយឡែកទាំងរួមគ្នា ចំពោះការឈ្លានពានរបស់អង្គការណាតូ ។

ដោយសារនយោបាយនិងការមិនយល់ស្របទាំងស្រុងទៅលើលក្ខន្តិកៈរបស់តុលាការអន្តរជាតិពីសំណាក់រដ្ឋនានាជាសមាជិកអង្គការណាតូ ជាពិសេសសហរដ្ឋអាមេរិកដែលជាមហាអំណាចពិភពលោក និងបើគ្មានអាមេរិកក៏គ្មានយុទ្ធនាការណាតូដែរនោះ វាហាក់ដូចជាមិនអាចទៅរួចទេថាប្រទេសសមាជិកអង្គការណាតូនឹងត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ។ ករណីសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីនៅតុលាការអន្តរជាតិបង្ហាញពីភាពខ្វះចន្លោះនៃច្បាប់អន្តរជាតិ និងធ្វើជាឧទាហរណ៍បង្ហាញឲ្យឃើញពីប្រសិទ្ធភាពនៃគោលការណ៍នានានៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងការទទួលខុសត្រូវរបស់រដ្ឋ ។ ប្រសិនបើប្រទេសមានអំណាចនានាមិនត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះការរំលោភបំពានរបស់ខ្លួនលើច្បាប់អន្តរជាតិនោះ ច្បាប់អន្តរជាតិគ្មានឥទ្ធិពលជាធរមានឬគួរជឿទុកចិត្តឡើយ ។

ក្រោយពីសង្គ្រាមលោកលើកទី២ ពាក្យថា“សណ្តាប់ធ្នាប់ពិភពលោកថ្មី”ជាក់ស្តែងមិនមែនជាសណ្តាប់ធ្នាប់ច្បាប់អន្តរជាតិដែលផ្អែកលើគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិឡើយ ។ ផ្ទុយទៅវិញ សណ្តាប់ធ្នាប់ពិភពលោកថ្មីគឺជាសណ្តាប់ធ្នាប់ដែលបញ្ជាពីលើដោយប្រទេសឬក្រុមមួយដែលមានអំណាច ករណីសព្វថ្ងៃនេះគឺអាមេរិកផ្ទាល់តែម្តង ។ បើគេពឹងផ្អែកលើច្បាប់គឺគ្រាន់តែបំពេញទៅតាមចិត្តរបស់ប្រទេសដែលមានអំណាចតែប៉ុណ្ណោះ ។ ករណីសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីគឺជាឧទាហរណ៍មួយបញ្ជាក់ពីការសម្របសម្រួលច្បាប់អន្តរជាតិដើម្បីបម្រើឲ្យផលប្រយោជន៍ប្រទេសមានអំណាចដោយមិនឲ្យប្រទេស


យោធាខ្មែរក្រហម

ទាំងនេះទទួលខុសត្រូវអ្វីឡើយ ។ អង្គការណាតូបានវាយប្រហារតាមផ្លូវអាកាសដោយសារខ្លួនបានចោទប្រកាន់សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីថាបានបោសសម្អាតជនជាតិភាគតិច ប៉ុន្តែនៅពេលសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីប្ដឹងប្រទេសជាសមាជិកអង្គការណាតូដោយចោទថាប្រទេសទាំងនេះបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើប្រជាជននៃសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីតាមរយៈការរោយថ្នាំជាតិអ៊ុយរ៉ានីញ៉ូម និងទម្លាក់គ្រាប់បែកនោះ ប្រទេសជាសមាជិកអង្គការណាតូបានបដិសេធដែនសមត្ថកិច្ចរបស់តុលាការអន្តរជាតិយ៉ាងដាច់អហង្ការនិងយ៉ាងមានប្រសិទ្ធភាព ។ ប្រសិនបើការអះអាងរបស់អង្គការណាតូត្រឹមត្រូវពិតប្រាកដមែននោះ ម៉្លេះអង្គការណាតូប្រហែលជាប្ដឹងតបនឹងសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីវិញជាពុំខានឡើយ ដូចជាសហរដ្ឋអាមេរិកធ្វើកន្លងមកក្នុងករណីវិវាទរវាងសាធារណរដ្ឋអ៊ីរ៉ង់និងសហរដ្ឋអាមេរិក (នៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨) និងសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីអនុវត្តនៃអនុសញ្ញាស្ដីពីការទប់ស្កាត់និងផ្ដន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រទេសបូស្នៀនិងហ៊ើស៊ីហ្គោវីណា (ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧) ។ នៅក្នុងករណីសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីអង្គការណាតូមិនបានធ្វើដូចករណីខាងលើឡើយ ។

**ឆូច ប៉ូរ៉ា**



# ជីវប្រវត្តិរបស់បងស្រី អ៊ុម ផល្លី



អ៊ុម ផល្លី
(ថតនៅជំរំខាវអ៊ីដាង)

ដាំម្ចូ គឺជាឈ្មោះភូមិមួយស្ថិតនៅក្នុងឃុំវាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ខេត្តកំពង់ស្ពឺស្ថិតនៅក្នុងតំបន់៣២ ភូមិភាគនិរតី ។ ដាំម្ចូគឺជាស្រុកកំណើតរបស់បងស្រី អ៊ុម ផល្លី ហៅកែវ ។ បងស្រីអ៊ុម ផល្លី កើតនៅឆ្នាំ១៩៥៨ ជាកូនទី៣នៅក្នុងត្រកូលមធ្យមមួយ ។ ឪពុកឈ្មោះ អ៊ុម អឿ មានមុខរបរជាជាងមាស និងម្តាយឈ្មោះ ជាម សយ មេផ្ទះ ។ បងស្រីមានបងប្អូន៧នាក់ ស្រី៣នាក់ និងប្រុស៤នាក់ ។

នៅឆ្នាំ១៩៦៩រហូតដល់ឆ្នាំ១៩៧០ បងស្រីជាសិស្សនៅវិទ្យាល័យឧដុង្គ(ទីក្រុងចាស់) ខេត្តកំពង់ស្ពឺ ។ ប្រហែលគឺជាការបែងនៃអាក្រក់ ប្រទេសកម្ពុជាបានផ្លាស់ប្តូររបបគ្រប់គ្រងពីសង្គមរាស្ត្រនិយមទៅជារបបសាធារណរដ្ឋវិញ ស្របពេលជាមួយគ្នានោះចលនាខ្មែរក្រហមក៏បានកើតមានឡើង ។ ក្រុមគ្រួសាររបស់បងស្រី កែវ និងប្រជាពលរដ្ឋខ្មែរដែលស្ថិតនៅក្នុងស្រុកឧដុង្គទាំងមូលមានការព្រួយបារម្ភយ៉ាងខ្លាំងជាមួយនឹងស្នូរគ្រាប់កាំភ្លើងប៉ះទង្គិចរវាងទាហាន លន់ ណុល និងទាហានខ្មែរក្រហមដែលបាញ់តគ្នាឥតឈប់ឈរ ។

បងស្រី កែវ បានរៀបរាប់ពីហេតុការណ៍ដែលកើតមានឡើងចំពោះក្រុមគ្រួសាររបស់បងស្រីថាៈ នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានវាយដណ្តើមយកស្រុកឧដុង្គ ហើយក៏ជាឆ្នាំដែលបងស្រីត្រូវព្រាត់ប្រាសពីក្រុមគ្រួសារដែរ ។ ឪពុកម្តាយ បងប្អូនរបស់បងស្រីត្រូវកងទ័ពខ្មែរក្រហមជម្លៀសចេញ ដោយមិនដឹងថាទៅទីណាឡើយ ។ បងស្រីបានប្រាប់ពីមូលហេតុដែលគាត់ត្រូវបែកពីគ្រួសារនោះថាៈ ដោយសារតែមុនមួយថ្ងៃខ្មែរក្រហមវាយយកស្រុកឧដុង្គ បងស្រីបានទៅមើលជីដូនឈឺនៅឯបន្ទាយលង្វែក(ស្រុកកំណើតជីដូននិងម្តាយរបស់បងស្រី) ។ ដូច្នេះបងស្រីក៏រស់នៅជាប់ជាមួយជីដូនរហូតមក ។ បងស្រីបានរៀបរាប់ថាៈ «នៅពេលនោះហើយដែលខ្ញុំត្រូវក្លាយជាក្មេងកំព្រាមួយរូប ប៉ុន្តែទោះបីជាខ្ញុំត្រូវឃ្លាតឆ្ងាយពីឪពុកម្តាយ ក៏ខ្ញុំនៅតែព្យាយាមបន្តការសិក្សាទាំងត្រដាបត្រដួសរហូតដល់ខ្ញុំប្រឡងជាប់មធ្យមសិក្សាបឋមភូមិ» ។

ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសបានទទួលអបអរសាទរចំពោះជោគជ័យ ដោយប្រទេសត្រូវបានរំដោះពីសង្គ្រាមដ៏រ៉ាំរ៉ៃ ។ ប្រជាពលរដ្ឋខ្មែរសប្បាយរីករាយនឹងជោគជ័យនេះណាស់ ផ្ទុយទៅវិញខ្មែរក្រហមបែរជាយកថ្ងៃជ័យជម្នះនេះជម្លៀសប្រជាជនចេញពីផ្ទះសម្បែងភូមិឋាន ។ ចំណែកបងស្រី កែវ វិញ ក៏សង្ឃឹមថាថ្ងៃនេះនឹងបានជួបមុខឪពុកម្តាយបងប្អូនមិនខាន ប៉ុន្តែបែរជាត្រូវខកបំណងទៅវិញ ។

បងស្រី កែវ បានប្រាប់ថា គាត់និងជីដូនបានចាកចេញពីលំនៅដ្ឋាននៅបន្ទាយលង្វែកឆ្ពោះទៅខេត្តកំពង់ឆ្នាំង ។ នៅតាមផ្លូវគាត់ប្រទះឃើញសាកសពរដូករណែលពាសពេញផ្លូវ ។ បងស្រីបានសួរខ្លួនឯងថា «តើគាត់បានសាងបាបកម្មអ្វីបានជាជួបតែការព្រាត់ប្រាសបែបនេះ?» ។ បងស្រីបន្តទៀតថាៈ ក្បួនដំណើរជម្លៀសបានមកដល់ទីរួមខេត្តកំពង់ឆ្នាំង ប្រជាជនទាំងអស់រួមទាំងរូបបងស្រីត្រូវបានប្រមូលផ្តុំគ្នាដើម្បីស្តាប់អំពីផែនការរបស់ខ្មែរក្រហមរួចបំបែកគ្នាទៅកាន់កន្លែងរៀងៗខ្លួន ។ ព្រលឹមស្រាងៗ ឡើងខ្មែរក្រហមបានចេញបញ្ជាថ្មីឲ្យបងស្រីរៀបចំចេញ

ដំណើរទៅកាន់កន្លែងមួយដែលត្រូវជម្លៀសទៅ ។ នៅតាមផ្លូវធ្វើដំណើរ បងស្រីប្រទះឃើញសុទ្ធតែសាកសពដែលស្លាប់ដោយសារការហេវហត់ និងអត់អាហារ ។ បងស្រីបានប្រាប់ថា គាត់បានឃើញកងទ័ពរំដោះជាតិ (ខ្មែរក្រហម) បណ្តើរទាហានសាធារណរដ្ឋខ្មែរទាំងខ្សែៗយកទៅសម្លាប់ចោលដោយគ្មានរើសមុខ ។ ដំណើរជម្លៀសនេះបងស្រីត្រូវចំណាយអស់រយៈពេលពីរថ្ងៃ ទើបទៅដល់ភូមិត្រពាំងព្រីង ឃុំចោងម៉ោង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ជាកន្លែងដែលអង្គការខ្មែរក្រហមចាត់តាំងឲ្យបងស្រីស្នាក់នៅ ។ បីថ្ងៃក្រោយមក បងស្រីត្រូវអង្គការខ្មែរក្រហមប្រមូលនារីដែលនៅលីវៗឲ្យទៅរែកដី លើកទំនប់ និងជីកប្រឡាយ ។ ខ្មែរក្រហមបានប្រាប់ថា ប្រមូលនារីៗឲ្យចូលជាកងចល័ត ហើយកងចល័តនេះខ្មែរក្រហមចាត់តាំងឲ្យទៅកាន់តំបន់ព្រៃភ្នំមួយឆ្ងាយដាច់ពីភូមិអ្នកស្រុក ។ កងចល័តនេះត្រូវបានខ្មែរក្រហមចល័តពីកន្លែងមួយទៅកន្លែងមួយដោយគ្មានកំណត់គោលដៅច្បាស់លាស់ឡើយ ។ ថ្ងៃមួយអង្គការខ្មែរក្រហមបានដាក់ទិសថ្មីមកឲ្យកងចល័តរបស់បងស្រីទៅលើកប្រព័ន្ធភ្លឺស្រែក្បែរជើងភ្នំដើម្បីឲ្យកាប់ដីគាស់គល់ឈើទាំងយប់ទាំងថ្ងៃ គ្មានពេលសម្រាក ។ បងស្រីប្រាប់ឲ្យដឹងទៀតថា ពេលភ្លៀងរងា ញ័រញាក់ពេលដេក ត្រាំទឹក ពេលហូបមិនគ្រប់គ្រាន់ ធ្វើឲ្យគាត់នឹកដល់បងប្អូននិងឪពុកម្តាយរបស់គាត់ ព្រោះតែពីមុនមក គាត់មិនដែលជួបប្រទះនឹងសភាពកម្សត់វេទនាបែបនេះ ។ គាត់អស់សង្ឃឹមក្នុងជីវិត ។ មិនយូរប៉ុន្មានបងស្រីក៏ធ្លាក់ខ្លួនឈឺ ។ ពេលបងស្រីឈឺ មេក្រុមកងចល័តបានបញ្ជាឲ្យបងស្រីទៅសម្រាកនៅមន្ទីរពេទ្យឃុំអស់រយៈពេលមួយសប្តាហ៍ ។ នៅពេលចេញពីមន្ទីរពេទ្យ បងស្រីធ្វើដំណើរតាមផ្លូវដែលមានព្រៃអមសងខាងក្នុងសភាពស្ងាត់ជ្រងំ ហើយក៏ដួលសន្លប់នៅតាមផ្លូវតែម្តង ។ យោធាខ្មែរក្រហមម្នាក់ជាអ្នកបរទេះគោជីកជ្រូកជួយសង្គ្រោះរូបបងស្រី ។ យោធាខ្មែរក្រហមរូបនេះក៏នាំបងស្រីដល់កងចល័ត រួចហើយក៏បរទេះបន្តទៅមុខទៀត ។ ចំណែកបងស្រីបានដើរចូលទៅក្នុងរោងដែលគាត់ធ្លាប់ស្នាក់នៅ ។ នៅក្នុងរោងគ្មានមនុស្សម្នាក់សោះ ដោយសារថាកងចល័តនោះត្រូវផ្លាស់ទៅកន្លែងផ្សេងទៀតទៅហើយ ។ បងស្រីនៅក្នុងរោងនោះតែម្នាក់ឯង មិនដឹងថាត្រូវទៅទីណាទៀត ។ ដោយសារជំងឺនិងការអត់អាហារជាច្រើនថ្ងៃបានធ្វើឲ្យបងស្រីសន្លប់ម្តងទៀត ។ មិនដឹងជាមានរយៈពេលប៉ុន្មានថ្ងៃទេ ទើបបងស្រីដឹងខ្លួនពីសន្លប់វិញ ។ នៅពេលដែលគាត់ដឹងខ្លួន គាត់ដឹងថាខ្លួនគាត់ស្ថិតនៅក្នុងភូមិមួយដែលមានឈ្មោះភូមិស្រែខ្ទម នៅមិនឆ្ងាយពីភូមិត្រពាំងព្រីងប៉ុន្មានទេ ។ បងស្រីត្រូវស្ត្រីចំណាស់ម្នាក់ជួយសង្គ្រោះ ។ ស្ត្រីចំណាស់នោះបានសួរទៅបងស្រីថា «នាងនៅភូមិណាហេតុអីបានជាមកដេកសន្លប់នៅក្នុងខ្ទមដែលគ្មានមនុស្សនៅ?» ។ បងស្រីបានរៀបរាប់តាមដំណើររឿងឲ្យស្ត្រីនោះស្តាប់ ។ ពីរថ្ងៃក្រោយមក ជំងឺរបស់បងស្រីបានធូរស្បើយ ។ បងស្រីបានសុំឲ្យស្ត្រីចំណាស់នោះជូនគាត់ត្រឡប់ទៅភូមិដើម្បីជួបមុខជីដូនវិញ ។ នៅពេលមកដល់ភូមិវិញ គាត់បានឃើញនិងស្គាល់ច្បាស់ថា ជាជីដូនរបស់គាត់កំពុងត្បាញកន្ទេលស្លឹកត្នោត ផ្ទុយទៅវិញជីដូនរបស់គាត់ទេដែលមើលគាត់មិនស្គាល់នេះដោយសារតែសភាពស្គាំងស្គម ស្លេកស្លាំងរបស់បងស្រី ។ នៅពេលជីដូនរបស់បងស្រីស្គាល់ច្បាស់ថាជាចៅគាត់ក៏ទ្រហោយំតែម្តង ។

ជីដូនរបស់បងស្រីបានផ្សំថ្នាំខ្មែរឲ្យបងស្រីផឹកទាល់តែជាសះស្បើយ ។ មិនទាន់ទាំងជាស្រួលបួលផង មេភូមិបានឲ្យបងស្រីទៅធ្វើការជាមួយកងចាស់ៗ ។ បងស្រីត្រូវធ្វើការបណ្តើរ គ្រុនញាក់បណ្តើរ ។ អំបែកនៅលើស្មាជាប់ជានិច្ច ។ មួយឆ្នាំទល់មួយឆ្នាំបងស្រីមិនដែលបានស្គាល់រសជាតិបាយទេ គឺស្គាល់តែបបរលាយត្រកួននិងព្រលិត ។ បងស្រីរៀបរាប់ថា «យើងធ្វើការជិតគ្នារាប់រយនាក់ ប៉ុន្តែហាក់ដូចជាធ្វើម្នាក់ឯង ពីព្រោះយើងគ្មានសិទ្ធិនឹងជជែកគ្នាទេ ខ្មែរក្រហមបានបំបិទសិទ្ធិក្នុងការនិយាយស្តី ម្នាក់ៗគិតតែពីប្រឹងធ្វើការរៀងៗខ្លួន ពេលជួបមុខគ្នាបានត្រឹមតែសម្លឹងមើលមុខគ្នាក្នុងក្តីសោកសៅប៉ុណ្ណោះ» ។

មានពេលមួយនោះ បងស្រីកំពុងតែស្ពុងអារម្មណ៍ក្នុងភាពវេទនារបស់ខ្លួន ជើងរបស់បងស្រីកំពុងឈានឡើងទៅលើខ្នងទំនប់បានបន្តិច ស្រាប់តែវិលមុខហើយដួលធ្លាក់មកក្រោយវិញ ។ ឈ្លបខ្មែរក្រហមបានស្ទុះមកជិតគាត់ ហើយស្រែកខ្លាំងៗថា «យ៉ាងម៉េចចង់ងាប់ឬ បានធ្វើជាដួល ឬមួយមិត្តនារីឯងឈឺសតិអារម្មណ៍ កុំជិះជាន់ពលកម្មគេពេក ប្រយ័ត្នវាយកប់ចោល

នៅនឹងទំនប់នេះទៅ...» បងស្រីប្រាប់ថា «ពេលឮដូច្នោះខ្ញុំភ័យណាស់ស្ទុះក្រោកស្រវាដងវែកនិងបង្គីទៅរែកដីទាំងដើមទ្រូងញ័ររន្ធត់» ។ ក្រោយពេលត្រឡប់មកពីការដ្ឋានវិញ បងស្រីសម្រេចចិត្តត្រូវតែលួចរត់ចេញពីភូមិនេះដើម្បីទៅស្រុកកំណើត ទោះជាត្រូវជួបខុសគ្រោះរហូតដល់ស្លាប់ខ្លួនក៏ដោយ ក៏គាត់ត្រូវតែផ្សងព្រេង ។ បងស្រីបានលួចរត់កាត់ព្រៃភ្នំទាំងអត់បាយក្រហាយទឹក ។ ពេញមួយថ្ងៃរហូតដល់ម៉ោងប្រហែល៩-១០យប់ ទើបបងស្រីដើរមកដល់ផ្លូវជាតិលេខ៥ (ចន្លោះពីបន្ទាយលង្វែកនិងខដុង្គ) ។ បងស្រីត្រេកអរខ្លាំងណាស់ ព្រោះគាត់ស្គាល់ច្បាស់ថាជាកន្លែងដែលគាត់ធ្លាប់ជិះកង់លេងជាមួយមិត្តភក្តិ ។ បងស្រីបានបន្តដំណើរទាំងយប់ពីភូមិផ្សារត្រាចឆ្ពោះទៅខដុង្គដើម្បីចូលភូមិវិញ ។ ចូលដល់ភូមិមិនទាន់បានប៉ុន្មានម៉ែត្រផង ស្រាប់តែជួបប្រធានភូមិអំពិលដាំទឹកដែលបានស្គាល់ឪពុកម្តាយរបស់បងស្រីច្បាស់បានប្រាប់ថា ឪពុកម្តាយរបស់បងស្រីត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលតាំងពីឆ្នាំ១៩៧៤ម្ល៉េះ ដោយចោទប្រកាន់ថាជានាយទុនសក្តិភូមិមានកម្មសិទ្ធក្រាស់នៅជាប់នឹងខ្លួន ។

បងស្រីរៀបរាប់ទាំងទឹកភ្នែករលីងរលោងថាៈ «ខ្ញុំរស់នៅបានមកដល់សព្វថ្ងៃនេះ ក៏ដោយសារប្រធានភូមិនោះគាត់ជាអ្នកជួយយកខ្ញុំទៅលាក់ទុកនៅកន្លែងមួយដែលពុំមានអ្នកណាស្គាល់» ។

នៅឆ្នាំ១៩៧៧ អង្គការខ្មែរក្រហមបានដាក់ទិសឲ្យប្រធានភូមិជ្រើសរើសយកនារីៗដែលនៅក្នុងភូមិទាំងប៉ុន្មានឲ្យចូលជាកងចល័ត អ៊ីប្រធានភូមិបានបញ្ចូលបងស្រីទៅកងចល័តនោះដើម្បីគេចផុតពីការចាប់ខ្លួន ។ នៅក្នុងកងចល័ត បងស្រីមានមិត្តម្នាក់ឈ្មោះ សុផល អាយុស្រករនិងបងស្រីដែរ ប៉ុន្តែ សុផល ពុំមែនជាអ្នក១៧មេសាទេ ។ គាត់ទាំងពីរស្រឡាញ់គ្នាណាស់ ស៊ូទ្រាំអត់ឃ្លានជាមួយគ្នា រហូតដល់អង្គការខ្មែរក្រហមជម្លៀសគ្រួសារសុផល ទៅនៅខេត្តបាត់ដំបង ។ ចំណែកបងស្រីត្រូវខំប្រឹងធ្វើការបន្តនៅក្នុងកងចល័តដើម្បីប្តូរនឹងបបររាវលាយត្រកួនគ្រាន់សម្រន់ការស្រេកឃ្លានបានមួយពេលៗ ។

ថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ បានចូលមកដល់បងប្អូនប្រជាពលរដ្ឋទូទាំងប្រទេសបានរួចផុតពីទុក្ខវេទនានិងគុកឥតជញ្ជាំង ម្នាក់ៗមានទឹកចិត្តរីករាយក្នុងជីវិតថ្មី ។ ដោយឡែកតែបងស្រី កែវ ម្នាក់ប៉ុណ្ណោះ ដែលមានអារម្មណ៍ថា ពេលនេះថ្ងៃនេះ គាត់អាចជាន់លើគន្លងឆ្នាំ១៩៧៥ឬអត់ ។ ក្រោយពីរួចផុតពីសេចក្តីស្លាប់គាត់ត្រូវក្លាយទៅជាក្មេងកំព្រារស់នៅតែឯងគ្មានអ្នកទីពឹងឡើយ ។ បងស្រីនិយាយថា «គាត់មានទុក្ខសោកមួយជីវិតក្នុងការព្រាត់ប្រាសនិរាសបងប្អូនឪពុកម្តាយ ហើយទើបដឹងថាខ្លួនក្លាយជាកូនកំព្រាពិតប្រាកដ» ។

ចុងឆ្នាំ១៩៧៩ បងស្រីបានធ្វើដំណើរផ្សងព្រេងឆ្ពោះទៅជំរំជាយដែនខ្មែរ-ថៃ ដោយឆ្លងកាត់គ្រោះថ្នាក់ជាច្រើនទម្រាំតែទៅដល់ជំរំវិទ្ធិសែន ។ នៅឆ្នាំ១៩៨៧ បងស្រីសម្រេចកសាងជីវិតថ្មីជាមួយបុរសម្នាក់ដែលជាគ្រូបង្រៀននៅក្នុងជំរំនោះ រួចបន្តដំណើរឆ្ពោះទៅរស់នៅជំរំខាវអ៊ីដាង នៅលើទឹកដីជាយដែនកម្ពុជា ។ ប៉ុន្តែជាអកុសល សុភមង្គលរបស់បងស្រីនិងស្វាមីមិនបានឋិតថេរ ។ នៅឆ្នាំ១៩៩១ បងស្រីនិងស្វាមីបានចែកផ្លូវគ្នាដោយបន្សល់ទុកនូវកូនស្រីមួយដែលជាចំណងស្នេហ៍ដូរចត់របស់បងស្រី ។ បន្ទាប់ពីលែងលះមក បងស្រីបានត្រឡប់មករស់នៅមាតុប្រទេសវិញ ។ បច្ចុប្បន្ននេះបងស្រីគឺជាបុគ្គលិកពេទ្យឆ្មបម្នាក់នៅមន្ទីរពេទ្យផ្សារដើមថ្កូវ ក្រុងភ្នំពេញ ។

បងស្រីបានប្រាប់ជាចុងក្រោយថា គាត់គ្មានប្រាថ្នាចង់បានអ្វីទៀតឡើយ គឺគ្រាន់តែចង់មានតុលាការឯករាជ្យមួយដែលមានសច្ចធម៌និងយុត្តិធម៌ សម្រាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហមដែលបានសម្លាប់ប្រជាជនខ្មែរអស់រាប់លាននាក់ ។

**ឡុង អួន**

## ពាក្យស្លោកខ្មែរក្រហម

◆ **រៀនសូត្រតាមអង្គភាពឡើនលឿន វ៉ៃស្រអំបិល ការដ្ឋានដាំកៅស៊ូថ្មី បូព៌ា ស្រុកប្រសូត្រ កំពង់ត្រឡាចលើ និងត្រាំកក់ ដើម្បីគ្រប់គ្រងអង្គភាពទូទាំងប្រទេសទៅជាមហាចលនាបដិវត្តន៍ វាយសម្រុក មហាលោតផ្លោះ មហាអស្ចារ្យ!**

(សៀវភៅកំណត់ហេតុលេខ១០៧៦)

## ប្រលោមលោកបដិវត្តខ្មែរក្រហមៈ

# ពលិកម្មម៉ែឪយើង

ខ្ញុំជាកូនស្រីពៅក្នុងគ្រួសារមួយដែលមានគ្នា៤នាក់ ។ បងប្រុសខ្ញុំអាយុ១២ឆ្នាំ ។ ពុកនិងម៉ែខ្ញុំធ្វើស្រែ ដាំដំណាំ បេះក្រវាញ បោចវល្លិ និងកាប់ដើមរុនធ្វើកន្ទេលលក់ ។ យើងមានដីស្រែនិងដីចំការជិត១ហិកតាដែរ ។ ដីនេះបានមកដោយកម្លាំងញើសឈាមពុកនិងម៉ែ ។ កាលពីមុនទីនេះសុទ្ធតែជាព្រៃឈើធំៗ និងជាព្រៃឫស្សីចាក់ស្រេះចូលមិនចុះទេ ថែមទាំងជាទីលំនៅនៃសត្វព្រៃសាហាវផង ។ ពុកនិងម៉ែបានប្ដូរស្លាប់រស់ជាមួយសត្វព្រៃ ជាមួយការចាញ់ទឹកដី ធាតុអាកាសព្រៃភ្នំទើបអាចកាប់រានឆ្ការព្រៃស្ដុកនេះមកធ្វើដំណាំចិញ្ចឹមជីវិតបាន ។ ម៉ែតែងនិទានអំពីប្រវត្តិឆ្ការព្រៃតស៊ូនឹងធម្មជាតិប្រាប់យើងខ្ញុំជាញឹកញយ ហាក់ចង់បណ្ដុះយើងខ្ញុំឲ្យមានស្មារតីតស៊ូ ដំហរប្រយុទ្ធពុះពារឧបសគ្គ តាំងតែពីយើងខ្ញុំនៅតូចៗម្ល៉េះ ។

នៅមានភូមិណាល្អត្រកុំត្រកាលជាងភូមិសំឡូតយើងនេះ? នៅគ្រប់ផ្ទះមានដើមស្វាដុះខ្ពស់ស្រឡូនៗ ។ ដើមដូងដុះប្រជែងនឹងដើមស្វាទម្លាក់ផ្លែរាប់ធ្លាយពីក្រោមធាងនិងស្លឹកត្រសុំត្រសាយ ។ ដើមសាវម៉ាវ ដើមមង្ឃុត ដើមសិរមាន់ ដើមខ្នុរ ដើមស្វាយ ដើមចេក ដុះប្រណាំងគ្នាទ្រុបទ្រុល ។ បើយើងទៅឯក្រោយភូមិឆ្ងាយបន្តិច យើងនឹងបានបេះផ្លែដាក់កាវ៉ាន់ ផ្លែរកាំ កាដេន លលាស់ យ៉ង ពហូត ដំបង ប៉ង ប៉ាយ ក្រឡុំពុក ហូបមិនខានឡើយ ។

ប្រពៃណីរបស់អ្នកភូមិគឺរស់នៅក្នុងសាមគ្គីភាពភាតរភាពជាបងប្អូនសាច់មួយឈាមមួយយ៉ាងជិតស្និទ្ធបំផុត ។ នៅពេលដែលប្រជាជនណាម្នាក់ដាក់សត្វព្រៃបានមានជ្រូកព្រៃជាដើម បងប្អូនយើងតែងយកមកពន្លះសាច់ចែកគ្នាហូបគ្រប់ផ្ទះ មិនស្រវាស្រទេញសន្សំទុកប្រមែប្រមូលហូបតែម្នាក់ឯងឡើយ ។

ព្រឹកមួយ ពេលដែលបងប្អូនរួមភូមិយើងកំពុងភ្ជួរស្រែ ស្រាប់តែឃើញឡានកង់១០ពីរគ្រឿងដឹកទាហានពេញៗឡានប្រមាណ៦០នាក់ បើកលឿនស្ទេវហុយដីទ្រលោមមកឈប់ផ្ទក់នៅមុខស្រែយើង ។ រំពេចនោះ ពួកទាហានឡានមុខលោតចុះពីលើឡានព្រឹបៗបន្តបន្ទាប់គ្នា ។ ពួកវាប្រដាប់អាវុធគ្រប់ដៃរាយគ្នានៅតាមបណ្ដោយស្រែ ហើយតម្រង់មាត់ត្រែ កាំភ្លើងមករកយើងរាល់គ្នាតែម្ដង ។ ចំណែកឯអ្នកភូមិវិញក៏ទៅជាភ័ន្តភាំងឈរទ្រឹងធ្វើភ្នែកឡឹងឡង់ៗសម្លឹងគ្នាទៅវិញទៅមកជាសញ្ញាសួរគ្នា ហើយចាំមើលស្ថានការណ៍តទៅទៀតដោយស្ងៀមស្ងាត់ ។ ខ្ញុំស្មានតែពួកអស់នោះមកបាញ់សត្វ ព្រោះខ្ញុំធ្លាប់ឃើញពុកនាំបងទៅដាក់អន្ទាក់ឈ្លូស ជ្រូកព្រៃ ដោយយកកាំភ្លើងកិបទៅជាមួយផង ។ ខ្ញុំមើលទៅពុកនិងម៉ែ ឃើញគាត់បញ្ចេញទឹកមុខព្រួយបារម្ភនិងមិនពេញចិត្តចំពោះពួកទាហានអស់នោះទេ ។

បន្ទាប់មក ពួកទាហានឡានក្រោយក៏ចាប់បោះលួសបន្លាមួយចំនួននិងបង្គោលឈើជាច្រើនពីលើឡានទម្លាក់មកដី ។ រួចអាខ្លះចាប់ជីករណ្ដៅដាំបង្គោល អាខ្លះទៀតលាចផ្ដាយខ្សែលួសបន្លាចងភ្ជាប់ពីបង្គោលមួយទៅបង្គោលមួយយ៉ាងញាប់ដៃញាប់ជើង ។ មិនយូរប៉ុន្មាន បរិវេណដីស្រែចម្ការយើង ត្រូវហ៊ុមព័ទ្ធដោយលួសបន្លាជុំជិត ។ អ្នកភូមិជ្រួញចិញ្ចើមគ្រប់គ្នា ពុំដឹងថាពួកវារៀបចំគម្រោងធ្វើអ្វី? ដល់វាធ្វើរបងហើយ វាយកផ្លាកមួយធំល្មមទៅបោះភ្ជាប់នឹងបង្គោល ។ នៅលើផ្លាកនោះមានសរសេរថា÷ «ដីទាំងអស់នេះជាកម្មសិទ្ធិរបស់លោកវរសេនីយ៍ត្រីឈ្លួន» «ហាមមិនឲ្យចូលក្នុងទីនេះដោយគ្មានច្បាប់អនុញ្ញាត» «ជនណាដែលល្មើសនឹងបញ្ញត្តិនេះ នឹងត្រូវផ្ដន្ទាទោសតាមច្បាប់» ។

ចប់កិច្ចការវា ពួកនេះក៏ឡើងឡានព្រឹបៗទៅវិញអស់រលីង ។ កាលវាមកក៏វាអត់និយាយរកយើងមួយម៉ាត់ ។ ដល់វាទៅវិញក៏វាអត់លាយើងមួយម៉ាត់ដែរ វាចាត់ទុកពួកយើងនេះដូចជាបង្គោលឈើដែលវាដាំហើយមើលទៅ? ពួកវាចេញទៅ

បាត់ក្លាម ពួកយើងក៏នាំគ្នារត់ស្រទៅមើលសេចក្តីដែលចែងក្នុងផ្លាកនោះ ។ មើលចប់កាលណា ពុកខឹងញ័រដៃញ័រជើង ។ គាត់ហៀបនឹងយកខ្វែវកាប់ផ្លាកនោះចោលទៅហើយ តែបានម៉ែឃាត់ទាន់ ។ ម៉ែឲ្យយោបល់គាត់ថា “កុំអាលខឹងប្រឡោតពេក សួរយោបល់បងប្អូនយើងសិន” ។ ពុកឥតឆ្លើយទេ គាត់ស្តោះទឹកមាត់ឆ្ទាប់ដាក់លើបម្រាមវា ហើយដើរចេញទៅទាំងម៉ូរម៉ង ។ តាយុត, អ៊ីពាង, ពូណម, និយាយទាំងក្រេវក្រោធថា “ដីនេះយើងទាំងអស់គ្នាខំប្តូរអាយុជីវិតមិនគិតស្លាប់រស់ឡើយ ដើម្បីកែប្រែតំបន់ព្រៃស្តុកនេះមកជាដីបង្កបង្កើនផលយ៉ាងនេះបាន ។ ឥឡូវស្រាប់តែវាមកប្លន់ទាំងកណ្តាលថ្ងៃត្រង់ពីពួកយើងតែម្តង” ។ ពូសុខដេរប្រទេចផ្តាសា អាឈួន យ៉ាងខ្លាំង ។ មីងត្រប់ដាក់បណ្តាសាអាឃោរឃៅទាំងនោះឥតញញើតមាត់ឡើយ ។ តែម្នាក់ៗពុំដឹងដោះស្រាយយ៉ាងដូចម្តេច ។

អាឈួន នេះវាទើបមកនៅសំឡូតបាន៣ខែប៉ុណ្ណោះ តែវាមានឈ្មោះស្អុយអាសោចខាងអំពើឃោរឃៅយង់ឃ្នងពាលាអាវ៉ាសែពេញទាំងស្រុក ។ កាលពីថ្ងៃមុនដោយវាស្រវឹងស្រា វាបានបើកឡានកិនសម្លាប់ ពូចេវ ទាំងរទេះទាំងម្ចាស់នៅត្រង់អូរអំពិប ។ សាហាវណាស់ទៅទៀត ពេលដែលវាកិនហើយ វាមិនទាំងចុះមើលអ្នករងគ្រោះទៀតផង ។ គ្រួសារ ពូចេវ តវ៉ាទៅតាមច្បាប់ដែរ តែបាត់សូន្យឈឹង ។ ពួកវាទុកជីវិតកសិករក្រីក្រយើងមិនស្មើនឹងសត្វឆ្កែវាមួយផង ។ ក្រៅពីនេះ វាប្លន់ដីអ្នកស្រុកអ្នកភូមិយកធ្វើចំការដូរេន ចំការសាវម៉ាវ របស់វាយ៉ាងគឃ្លើនទៀត ។ ដី អាឈួន មាននៅគ្រប់ទីកន្លែង នៅស្រែអណ្តូងក៏មាន នៅស្រែពន្លឺក៏មាន នៅស្រែចាពៅក៏មាន នៅបាក់អំពង់ក៏មាន នៅកញ្ចាំងក៏មាន ។ ឥឡូវនេះវាមកប្លន់ដីអ្នកស្រុកភូមិខ្ញុំទៀត ។ ស្អែកឡើងយើងនាំគ្នាទៅធ្វើស្រែតាមធម្មតា ។ ទៅដល់ស្រែស្រាប់តែឃើញទាហានរបស់ អាឈួន ប្រហែល១០០នាក់នៅចាំការពារទីនោះស្រេចមិនឲ្យយើងធ្វើស្រែលើដីរបស់យើងដាច់ខាត ។ វាបាញ់កាំភ្លើងឡើងលើសម្លុតយើងដូងដាំងៗអស់មួយសន្ទុះធំទើបឈប់ ។ បងប្អូនយើងខ្លះភ័យរត់កាត់អូរ លបចូលពួនសំងំក្នុងគុម្ពឫស្សីដាច់ដៃដាច់ជើងឈាមហូរសស្រាក់ ។ អ្នកខ្លះក៏រត់មកផ្ទះវិញទាំងឈឺចាប់ខ្លោចផ្សានិងចងអាឃាតចំពោះពួកអាចោរប្លន់ដីទាំងនោះ ។

ក្រោយពីពួកអាជិះជាន់ទាំងនោះវាដេញអ្នកភូមិរត់ខ្ចាត់ខ្ចាយមិនឲ្យធ្វើស្រែមក តាយុត អ៊ំណម ក៏មកជំនុំគ្នាជាមួយពុកដើម្បីដោះស្រាយរឿងនេះ ។ តាយុត ពោលថា “បើយើងសុខចិត្តឲ្យដីរបស់យើងទាំងអស់ទៅអាពាលនោះ ហើយយើងទៅចាប់ដីថ្មីទៀតក៏ពុំកើតដែរ ពីព្រោះអាមេព្រៃដែលជា ភឿន របស់ អាឈួន វានឹងចេញច្បាប់មួយហាមឃាត់មិនអនុញ្ញាតឲ្យប្រជាជនណាកាប់ឈើមួយដើមក្នុងព្រៃដាច់ខាត ដោយវាអាងលេសថានាំឲ្យខូចខាតភោគទ្រព្យធម្មជាតិរបស់រដ្ឋ ។ តែខ្លួនវាវិញ កាប់ឈើទាំងហ៊ុបៗយកទៅសង់ផ្ទះឲ្យប្រពន្ធចុងវារាប់ខ្នង ហើយវាបើកដៃឲ្យអាថៅកែកាក់ “ក្រុមហ៊ុនមហាពាណិជ្ជ” កាប់ព្រៃយើងចង់វាលអស់រលីងទៅហើយ ។

កំពុងតែនិយាយស្រាប់តែឃើញអាអង្គរក្សរបស់ អាឈួន ដើមតំរង់ផ្ទះយើងតែម្តង ។ វាឡើងមកលើផ្ទះតាំងៗសឹងរលំខ្ទម ។ មកដល់មុខយើងវាទឹមចង្កេះពោលទាំងរបៀបខ្មោះខ្វូរថា “លោកសក្តិ៤បញ្ជូនយើងមកប្រាប់ពួកឯងថា បើចង់បានដីធ្វើស្រែ លោកយកឈ្នួល១រដូវ១០០ថាំងក្នុងគ្រួសារនីមួយៗ ។ នេះមកពីលោកអាណិតអាសូរពួកឯងពេក លោកចង់ស្រោចស្រង់ឲ្យរួចពីភាពក្រតោកយ៉ាងសព្វថ្ងៃនេះខ្លាំងណាស់ ។ យើងមកប្រាប់តែប៉ុណ្ណោះទេ! យើងលាហើយ!” ។

តាំងពីពេលនោះមក អ្នកភូមិយើងត្រូវជួលដី អាឈួន ធ្វើស្រែគ្រប់ៗគ្នា ។ យើងក៏ក្លាយទៅជាកូនបំណុលរបស់វាឥតមាននរណាម្នាក់គេចរួចឡើយ ។ ជីវភាពប្រជាជនកាន់តែត្រដាបត្រដួសខ្លាំងឡើងៗ ។ មួយគ្រួសារៗធ្វើយ៉ាងច្រើនបានពី១២០ទៅ១៥០ថាំង ។ ពេលមានជំងឺគឺជាពេលជំពាក់បំណុលគេវ័ណ្ឌក ។ ចំណែកឈ្នួលដីរបស់ អាឈួន ត្រូវតែឲ្យវាគ្រប់ចំនួនកំណត់ទើបបាន ។ បើពុំដូច្នោះទេ វាបញ្ជូនទាហានវាមកធ្វើទុក្ខបុកម្នេញយ៉ាងព្រៃផ្សៃបំផុតទៅលើអ្នកជំពាក់បំណុលនោះ ។ យ៉ាងនេះហើយទើបបងប្អូនយើងទោះបីឈឺក្តី ឬមានធុរៈក្តី ឬអត់ឃ្លានយ៉ាងណាក្តី គឺខិតខំលៃលកដើរខ្ចីគេខ្ចីឯងក៏ខ្ចីដែរ លក់បញ្ចាំគេរអាករក៏លក់ដែរ ឲ្យតែបានថ្លៃឈ្នួលដី“ជូនលោកសក្តិ៤ ឈួន” ។

**(នៅមានត)**

# លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

*អាត្មាទើបត្រឡប់មកពីសហរដ្ឋអាមេរិកវិញ បានឃើញទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលផ្ញើទៅអាត្មាហើយ ។ សូមថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ខំចំណាយពេលផ្ញើទៅនេះ ។ ឯកសារដ៏មានតម្លៃជាប្រវត្តិសាស្ត្រនេះបានតម្កល់ទុកក្នុងវត្តសម្រាប់ជូនសាធារណជនមើល ។ នឹងផ្ញើវិភាគទានជាបច្ច័យនៅពេលក្រោយ ។*

*អាត្មាបានស្តាប់វេទិកាអ្នកស្តាប់តាមវិទ្យុអាស៊ីសេរីនៅថ្ងៃច័ន្ទ ៣ ធ្នូ និយាយអំពីការកាត់ទោសខ្មែរក្រហម ។ បើមានប្រសាសន៍ម្តងទៀត សូមមេត្តាជួយមានប្រសាសន៍អំពីវិនាសកម្មរបស់ពុទ្ធសាសនានៅពេលនោះ តាមឯកសារដែលបានស្រាវជ្រាវឃើញ ដូចជាធ្វើគុតព្រះសង្ឃ បង្ខំឲ្យសឹក រំលាយវត្ត ដុតសៀវភៅធម៌ជាដើម មានលក្ខណៈយ៉ាងណាខ្លះ?*

*សូមជូនពរសព្ទសាធុការ សូមការរកយុត្តិធម៌ជូនប្រជាពលរដ្ឋខ្មែរអ្នករងគ្រោះនេះបានសម្រេចដោយជោគជ័យ ។*

**ពីអាត្មា ហុក សុខណ្ណ**
**ប្រទេសកាណាដា**



កុមារបដិវត្ត

**ចម្រៀងបដិវត្ត**

# យើងខ្ញុំប្រជាជនសូមសរសើរបងប្អូនកងទ័ពបដិវត្តន៍

ឱះឱបងប្អូនៗកងទ័ព
អ្នកវាយខ្មាំងដារំដោះជាតិ
រំដោះប្រជាជនអើយនឹងមិត្តញាតិ
យកជ័យល្អស្អាត ខែមេសា ។
យើងខ្ញុំទាំងអស់រំភើបពេកក្រៃ
ចំពោះស្មារតីអង់អាចក្លៀវក្លា
វីរភាពបដិវត្តបងប្អូនរាល់គ្នា
ហ៊ានលះបង់ជីវ៉ាគ្មានស្តាយស្រណោះ ។
ចាប់តាំងតែពីបាតដៃទទេ
បងប្អូនរិះរេ ច្នៃប្រឌិតខ្ពស់
ហ៊ានវាយមេខ្លាំងអើយធំបង្អស់
ចក្រពត្តិទុរយសចោរអាគាំង ។
បងប្អូនរួមចំណែកធំប្រាកដ
ក្នុងការបើកប្រវត្តិថ្មីស្រឡាង
កម្ពុជាឯករាជ្យ ម្ចាស់ការភ្លឺស្វាង
ឆ្អិនឆ្អៅចែងចាំងពេញសាកល ។
កម្មករ   កសិករ   អ្នកក្រខ្សត់
កាលដើមកប់បាត់ក្នុងសំណល់
ពេលនេះលេចធ្លោអើយថ្លៃវិបុល
ធ្វើម្ចាស់លើផលបដិវត្ត ។
បងប្អូនធ្វើម្ចាស់លើវាសនា
ម្ចាស់លើកិច្ចការអំណាចរដ្ឋ
មានសិទ្ធិសេរី អើយមានមុខមាត់
អត្តភាពផង់ជាតិចោលឈ្ងុយឈ្ងប់ឆ្ងាយ ។
នេះគឺមកពីបងប្អូនរាបសា
គោរពអង្គការនឹងវិន័យ
ទៅតាមប្រពៃណី អើយដ៏ថ្លាថ្លៃ
បដិវត្តមានជ័យរបស់យើង ។
បងប្អូនមានសីលធម៌បដិវត្ត
សីលធម៌ប្រយុទ្ធមុតស្រួចរឹងប៉ឹង
មានកំហឹងជាតិ អើយក្តៅដូចភ្លើង
ស្នេហ៍ប្រជាជនយើងយ៉ាងមោះមុត ។
យើងខ្ញុំសូមសរសើរបងប្អូនរាល់គ្នា
បងប្អូនពិតជាកងទ័ពបដិវត្ត
ពិតជាកូនចៅប្រជាជនក្រខ្សត់
កូនអង្គការបដិវត្តកម្ពុជា ។
យើងសូមជូនពរជ័យ
បងប្អូនទាំងឡាយមាំមួនខ្លាំងក្លា
សម្រេចជោគជ័យ អើយថ្មីទៀតណា
ក្នុងកិច្ចការពារនឹងកសាងជាតិ
ទៅជាបង្អែកបដិវត្តកម្ពុជា
រឹងប៉ឹងអស្ចារ្យរុងរឿងអើយ ។


ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the truth. Number 25,January 2002.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; Canadian International Development Agency (CIDA) through the Civil Society Fund; the Royal Danish Government and the Royal Netherlands Government, *The Hague*.